## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université royale de droit et des sciences économique

Royal University of Law and Economics


### សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃរូបវន្តបុគ្គល

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ ៖ លោក **លេខ ខ្មៀន**

កញ្ញា **ម៉េង គីមមួយ**

ណែនាំដោយ៖

**បណ្ឌិត ទេព សុខ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២៣**

ឆ្នាំចូលសិក្សា **២០១៩**

ឆ្នាំសរសេរសារណា **២០២៣**

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំឈ្មោះ **ម៉េង គីមមួយ** និង **លេខ ឡៃន** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី**២៣** នៅក្នុងឆ្នាំសិក្សា **២០១៩-២០២៣** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមសម្តែងនូវការគោរព និងថ្លែងនូវកតញ្ញូដឹងគុណដ៏ជ្រាលជ្រៅបំផុតជូនដល់លោកឪពុក អ្នកម្តាយ ដែលជាអ្នកមានគុណទាំងទ្វេរបស់យើងខ្ញុំដែលលោកបានផ្តល់កំណើត ព្រមទាំងផ្តល់នូវការចិញ្ចឹមបីបាច់ថែរក្សា អប់រំប្រៀនប្រដៅដល់យើងខ្ញុំដែលត្រូវជាកូនប្រុសស្រីដោយក្តី មេត្តា ករុណា មុទិតា និង ឧបេក្ខា ជាអនេកប្បការបំផុត។ មិនត្រឹមតែប៉ុណ្ណោះ លោកបានលះបង់ទាំងកម្លាំងកាយកម្លាំងចិត្ត និងបានផ្គត់ផ្គង់គ្រប់សព្វបែបយ៉ាងទាំងផ្នែកថវិកា ទាំងផ្នែកសម្ភារៈផ្សេងៗមកកាន់យើងខ្ញុំដែលត្រូវជាកុលបុត្រកុលធីតាគ្រប់រូប ដោយលោកមិនដែល គិតពីភាពនឿយហត់ ឬឧបសគ្គអ្វីទាំងអស់ចំពោះខ្លួនឡើយ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនដល់**ឯកឧត្តមសាកលវិទ្យាធិការសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូជាសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំអស់ពីសមត្ថភាពក្នុងការផ្ទេរនូវរាល់ចំណេះដឹងដល់យើងខ្ញុំទាំងអស់គ្នា ជាពិសេសគឺការតម្រង់ទិសដើម្បីធ្វើឱ្យពួកយើងខ្ញុំក្លាយជានិស្សិតល្អ កូនល្អ និងជាពលរដ្ឋល្អ ប្រកបដោយ សីលធម៌ សុជីវធម៌ គុណធម៌ និងចំណេះដឹងនៅក្នុងសង្គមជាតិទាំងមូល តាមរយៈការចូលរួមចំណែក ក្នុងការអភិវឌ្ឍសង្គមជាតិអោយមានភាពរីកចម្រើន។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនដល់លោកគ្រូ **បណ្ឌិត ទេព សុខ** ដែលជាសាស្ត្រាចារ្យណែនាំនៅក្នុងកិច្ចការស្រាវជ្រាវនៃការសរសេរសារណាមួយនេះ ដោយលោកគ្រូបានខិតខំចំណាយនូវពេលវេលាដ៏មានតម្លៃ ទាំងកម្លាំងកាយចិត្ត និងកម្លាំងប្រាជ្ញា ព្រមទាំងបានផ្តល់នូវគំនិត និងបានផ្តល់នូវអនុសាសន៍ល្អៗក្នុងការដឹកនាំយើងខ្ញុំដោយយកចិត្តទុកដាក់អស់ពីសមត្ថភាព តាមរយៈការផ្តល់ជាយោបល់នៅក្នុងការកែសម្រួល និងផ្តល់ឯកសារជំនួយស្មារតីផ្សេងៗ ដើម្បីជួយតម្រង់ទិសដល់យើងខ្ញុំរយៈពេលកន្លងមករហូតដល់ស្នាដៃមួយនេះបានលេចចេញជារូបរាងឡើងមក។

ជាចុងក្រោយ យើងខ្ញុំដែលជាកូនៗ សូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ ចូលកើតមានដល់ លោកអ្នកមានគុណទាំងទ្វេ លោកគ្រូ **បណ្ឌិត ទេព សុខ** ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលវេលាក្នុងការបង្ហាត់បង្រៀនកន្លងមកនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច សូមគោរពជូនពរអោយជួបប្រទះនូវពុទ្ធពរ ទាំងឡាយបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ក្រោយពីបានឆ្លងកាត់ការសិក្សា និងក្រេបជញ្ជក់នូវចំណេះដឹងអស់រយៈពេល៤ឆ្នាំកន្លងមកនេះនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំក៏បានសម្រេចចិត្ត ជ្រើសរើសយកប្រធានបទស្តីពី "**របបគតិយុត្តនៃរូបវន្តបុគ្គល**" ក្នុងការសរសេរជាសារណាដែលមានលោកគ្រូណែនាំដោយ **បណ្ឌិត ទេព សុខ** ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាកិច្ចការសារណាដែលជាឯកសារបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

ការជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ គឺពុំមែនជារឿងដៃរចៃដន្យនោះទេ ប៉ុន្តែវាជាការពិចារណាយ៉ាងហ្មត់ចត់ តាមរយៈការសិក្សាលើអត្ថបទច្បាប់ដែលពាក់ព័ន្ធកន្លងមកនេះ គឺដោយសារតែយល់ឃើញថា ការយល់ដឹងអំពីការទទួលសិទ្ធិនិងការកម្រិតនៃសិទ្ធិរបស់ខ្លួន ដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងសង្គម ដើម្បីធ្វើឱ្យមានការល្អប្រសើរសម្រាប់បុគ្គលគ្រប់រូប។ ទន្ទឹមនឹងនេះផងដែរ ប្រធានបទនេះក៏បានឆ្លងកាត់នូវការពិគ្រោះ និងបានផ្តល់ជាយោបល់ពីសំណាក់លោកគ្រូសាស្ត្រាចារ្យ ក្នុងការសរសេរសារណានេះផងដែរ។

យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលបានសរសេរសារណាក្រោមប្រធានបទស្តីអំពីរបបគតិយុត្តនៃរូបវន្តបុគ្គល ដែលមានលោកគ្រូណែនាំគឺ **បណ្ឌិត ទេព សុខ** ដោយលោកគ្រូបានផ្តល់ជាគំនិត យោបល់ ការណែនាំ ព្រមទាំងផ្តល់នូវឯកសារផ្សេងៗដល់យើងទាំងពីរដើម្បីជាគំនិតបន្ថែមនៅក្នុងកិច្ចការនៃការសរសេរសារណាមួយនេះអោយទទួលបាននូវផ្លែផ្កា និងបញ្ចប់ទៅបានយ៉ាងល្អប្រសើរ។ យើងខ្ញុំសង្ឃឹមថាសារណាមួយនេះជាកិច្ចការដែលបានកើតចេញពីការខិតខំប្រឹងប្រែងនៃក្រុមយើងខ្ញុំផ្ទាល់ គឺជាផ្នែកមួយដែលបានផ្តល់ចំណេះដឹងបន្ថែមមួយកម្រិតទៀត ព្រមទាំងបានផ្តល់ជាផលប្រយោជន៍ដល់មិត្ត សិស្ស និស្សិតអ្នកអាន ឬអ្នកដែលកំពុងតែធ្វើការសិក្សាស្វែងយល់ និងស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទមួយនេះ ព្រមទាំងបានបន្សល់ទុកនូវកម្រងស្នាដៃស្រាវជ្រាវមួយដើម្បីទុកជាឯកសារជំនួយស្មារតីបន្ថែមពេលដែលនិស្សិតជំនាន់ក្រោយៗត្រូវការផងដែរ។

បើទោះបីជាមានការខិតខំសិក្សាស្រាវជ្រាវ និងការត្រួតពិនិត្យហ្មត់ចត់យ៉ាងណាក៏ដោយ ក៏ការសរសេរសារណានេះពិតណាស់ថានិងមានការកើតមានឡើងនូវចំណុចមួយចំនួនដែលខ្វះខាត ដូចនេះយើងខ្ញុំ ទាំងពីរនាក់ សូមស្វាគមន៍នូវរាល់មតិរិះគន់នៅក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ សាស្ត្រាចារ្យ មិត្តនិស្សិតអ្នកអាន និងមិត្តអ្នកសិក្សាស្រាវជ្រាវនៅគ្រប់មជ្ឈដ្ឋានទាំងអស់ ដោយសេចក្តីគោរព និងដោយសុទ្ធចិត្តពីយើងខ្ញុំផងដែរ។ តាមរយៈការកែលម្អនូវកិច្ចការសារណានេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរ ពោលគឺដើម្បីឱ្យកម្រងឯកសារ នៃកិច្ចការស្រាវជ្រាវមួយនេះកាន់តែមានអត្ថន័យ និងខ្លឹមសារកាន់តែល្អ រឹតតែច្បាស់លាស់ និងមានភាពស៊ីជម្រៅថែមទៀតផង។

# មាតិកា

**សេចក្តីថ្លែងអំណរគុណ** ........ I

**អារម្ភកថា** ........ II

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណគតិយុត្តស្តីពីសិទ្ធិរូបវន្តបុគ្គល**

**១.១. អត្ថន័យនៃសិទ្ធិបុគ្គល** ........ ៣

**១.២. គោលការណ៍អនុវត្តសិទ្ធិជាមូលដ្ឋាននៃរូបវន្តបុគ្គល** ........ ៣

**១.២.១. គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ** ........ ៣

ក. សិទ្ធិទាមទារឱ្យបញ្ឈប់ ........ ៤

ខ. សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ ........ ៤

គ. សិទ្ធិទាមទារសំណងការខូចខាត ........ ៥

**១.២.២. គោលការណ៍មិនរំលោភបំពានដាច់ខាតលើកម្មសិទ្ធិ** ........ ៥

**១.២.៣. គោលការណ៍ស្វ័យភាពបុគ្គលឯកជន** ........ ៦

**១.២.៤. គោលការណ៍សុចរិត និងភាពស្មោះត្រង់** ........ ៧

**១.៣. ការហាមប្រើប្រាស់សិទ្ធិដោយបំពាន** ........ ៧

១.៣.១ គោលបំណង ........ ៧

១.៣.២ អានុភាពនៃការប្រើប្រាស់សិទ្ធិដោយបំពាន ........ ៧

**ជំពូកទី២**

**ការចាប់ផ្តើម និងបញ្ចប់នៃសមត្ថភាពទទួលសិទ្ធិនៃរូបវន្តបុគ្គល**

**២.១. ការចាប់ផ្តើមសមត្ថភាពទទួលសិទ្ធិនៃរូបវន្តបុគ្គល** ........ ១០

**២.១.១. អត្ថន័យ និងអត្តសញ្ញាណនៃរូបវន្តបុគ្គល** ........ ១០

ក. អត្ថន័យនៃរូបវន្តបុគ្គល ........ ១០

ខ. អត្តសញ្ញាណនៃរូបវន្តបុគ្គល ........ ១១

**២.១.២. គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ** ........ ១១

**២.១.៣. ពេលចាប់ផ្តើមនៃសមត្ថភាពទទួលសិទ្ធិ** ........ ១២

ក. គោលការណ៍ទូទៅ ..... ១២
ខ. ករណីលើកលែង ..... ១៣
**២.២. ការបញ្ចប់នៃសមត្ថភាពទទួលសិទ្ធិនៃរូបវន្តបុគ្គល** ..... ១៥
**២.២.១. ការទទួលមរណភាព** ..... ១៥
ក. សំបុត្រមរណភាព ..... ១៥
ខ. អត្ថិភាពនៃបុគ្គលភាពគតិយុត្តក្រោយពេលស្លាប់ ..... ១៥
**២.២.២. ការប្រកាសបាត់ខ្លួននៃរូបវន្តបុគ្គល** ..... ១៦
ក. ការប្រកាសបាត់ខ្លួនធម្មតា ..... ១៧
ខ. ការប្រកាសបាត់ខ្លួនពិសេស ..... ១៧
**២.២.៣. អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន** ..... ១៧
**២.២.៤. អានុភាពការលុបចោលការប្រកាសបាត់ខ្លួន** ..... ១៨
**២.២.៥. ការចាត់ទុកថាបានទទួលមរណភាពស្របពេលជាមួយគ្នា** ..... ១៨

**ជំពូកទី៣**

**ជនដែលត្រូវកម្រិតសមត្ថភាពក្នុងការបង្ហាញឆន្ទៈ**

**៣.១. អានុភាពនៃការខ្វះសមត្ថភាពខាងឆន្ទៈ** ..... ២១
**៣.២. សមត្ថភាពក្នុងការធ្វើសកម្មភាព** ..... ២២
**៣.២.១. អនីតិជន** ..... ២៣
**៣.២.២. ជននៅក្រោមអាណាព្យាបាលទូទៅ** ..... ២៥
**៣.២.៣. ជននៅក្រោមហិតូបត្ថម្ភ** ..... ២៧
**៣.៣. ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព** ..... ២៩
**៣.៣.១. សិទ្ធិដាស់តឿន** ..... ៣០
**៣.៣.២. ការឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព** ..... ៣១
**៣.៣.៣ មធ្យោបាយឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព** ..... ៣២
**សេចក្តីសន្និដ្ឋាន** ..... ៣៤
**អនុសាសន៍** ..... ៣៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ចាប់តាំងពីអតីតកាលមកដល់បច្ចុប្បន្ននេះ បុគ្គលគ្រប់រូបកើតមករមែងទទួលបាននូវសិទ្ធិ។ គ្រប់សិទ្ធិដែលពួកគេទទួលបាន គឺអាចយកទៅប្រើប្រាស់បំពេញកាតព្វកិច្ចក្នុងជីវភាពប្រចាំថ្ងៃបាន។ កត្តាទាំងនេះហើយបានមានចំណោទមួយសួរថា តើសិទ្ធិដែលបុគ្គលគ្រប់រូបទទួលបាន ត្រូវកម្រិតសមត្ថភាពទទួលសិទ្ធិដែរឬទេ? បញ្ហាទាំងនេះហើយដែលបុគ្គលគ្រប់រូបគួរតែសិក្សាឈ្វេងយល់ឱ្យកាន់តែច្បាស់ ដើម្បីជៀសវៀងមានកំហុសឆ្គងអាចឈានដល់ការរំលោភបំពានដល់សិទ្ធិអ្នកដ៏ទៃដោយមិនដឹងខ្លួន។ ម្យ៉ាងវិញទៀត **ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា**ក៏បានបែងចែកយ៉ាងច្បាស់ផងដែរ អំពីសិទ្ធិបុគ្គល ការចាប់ផ្តើមទទួលសិទ្ធិ និងការបញ្ចប់នៃការទទួលសិទ្ធិ ព្រមទាំងការកម្រិតសមត្ថភាពនៃរូបវន្តបុគ្គលផងដែរ។ បញ្ហាទាំងនេះហើយបានជាយើងខ្ញុំបានលើកយកប្រធានបទមួយមកបកស្រាយឱ្យកាន់តែច្បាស់គឺ **របបគតិយុត្តនៃរូបវន្តបុគ្គល** ដែលជាប្រធានបទមួយដ៏សំខាន់ក្នុងការសិក្សាឈ្វេងយល់អំពីសិទ្ធិ និងករណីយកិច្ចក្នុងជីវភាពប្រចាំថ្ងៃរបស់បុគ្គលគ្រប់រូប។

គោលបំណងរបស់យើងខ្ញុំក្នុងការជ្រើសរើសយកប្រធានបទ **របបគតិយុត្តនៃរូបវន្តបុគ្គល**នេះមកចងក្រងសរសេរជាសារណា វាមិនមែនជាប្រធានបទថ្មីនោះទេ សម្រាប់សិស្ស-និស្សិត ព្រមទាំងប្រជាជនកម្ពុជា។ ប៉ុន្តែយើងខ្ញុំបានមើលឃើញថាដោយសារមានការភាន់ច្រឡំក្នុងចំណុចមួយចំនួនដែលបានមើលរំលង។ ដូច្នេះហើយបានជាយើងខ្ញុំចង់ចែករំលែក ព្រមទាំងពន្យល់លម្អិតអំពីប្រធានបទមួយនេះផងដែរ។

**តើរបបគតិយុត្តនៃរូបវន្តបុគ្គលបានប្រព្រឹត្តឡើងយ៉ាងដូចម្តេច?**

មុនឈានដល់ការបកស្រាយក្នុងប្រធានបទទាំងមូល យើងទាំងអស់គ្នាដឹងហើយថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានឱ្យនិយមន័យនៃសិទ្ធិបុគ្គល គឺសំដៅទៅលើសិទ្ធិដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិត រូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬសិទ្ធិផ្សេងទៀតដែលជាផលប្រយោជន៍ទាក់ទងនឹងលក្ខណៈបុគ្គល។ ចំណែក រូបវន្តបុគ្គល គឺបុគ្គលគ្រប់រូប មានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។ ជាគោលការណ៍ គ្រប់រូបវន្តបុគ្គលទាំងអស់ មិនថាជាជនជាតិខ្មែរ ឬជនជាតិបរទេស អាចទទួលបាននូវសិទ្ធិដូចគ្នា។ ប៉ុន្តែចំពោះជនបរទេសដែលរស់នៅលើទឹកដីខ្មែរត្រូវបានក្រមរដ្ឋប្បវេណីកម្រិតនៅសិទ្ធិមួយចំនួន គឺជនជាតិបរទេស មិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។

ហេតុនេះសិស្ស និស្សិតពិតជាចង់ដឹងហើយថា តើសមត្ថភាពទទួលសិទ្ធិចាប់ផ្តើមពីពេលណា របបគតិយុត្តនៃរូបវន្តបុគ្គលត្រូវមានលក្ខខណ្ឌអ្វីខ្លះ?

កត្តាទាំងនេះហើយយើងខ្ញុំបានបែងចែកសារណារជាមាតិកាធំៗដូចខាងក្រោមនេះ ៖

**ជំពូកទី១៖ សញ្ញាណគតិយុត្តស្តីពីសិទ្ធិរូបវន្តបុគ្គល** ១.១. អត្ថន័យនៃសិទ្ធិបុគ្គល ១.២. គោលការណ៍អនុវត្ត សិទ្ធិជាមូលដ្ឋាននៃរូបវន្តបុគ្គល ១.៣. ការហាមប្រើប្រាស់សិទ្ធិដោយបំពាន

**ជំពូកទី២៖ ការចាប់ផ្តើម និងបញ្ចប់នៃសមត្ថភាពទទួលសិទ្ធិនៃរូបវន្តបុគ្គល**២.១. ការចាប់ផ្តើមសមត្ថភាពទទួល សិទ្ធិនៃរូបវន្តបុគ្គល ២.២. ការបញ្ចប់នៃសមត្ថភាពទទួលសិទ្ធិនៃរូបវន្តបុគ្គល

**ជំពូកទី៣៖ ជនដែលត្រូវកម្រិតសមត្ថភាពក្នុងការបង្ហាញឆន្ទៈ** ៣.១. អានុភាពនៃការខ្វះសមត្ថភាពខាងឆន្ទៈ ៣.២. សមត្ថភាពក្នុងការធ្វើសកម្មភាព ៣.៣. ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព

# ជំពូកទី១

# សញ្ញាណគតិយុត្តស្តីពីសិទ្ធិរូបវន្តបុគ្គល

# ជំពូកទី១

# សញ្ញាណគតិយុត្តស្តីពីសិទ្ធិរូបវន្តបុគ្គល

ក្រមរដ្ឋប្បវេណីបានបង្កើតឡើងក្នុងគោលការណ៍ការធានានូវសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និងសិទ្ធិលើទ្រព្យសម្បត្តិដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ។ កាលណាបុគ្គលគ្រប់រូបបានប្រើប្រាស់សិទ្ធិរបស់ខ្លួនដោយបំពាន នោះក្រមរដ្ឋប្បវេណីមិនទទួលស្គាល់ទេ ដូច្នេះការប្រើប្រាស់សិទ្ធិដោយបំពានអាចយកមកអនុវត្តបានចំពោះការអនុវត្តកាតព្វ សិទ្ធិប្រត្យក្ស កិច្ចសន្យា សេចក្តីចម្រើនឥតហេតុ ឬអំពើអនីត្យានុកូល។

## ១.១. អត្ថន័យនៃសិទ្ធិបុគ្គល

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានឱ្យនិយមន័យនៃសិទ្ធិបុគ្គល គឺសំដៅទៅលើសិទ្ធិដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិត រូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬសិទ្ធិផ្សេងទៀតដែលជាផលប្រយោជន៍ទាក់ទងនឹងលក្ខណៈបុគ្គល។[1]

បើយោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ កថាខណ្ឌទី២ បានចែងថា ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ជាដើមកំណើតជាតិឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌកំណត់ក្នុងច្បាប់។[2]

## ១.២. គោលការណ៍អនុវត្តសិទ្ធិជាមូលដ្ឋាននៃរូបវន្តបុគ្គល

### ១.២.១. គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ហើយនីតិបុគ្គលក៏មានសិទ្ធិនេះដែរ។[3] លក្ខណៈសម្បត្តិក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចនេះ ត្រូវបានឱ្យឈ្មោះថា "**សមត្ថភាពទទួលសិទ្ធិ** " កម្មវត្ថុនៃសមត្ថភាពទទួលបានសិទ្ធិ ក្រៅពីរូបវន្តបុគ្គល គឺជានីតិបុគ្គល។[4]

[1] មាត្រា ១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[2] មាត្រា ៣១ កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[3] មាត្រា ៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[4] មាត្រា ៤៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

**ក. សិទ្ធិទាមទារឱ្យបញ្ឈប់**

ចំពោះសិទ្ធិទាមទារឱ្យបញ្ឈប់ ប្រសិនបើមានការបារម្ភថានឹងអាចមានការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់ ឬមានការបារម្ភថា ការរំលោភសិទ្ធិបុគ្គលដែលបានកើតឡើងហើយនោះ នឹងអាចបន្តឬនឹងអាចកើតឡើងម្តងទៀតដោយខុសច្បាប់ អ្នកដែលមានសិទ្ធិបុគ្គលអាចទាមទារឱ្យបញ្ឈប់នូវការរំលោភនោះបាន។ [5] នេះគឺជាបញ្ញត្តិដែលចែងអំពីករណី ដែលអាចមានការរំលោភបំពាននូវសិទ្ធិបុគ្គលនោះ ប៉ុន្តែនៅមិនទាន់បានទទួលនូវការរំលោភបំពាននោះនៅឡើយ និងករណីដែលមានការរំលោភហើយ ហើយការរំលោភនោះអាចបន្តរហូត ដល់អនាគតទៀត។ ព្រោះថា តើទទួលស្គាល់នូវការទាមទារឱ្យបញ្ឈប់នូវការរំលោភបំពាននោះដោយផ្អែកទៅលើផលប្រយោជន៍ ដែលមិនទាន់បានទទួលស្គាល់ជាសិទ្ធិដែរ ឬទេ? ករណីនេះត្រូវបកស្រាយតាមភាពជាក់ស្តែង។ នៅក្នុងជំពូកស្តីពីអំពើអនីត្យានុកូលក៏មានបញ្ញត្តិទទួលស្គាល់នូវការបញ្ឈប់ដោយមានលក្ខខណ្ឌកំណត់ដែរ។[6]

**ខ. សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ**

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបញ្ញត្តិថា បើស្ថានភាពរំលោភសិទ្ធិបុគ្គលនៅតែបន្តបន្ទាប់ដោយសារសំណល់នៃលទ្ធផលដែលកើតពីសកម្មភាពរំលោភនោះ អ្នកដែលបានទទួលរងនូវការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់នោះអាចទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភនោះបាន លុះត្រាតែលទ្ធផលនោះអាចដកចេញបាន។[7]

ក្នុងករណីដែលស្ថានភាពរំលោភនៅតែមានជាបន្តបន្ទាប់ ដោយសារតែមានការទុកចោលនូវលទ្ធផលនៃសកម្មភាពរំលោភ (**ឧទាហរណ៍៖** សារព័ត៌មានមួយបានចុះផ្សាយព័ត៌មានមិនពិតដោយបានចុះផ្សាយបរិហារកេរ្តិ៍តាមបណ្តាញសង្គមជាសាធារណៈ) ច្បាប់ទទួលស្គាល់នូវសិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃការរំលោភដែលជាមូលហេតុនៃការបន្តការរំលោភ(**ឧទាហរណ៍៖** បុគ្គលដែលបានទទួលរងពីសារព័ត៌មាននោះ អាចទាមទារឱ្យលុបចោល ឬចុះអត្ថបទកែតម្រូវថ្មីទៅតាមស្ថានភាពជាក់ស្តែង)។ នៅក្នុងមាត្រា១២នេះផងដែរមានខ្លឹមសាររួមទាំងសិទ្ធិទាមទារឱ្យបញ្ឈប់ការរំលោភនាអនាគត ព្រមជាមួយនឹងសិទ្ធិទាមទារឱ្យធ្វើការចាត់ចែងដែលមានអានុភាពធ្វើបដិទាននូវការខូចខាតផងដែរ ដូចជាការចុះអត្ថបទកែតម្រូវ ឬអត្ថបទលុបចោលនូវអត្ថបទចាស់ជាដើម។ ផ្ទុយទៅវិញ សិទ្ធិទាមទារឱ្យធ្វើបដិទាននូវការខូចខាត ដូចជាការទាមទារឱ្យផ្សាយសុំអភ័យទោសវិញ ជាគោលការណ៍ត្រូវមានកំហុសជាមូលដ្ឋាននៃជំពូកអំពីអំពើអនីត្យានុកូល។[8]

---

[5] មាត្រា ១១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[6] មាត្រា ៧៥៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[7] មាត្រា ១២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[8] មាត្រា ៧៥៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

**គ. សិទ្ធិទាមទារសំណងការខូចខាត**

រាល់បញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា១១ (សិទ្ធិទាមទារឱ្យបញ្ឈប់) និងមាត្រា១២ (សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ)នៃមាត្រាទាំងពីរនេះ មិនរារាំងដល់ការទាមទារសំណងការខូចខាត ដោយអ្នកដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនិងលក្ខណៈបុគ្គលនោះ ដោយយោងទៅតាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូលបានឡើយ។[9]

**១.២.២. គោលការណ៍មិនរំលោភបំពានដាច់ខាតលើកម្មសិទ្ធិ**

កម្មសិទ្ធិ គឺជាអំណាចដែលបុគ្គលមានសិទ្ធិពេញលេញជាម្ចាស់លើទ្រព្យសម្បត្តិជាគោលការណ៍ គឺមិនអាចរំលោភបំពានបានទេ។ គោលគំនិតមួយចំនួនពាក់ព័ន្ធនឹងសិទ្ធិប្រត្យក្ស មានមូលដ្ឋានផ្អែកលើគោលការណ៍នេះ។

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងថា ជនណាក៏ដោយបើទោះបីជាបុគ្គលក្តី ឬសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។[10] ទន្ទឹមនិងនេះ ក្រមរដ្ឋប្បវេណីក៏បានចែងផងដែរថា កម្មសិទ្ធិ គឺជាសិទ្ធិដែលកម្មសិទ្ធិករ អាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីបាន។

គោលគំនិតនៃកម្មសិទ្ធិនៅក្នុងនីតិវិធីរដ្ឋប្បវេណី មានន័យថា អំណាចដាច់ខាត និងមិនអាចរំលោភបំពានបានទៅលើទ្រព្យសម្បត្តិ ចំពោះមូលហេតុជាប្រវត្តិសាស្ត្រ ក៏ប៉ុន្តែនៅសម័យបច្ចុប្បន្នកម្មសិទ្ធិមិនត្រូវបានចាត់ទុកថាមិនអាចរំលោភបំពានបានជាដាច់ខាតនោះទេ។

សម័យបច្ចុប្បន្ន កម្មសិទ្ធិមិនត្រូវបានចាត់ទុកថា មិនអាចរំលោភបំពានបានជាដាច់ខាតនោះទេ ក្រមរដ្ឋប្បវេណីបានចែងថា កម្មសិទ្ធិអាចត្រូវបានអនុវត្ត នៅក្នុងទំហំដែលច្បាប់បានកំណត់។[11] ទន្ទឹមនឹងនេះក៏មានគោលការណ៍ចំនួនពីរ ខាងក្រោមនេះគឺត្រូវបានទាញចេញពី គោលការណ៍ដែលមិនអាចរំលោភបំពានបានជាដាច់ខាតនៃកម្មសិទ្ធិ៖

- គោលការណ៍សេរីភាពក្នុងការអនុវត្តសិទ្ធិ
- គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់។[12]

**ឧទាហរណ៍៖** រដ្ឋធម្មនុញ្ញបានបញ្ញត្តិថា ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែដើម្បីផលប្រយោជន៍សាធារណៈ ដូចដែលមានបញ្ញត្តិនៅក្នុងច្បាប់ និងទទួលបានសំណងដោយសមរម្យជាមុន។[13]

[9] មាត្រា ១៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[10] មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[11] មាត្រា ១៣៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[12] មាត្រា ១៣១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[13] មាត្រា ៤៤ កថាខណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

### ១.២.៣. គោលការណ៍ស្វ័យភាពបុគ្គលឯកជន

ជាគោលការណ៍របស់រដ្ឋមួយតែងតែគោរពសិទ្ធិសេរីភាពរបស់បុគ្គល មិនត្រូវជ្រៀតជ្រែកចូលក្នុងទំនាក់ទំនងគតិយុត្តរបស់បុគ្គលឯកជននោះទេ។ នៅក្នុងគោលការណ៍នេះ បុគ្គលម្នាក់ៗមានសិទ្ធិសេរីភាពក្នុងការបង្កើតទំនាក់ទំនងគតិយុត្តតាមឆន្ទៈរបស់ខ្លួន។

យោងតាមក្រមរដ្ឋប្បវេណី បានចែងយ៉ាងច្បាស់អំពី គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ក្រមនេះគោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និងបញ្ញត្តិអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល។ [14]នីតិបុគ្គលសាធារណៈដែលនៅក្នុងទំនាក់ទំនងនៃការជួញដូរ ត្រូវចាត់ទុកថាជាបុគ្គលឯកជន។

ក្នុងសង្គមជាមួយសេដ្ឋកិច្ចទីផ្សារ បុគ្គលម្នាក់ៗជាផ្នែកនៃសង្គម ចូលរួមក្នុងសកម្មភាពដោះដូរទំនិញសេវា រវាងបុគ្គលម្នាក់ និងបុគ្គលផ្សេងទៀតតាមរយៈកិច្ចសន្យា។ បុគ្គលទាំងនោះចងដោយកិច្ចសន្យា គោរពកិច្ចសន្យា និងអនុវត្តកាតព្វកិច្ចដោយសុចរិត។ វាជាលក្ខណៈធម្មតាសម្រាប់មនុស្សរស់នៅក្នុងប្រទេស ដែលឋិតក្រោមការគ្រប់គ្រងដោយច្បាប់ត្រូវគោរពច្បាប់។

ក្នុងសេដ្ឋកិច្ចទីផ្សាររួមទាំងការដោះដូរ និងការផ្តល់សេវា ជាគោលការណ៍ច្បាប់គោរពឆន្ទៈរបស់ប្រជាជនហើយ អនុញ្ញាតឱ្យពួកគាត់ បង្កើតវិធានផ្ទាល់ខ្លួន ដោយផ្អែកទៅលើឆន្ទៈសេរីរបស់ខ្លួន។ បុគ្គលឯកជនអាចធ្វើការសម្រេចចិត្តទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ចដោយផ្អែកលើឆន្ទៈរបស់ខ្លួន ដូចជាផលិតអ្វី ឬលក់អ្វី។ នៅក្នុងន័យនេះ បុគ្គលម្នាក់ៗ ត្រូវបានចងដោយឆន្ទៈរបស់ខ្លួនតែប៉ុណ្ណោះ។ គឺមានន័យថា សង្គមមានលក្ខណៈទីផ្សារត្រូវបានគ្រប់គ្រង ដោយគោលការណ៍ស្វ័យភាពបុគ្គលឯកជន។

**ឧទាហរណ៍៖** បុគ្គលឯកជន និងបុគ្គលឯកជន អាចបង្កើតកិច្ចសន្យាដោយគ្មានការជ្រៀតជ្រែកពីរដ្ឋ តុលាការ ឬរដ្ឋាភិបាលនោះទេ នេះជាស្វ័យភាពនៃបុគ្គលឯកជន។

គោលការណ៍នេះគឺមានទិដ្ឋភាពចំនួន២ គឺ៖

- គ្រប់រូបវន្តបុគ្គល មានសិទ្ធិទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចដោយឆន្ទៈសេរីរបស់ខ្លួន
- គ្មានបុគ្គលណាម្នាក់ ត្រូវបង្ខំឱ្យទទួលសិទ្ធិ និងកាតព្វកិច្ចដោយមិនបានបំពេញឆន្ទៈដោយសេរីរបស់ខ្លួនឡើយ។

គោលការណ៍នេះ ត្រូវបានយកមកអនុវត្ត មិនត្រឹមតែក្នុងរដ្ឋប្បវេណីនោះទេ គឺថែមទាំងច្បាប់ដែលជាប់ទាក់ទងនិងច្បាប់ឯកជន។ ចំណែកឯ ក្រមនីតិវិធីរដ្ឋប្បវេណី បានជ្រើសយក សិទ្ធិ របស់ភាគីក្នុងការចាត់ចែង[15]

---

[14] មាត្រា ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[15] មាត្រា ១៨២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

អំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៅក្នុងបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានចាត់ចែងដោយសេរីតាមឆន្ទៈរបស់ភាគី ដោយផ្អែកលើលក្ខណៈរបស់វា។ ដូច្នេះ ការជួយសង្គ្រោះតាមរយៈនីតិវិធីបណ្តឹង គឺមានលក្ខណៈគ្រប់គ្រាន់ នៅក្នុងទំហំ និងពេលវេលាដែលត្រូវបានទាមទារដោយភាគី។

តាមរយៈគោលការណ៍នេះ គោលការណ៍ដទៃផ្សេងទៀតអាចត្រូវបានទាញចេញ ដូចជា៖

- សេរីភាពក្នុងការធ្វើកិច្ចសន្យា (**ឧទាហរណ៍៖** បុគ្គលឯកជន អាចបង្កើតកិច្ចសន្យាដែលមិនមានចែងនៅក្នុងច្បាប់។
- គោលការណ៍ទទួលខុសត្រូវដែលកើតឡើងមកពីកំហុសរបស់ខ្លួន មានន័យថា ប្រសិនបើ បុគ្គលណាម្នាក់បង្កការខូចខាតដោយមិនមានកំហុស (ឬ ចេតនា) វាមិនមានភាពចាំបាច់នៅក្នុងការសងសំណងនៃការខូចខាតទេ។

### ១.២.៤. គោលការណ៍សុចរិត និងភាពស្មោះត្រង់

ជាគោលការណ៍ចម្បងមួយដែលមានចែងក្នុងក្រមរដ្ឋប្បវេណី បានចែងថា ការប្រើសិទ្ធិ និងការអនុវត្តករណីកិច្ច ត្រូវធ្វើឡើងដោយសុចរិតផ្អែកតាមភាពស្មោះត្រង់។ [16] គោលការណ៍នេះ ត្រូវបានបញ្ញត្តិឡើង ដើម្បីរក្សាស្ថេរភាពជំនួញ នៅក្នុងសង្គមឱ្យមានភាពរលូន និងទុកចិត្តគ្នាទៅវិញទៅមក។ នៅពេលធ្វើសកម្មភាពអ្វីមួយ ដូចជាការបង្កើតកិច្ចសន្យាទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ច និងកើតមានឡើង ដូចនេះបុគ្គលម្នាក់ៗត្រូវធ្វើសកម្មភាពក្នុងការប្រើប្រាស់សិទ្ធិ និងអនុវត្តកាតព្វកិច្ចដោយសុចរិត និងស្មោះត្រង់ធ្វើយ៉ាងណា ដើម្បីបង្កើនទំនុកចិត្តដល់ភាគីដែលពាក់ព័ន្ធ ដើម្បីកុំឱ្យមានការក្បត់គ្នា។

គោលការណ៍នេះ ត្រូវបានគេយកមកអនុវត្តតែនៅក្នុងទំនាក់ទំនងរវាងសិទ្ធិលើបំណុល និងកាតព្វកិច្ចដែលមាននៅក្នុងប្រវត្តិសាស្ត្រ។ ប៉ុន្តែ វាត្រូវបានគេយកទៅអនុវត្តយ៉ាងទូលាយចំពោះទំនាក់ទំនងដែលជិតស្និតនៅក្នុងសង្គមដូចជាទំនាក់ទំនងសិទ្ធិប្រត្យក្ស និងទំនាក់ទំនងឋានៈបុគ្គលផងដែរ។

## ១.៣. ការហាមប្រើប្រាស់សិទ្ធិដោយបំពាន

### ១.៣.១. គោលបំណង

ជាគោលការណ៍សេរីភាពនៃការអនុវត្តសិទ្ធិ ត្រូវបានទាញចេញពីគោលការណ៍ដែលមិនអាចរំលោភបំពានដាច់ខាតនៃកម្មសិទ្ធិ។ ក៏ប៉ុន្តែក្រមរដ្ឋប្បវេណី បញ្ញត្តិអំពី សិទ្ធិ ទោះបីជាមានសិទ្ធិក៏ដោយ ក៏ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយបំពានឡើយ។ [17]

[16] មាត្រា ៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[17] មាត្រា ៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ការអនុវត្តសិទ្ធិ ប៉ះពាល់ដល់ផលប្រយោជន៍របស់បុគ្គលផ្សេងដោយមិនសមហេតុផល អាចត្រូវបានចាត់ទុកថា គឺជាការបំពាន។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានចែងថាការប្រើសិទ្ធិដោយបំពានមិនត្រូវបានអនុញ្ញាតទេ ហើយប្រសិនបើសិទ្ធិត្រូវបានប្រើប្រាស់ដោយបំពានលើសពីទំហំ នៃការការពារ ដែលត្រូវបានបញ្ញត្តិទុកនោះ ការអនុវត្តសិទ្ធិមិនត្រូវបានគេទទួលស្គាល់អានុភាពឡើយ។

**ឧទាហរណ៍៖ ខ** ដែលរស់នៅដីក្រោម បានសាងសង់បំពង់បង្ហូរទឹកដោយចេញសោហ៊ុយផ្ទាល់ខ្លួនដើម្បីបង្ហូរទឹកក្តៅដែលផុសចេញពីដីមកកាន់ដីរបស់ខ្លួន ពីកន្លែងទឹកផុសចេញពីដីនៅផ្នែកលើ ដោយមានការយល់ព្រមពីម្ចាស់ដីនោះ។ គាត់សាងសង់កន្លែងងូតទឹក ដើម្បីបានចែករំលែកទឹកក្តៅនោះជាមួយអ្នកជិតខាងរបស់គាត់។ បំពង់បង្ហូរទឹកនោះមានប្រវែងប្រហែលជា ៨០០ម៉ែត្រ និងទទឹង២ម៉ែត្រ ហើយដែលហូរកាត់ដីមួយផ្នែករបស់ **គ** ស្ទើរតែទាំងអស់នៃដីរបស់ **គ** គឺសុទ្ធតែជាដីដែលប្រើប្រាស់មិនកើត។

**ក** បានដឹងអំពីបំពង់បង្ហូរទឹកនេះ ហើយក៏បានទិញដីពី **គ** ។ ហើយបន្ទាប់មក **ក** បានតំរូវឱ្យ **ខ** ទិញដីនោះក្នុងតម្លៃ ១០ដង ថ្លៃជាងតម្លៃទីផ្សារ។ នៅពេលដែលសំណើររបស់ **ក** ត្រូវបានគេច្រានចោល **ក** បានដាក់ពាក្យបណ្តឹងចំពោះ **ខ** ទាមទារឱ្យដកចេញបំពង់បង្ហូរទឹកនោះចេញ ដោយផ្អែកលើសិទ្ធិទាមទារឱ្យបញ្ឈប់នូវការរារាំងដោយផ្អែកលើកម្មសិទ្ធិ។

យោងតាមក្រមរដ្ឋប្បវេណី ការទាមទាររបស់ **ក** គឺស្របច្បាប់ដោយផ្អែកលើកម្មសិទ្ធិ។ [18]ប៉ុន្តែនៅក្នុងករណីស្រដៀងគ្នានេះ តុលាការកំពូលនៅប្រទេសជប៉ុនបានច្រានចោលនូវការទាមទាររបស់ **ក** ដោយសារតែការប្រើសិទ្ធិដោយបំពាន។ ដោយសារតែ **ក** មានឆន្ទៈលក់ដីនោះនៅក្នុងតម្លៃដែលខ្ពស់ជាងទីផ្សារទោះជា តាមពិតទៅមានតែប្រវែង ២ម៉ែត្រ នៃបំពង់បង្ហូរទឹកនោះហូរកាត់ដីរបស់ **ក** ហើយស្ទើរតែទាំងអស់នៃដីរបស់ **ក** គឺជាដីដែលប្រើប្រាស់មិនកើត។ ទន្ទឹមនឹងនេះ បំពង់បង្ហូរទឹកនោះ មានសារៈសំខាន់ណាស់មិនត្រឹមតែចំពោះ **ខ** គឺថែមទាំងអ្នកជិតខាងរបស់គាត់ផងដែរ។

### ១.៣.២. អានុភាពនៃការប្រើប្រាស់សិទ្ធិដោយបំពាន

- **ការអនុវត្តសិទ្ធិចាត់ទុកថា គ្មានអានុភាព**

ការប្រើប្រាស់សិទ្ធិ នៅក្នុងករណីដែលបានប្រើប្រាស់សិទ្ធិ ដោយបំពានហួសពីទំហំនៃការការពារ ដែលត្រូវបានកំណត់បញ្ញត្តិទុក មិនអាចទទួលស្គាល់អានុភាពនៃការប្រើសិទ្ធិនោះឡើយ។ [19]

**ឧទាហរណ៍៖** ការបដិសេធក្នុងការអនុវត្តសិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង ដែលផ្អែកលើកម្មសិទ្ធិនៅក្នុងករណីទឹកក្តៅផុសចេញពីដីខាងលើ ជាដើម។

[18] មាត្រា ១៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[19] មាត្រា ៤ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

– **នៅក្នុងករណីខ្លះ មានការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលកើតឡើង**

**ឧទាហរណ៍៖** ជនបានសាងសង់អគារបណ្តាលឱ្យបាំងផ្ទះអ្នកជិតខាង ធ្វើឱ្យកង្វះពន្លឺថ្ងៃ និងខ្យល់បក់ចូលក្នុងផ្ទះអ្នកជិតខាង។ នៅក្នុងករណីនេះ អ្នកជិតខាងនោះអាចទាមទារសំណងនៃការខូចខាតដែលកើតចេញពីអំពើអនីត្យានុកូលបាន។

– **ករណីលើកលែង សិទ្ធិត្រូវបានដកហូតដោយច្បាប់**

ក្រមរដ្ឋប្បវេណីបានចែងអំពី ការប្រកាស ការព្យួរ ឬការដកហូតអំណាចមេបា ថា បើឪពុក ឬម្តាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬបើបានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការអាចប្រកាសព្យួរ ឬការដកហូតអំណាចមេបាតាមការទាមទាររបស់ញាតិក្នុង ៤(បួន) ថ្នាក់របស់កូន មេឃុំ ឬចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬតំណាងអយ្យការបាន។[20]

[20] មាត្រា ១០៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

# ជំពូកទី២

# ការចាប់ផ្ដើម និងបញ្ចប់នៃសមត្ថភាពទទួលសិទ្ធិនៃរូបវន្តបុគ្គល

# ជំពូកទី២

# ការចាប់ផ្តើម និងបញ្ចប់នៃសមត្ថភាពទទួលសិទ្ធិនៃរូបវន្តបុគ្គល

ក្រមរដ្ឋប្បវេណីបានបញ្ញត្តិយ៉ាងច្បាស់អំពីពេលចាប់ផ្តើម និងពេលបញ្ចប់សមត្ថភាពទទួលសិទ្ធិ បានកំណត់ពីរូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព។

## ២.១. ការចាប់ផ្តើមសមត្ថភាពទទួលសិទ្ធិនៃរូបវន្តបុគ្គល

បុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិនៅពេលដែលចាប់កំណើត។ [21] ពេលចាប់ផ្តើមនៃកំណើតពុំមានកំណត់ច្បាស់លាស់នៅក្នុងក្រមនោះទេ ប៉ុន្តែក្រមរដ្ឋប្បវេណីបានលើកឡើងអំពីសិទ្ធិមួយចំនួនរបស់ទារកពេលនៅក្នុងគភ៌ដូចជា អំពើអនីត្យានុកូល សន្តតិកម្ម និងអច្ច័យទាន។ នៅក្នុងការកំណត់សិទ្ធិនេះឱ្យតែទារកនោះមានកំណើតនៅពេលក្រោយគឺសិទ្ធិទារកត្រូវបានការពារជានិច្ច។[22]

### ២.១.១. អត្ថន័យ និងអត្តសញ្ញាណនៃរូបវន្តបុគ្គល

#### ក. អត្ថន័យនៃរូបវន្តបុគ្គល

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្បាស់អំពីរូបវន្តបុគ្គលថាបុគ្គលគ្រប់រូប មានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។ [23] ជាគោលការណ៍ គ្រប់រូបវន្តបុគ្គលទាំងអស់ មិនថាជាជនជាតិខ្មែរ ឬជនជាតិបរទេស អាចទទួលបាននូវសិទ្ធិដូចគ្នា។ ប៉ុន្តែចំពោះជនបរទេស ដែលរស់នៅលើទឹកដីខ្មែរ ត្រូវបានក្រមរដ្ឋប្បវេណីកម្រិតនៅសិទ្ធិមួយចំនួន គឺជនជាតិបរទេសមិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។[24] ម្យ៉ាងវិញទៀត បើមិនមានសមត្ថភាពទទួលសិទ្ធិទេ ក៏មិនអាចទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចដែរ។ សមត្ថភាពទទួលសិទ្ធិត្រូវបានទទួលស្គាល់តែចំពោះបុគ្គលប៉ុណ្ណោះ។ ផ្ទុយទៅវិញ សត្វចិញ្ចឹម មិនមានសមត្ថភាពទទួលសិទ្ធិនោះទេ ហេតុនេះហើយមិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិតាមរយៈកិច្ចសន្យា និងមិនអាចទទួលកាតព្វកិច្ចតាមរយៈអំពើអនីត្យានុកូលនោះទេ។ [25]

[21] មាត្រា ៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[22] សេចក្តីពន្យល់នៃក្រមរដ្ឋប្បវេណី ភាគទី១ ផ្នែកទី៣ ទំព័រ១៣ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣

[23] មាត្រា ៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[24] មាត្រា ៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[25] ដកស្រង់ចេញពីគម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជា សមិទ្ធិផលរបស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គន្លឹះទី២ ទំព័រ៥

ការកម្រិតសិទ្ធិនេះ ក៏មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផងដែរ បានបញ្ញត្តិថា ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូហភាពក្តីមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ [26]

**ខ. អត្តសញ្ញាណនៃរូបវន្តបុគ្គល**

– **អត្រានុកូលដ្ឋាន**

អត្រានុកូលដ្ឋានគឺជាចំណងរួមភ្ជាប់ជាមួយសញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូល និងគ្រួសាររបស់ខ្លួននៅក្នុងសង្គមជាតិ និងបានបង្កើតទៅឱ្យជននោះមានសិទ្ធិនិងករណីយកិច្ចមានន័យថា សំដៅដល់ស្ថានភាពគតិយុត្តរបស់មនុស្សនោះ ឬអាចជាភាពស៊ីវិលនៃបុគ្គលម្នាក់ៗដែលជាឋានៈដែលជាទីកើតនៃសិទ្ធិនានានិងករណីយកិច្ចទាំងឡាយរបស់បុគ្គលនោះផង។ ដូចជាមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ គឺជាអ្នកដែលកាន់កាប់បញ្ជីអ្នកកើត ស្លាប់ និងអាពាហ៍ពិពាហ៍នៃពលរដ្ឋនៅក្នុងឃុំ/សង្កាត់។ ដូចនេះសំបុត្រអត្រានុកូលដ្ឋាន ជាសំបុត្រសម្រាប់កត់ត្រា និងសម្គាល់នូវអត្រានុកូលដ្ឋានរបស់បុគ្គលម្នាក់ៗ ហើយសំបុត្រអត្រានុកូលដ្ឋាននេះ ជាលិខិតដែលធ្វើឡើងដោយមន្ត្រីអត្រានុកូលដ្ឋាន គឺមានចៅសង្កាត់ ឬមេឃុំជាដើម នៅតាមមូលដ្ឋាននីមួយៗ។

បន្ទាប់មកយើងនិងសិក្សាបន្ថែមអំពីប្រភេទនៃសំបុត្រអត្រានុកូលដ្ឋាន ថា តើសំបុត្រអត្រានុកូលដ្ឋានបែងចែកជាប៉ុន្មានប្រភេទ?

សំបុត្រអត្រានុកូលដ្ឋានត្រូវបានបែងចែករួមមាន សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។ [27]

**២.១.២. គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ**

ជាគោលការណ៍ក្រមរដ្ឋប្បវេណីបានបែងចែកបុគ្គលជាពីរប្រភេទគឺ រូបវន្តបុគ្គល និងនីតិបុគ្គល។ រូបវន្តបុគ្គលគឺជាមនុស្ស ហើយនីតិបុគ្គលគឺជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច និងកាតព្វកិច្ចពិសេសដែលទទួលស្គាល់ដោយច្បាប់។ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា រូបវន្តបុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច [28] ។ មានន័យថា ក្រមរដ្ឋប្បវេណីបានទទួលស្គាល់ថា រូបវន្តបុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិ។

[26] មាត្រា ៤៤ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ព្រះរាជាណាចក្រកម្ពុជា

[27] មាត្រា ២ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក

[28] មាត្រា ៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

បញ្ញត្តិនេះចែងអំពីអត្ថន័យនៃសមត្ថភាពទទួលសិទ្ធិ ព្រមទាំងការប្រកាសអំពីគោលការណ៍នៃសមត្ថភាពទទួលសិទ្ធិ មានន័យថា បញ្ញត្តិនេះបានចែងយ៉ាងច្បាស់លាស់ថា ក្នុងឋានៈជាមនុស្សមិនត្រូវមានការរើសអើងវណ្ណៈ ភេទ អាយុ មុខរបរ សាសនា ជាអាទិ៍ឡើយ ហើយមនុស្សគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។

### ២.១.៣. ពេលចាប់ផ្តើមនៃសមត្ថភាពទទួលសិទ្ធិ

តើគ្រប់រូបវន្តបុគ្គលម្នាក់ៗមានសមត្ថភាពទទួលបាននូវសិទ្ធិចាប់តាំងពីពេលណាមក? បើយោងតាមបញ្ញត្តិច្បាប់កម្ពុជា ក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពី ពេលចាប់ផ្តើម និងពេលបញ្ចប់សមត្ថភាពទទួលសិទ្ធិថា រូបវន្តបុគ្គលម្នាក់ៗមានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត។ [29] នៅក្នុងនិយមន័យក្រមរដ្ឋប្បវេណីមិនបានបញ្ញត្តិលម្អិតទេ ត្រូវបានបើកចំហឱ្យធ្វើការបកស្រាយតាមការអនុវត្តនៅកម្ពុជា។ បើយោងទៅតាមក្រមរដ្ឋប្បវេណីប្រទេសជប៉ុន បានបញ្ញត្តិអំពីកំណើត គឺជាពេលដែលខ្លួនទារកទាំងមូលបានចេញផុតពីគភ៌ម្តាយ ហើយចាប់ផ្តើមដកដង្ហើមនឹងមានជីវិត។ ប៉ុន្តែទ្រឹស្តីនៃការកើតផុតខ្លួនទាំងមូល គឺគេទទួលស្គាល់ច្រើននៅប្រទេសកម្ពុជា យើងអាចបកស្រាយដោយយោងតាមវចនានុក្រម **សម្តេចសង្ឃរាជ ជួន ណាត** ពាក្យថាចាប់កំណើត មានន័យថា កើតចេញពីផ្ទៃម្តាយ ឬចាប់ពីពេលវេលាដែលកើត។ [30]

#### ក. គោលការណ៍ទូទៅ

ប្រសិនបើនៅពេលទារកមិនទាន់ចាប់កំណើតទារកមិនមានសមត្ថភាពទទួលបាននូវសិទ្ធិឡើយ។ ក៏ប៉ុន្តែវាហាក់ដូចជាអយុត្តិធម៌ ប្រសិនបើទារកនៅក្នុងគភ៌មិនអាចក្លាយជាប្រធាននៃសិទ្ធិថ្វីបើទារកនៅក្នុងគភ៌នោះ ត្រូវបានគេរំពឹងថានឹងចាប់កំណើតនៅពេលខាងមុខដ៏ខ្លី។

កំណើត គឺជាលក្ខខណ្ឌបង្កើតឱ្យមានបុគ្គលភាព។ នៅពេលកើតគ្រប់ក្មេងទាំងអស់ជារូបវន្តបុគ្គល កូនទើបនឹងកើតអាចនិយាយថាជារូបវន្តបុគ្គលទទួលបាននូវសិទ្ធិទាល់តែមានលក្ខខណ្ឌពីរ៖[31]

- ក្មេងកើតមករស់
- ក្មេងនោះនឹងអាចរស់បាន

ទារកដែលកើតមកហើយ ឪពុក ឬម្តាយរបស់ទារកនោះត្រូវប្តឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ/សង្កាត់ដែលជាលំនៅអចិន្ត្រៃយ៍របស់ខ្លួន ក្នុងរយៈពេល៣០ថ្ងៃ។ ក្នុងករណីឪពុក ឬម្តាយមិនអាចសុំចុះបានទេ ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្តាយនៃកូនអាចសុំចុះសំបុត្រកំណើតរបស់កូននោះបាន។ ការចុះបញ្ជី

[29] មាត្រា ៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[30] វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត

[31] មាត្រា ៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

អត្រានុកូលដ្ឋានហួសរយៈពេលកំណត់ខាងលើនេះដោយគ្មានមូលហេតុត្រឹមត្រូវ និងត្រូវបានពិន័យជាប្រាក់មិនលើសពី**១០០០០រៀល**។[32] មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះក្នុងសៀវភៅកំណើតនូវនាមត្រកូល នាមខ្លួន ថ្ងៃ-កំណើត និងភេទរបស់កូននោះ និងចុះនាមត្រកូល នាមខ្លួន លំនៅរបស់ឪពុកម្ដាយ។ ការបញ្ជាក់អំពីឈ្មោះឪពុកម្ដាយ វាជាការបង្កើតឱ្យមានផលវិបាកសំខាន់ទាក់ទងនឹងបុគ្គលភាព។ ចាប់ពីថ្ងៃកើតមក បុគ្គលម្នាក់ៗមានទំនាក់ទំនងទៅនឹងបញ្ញាគតិយុត្តដែលជាខ្លឹមសារសំខាន់ចំនួន៤ដូចជា៖

- ភាពកកើតនៃកំណើត និងការស្លាប់របស់គេ
- អត្តសញ្ញាណរបស់គេ
- សិទ្ធិដែលគេត្រូវបាន
- សមត្ថភាពរបស់គេ

**ខ. ករណីលើកលែង**

ជាគោលការណ៍ ទារកនៅមុនពេលចាប់កំណើតមិនមានសមត្ថភាពទទួលសិទ្ធិនោះទេ។ ប៉ុន្តែ ទារកដែលនៅក្នុងគភ៌ ហើយបែរជាមិនទទួលស្គាល់សិទ្ធិទាល់តែសោះ ដូចជាសន្តតិកម្មជាដើមនោះ គឺមិនស្មើភាពនោះទេ។ ហេតុនេះហើយ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិនូវករណីលើកលែងដោយទទួលស្គាល់សមត្ថភាពទទួលសិទ្ធិរបស់ទារកក្នុងគភ៌ ដែលទាក់ទងទៅនឹងការទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល សិទ្ធិទទួលបានសន្តតិកម្ម និងអច្ច័យទាន។[33]

**១. ទារកនៅក្នុងគភ៌ និងអំពើអនីត្យានុកូល**

តាមធម្មជាតិ ទារកនៅក្នុងគភ៌នឹងមានកំណើតនៅពេលខាងមុខដ៏ខ្លី ហេតុនេះនៅពេលដែលទារករងនូវផលប៉ះពាល់អំពីអំពើអនីត្យានុកូល បើទារកនេះមានកំណើតនៅពេលក្រោយ អាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួននៅក្នុងគភ៌ដោយអំពើអនីត្យានុកូលនោះបាន។[34] ទាក់ទងនឹងការទាមទារសំណងការខូចខាតដែលកើតឡើងដោយអំពើអនីត្យានុកូល ទារកក្នុងគភ៌ ត្រូវបានទទួលស្គាល់ថាមានសមត្ថភាពទទួលសិទ្ធិ។

ហើយក្រោយពីចាប់កំណើត ទារក អាចទាមទារឱ្យអ្នកបង្កគ្រោះថ្នាក់ (ចារី) សងសំណងការខូចខាតដោយផ្អែកលើអំពើ អនីត្យានុកូលតាមរយៈម្ដាយក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់បាន។ គួរកត់

[32] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៨៥, អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, លេខ១០៣អនក្រ/បក. ២៩ ធ្នូ ២០០០, មាត្រា១៧

[33] មាត្រា ៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[34] មាត្រា ៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

សម្គាល់ថាមុនពេលចាប់កំណើត ម្ដាយ មិនអាចទាមទារសំណងនៃការខូចខាតក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់របស់ទារកទេ ព្រោះទារកនៅក្នុងគភ៌ មិនអាចអនុវត្តសិទ្ធិរបស់ខ្លួនរហូតដល់ពេលដែលខ្លួនចាប់កំណើត។

**ឧទាហរណ៍៖** លោក **ក** មានប្រពន្ធឈ្មោះ **ខ** ព្រមទាំងកំពុងមានទារកនៅក្នុងគភ៌ ថ្ងៃបានជួបគ្រោះថ្នាក់ចរាចរណ៍ធ្វើឱ្យប្ដីស្លាប់ និងប្រពន្ធរងរបួសធ្ងន់ ដោយដឹងថានឹងសម្រាលកូននៅពេលក្រោយ។ នៅក្នុងករណីនេះ ប្រសិនបើទារកស្លាប់នៅពេលក្រោយសម្រាលម្ដាយជាដើម មិនអាចធ្វើសន្តតិកម្មសិទ្ធិទាមទារសំណងការខូចខាតបានទេ ហើយនៅមុនពេលទារកចាប់កំណើត ម្ដាយមិនអាចធ្វើជាអ្នកតំណាងឱ្យទារកក្នុងផ្ទៃដើម្បីធ្វើការទាមទារសំណងការខូចខាតនោះដែរ។

### ២. ទារកនៅក្នុងគភ៌ និងសន្តតិកម្ម

កូនរបស់មត៌កជន គឺជាសន្តតិជនជានិច្ច ហើយសន្តតិជនគ្រប់រូបទទួលបាននូវចំណែកមរតកស្មើៗគ្នា។[35]ជាគោលការណ៍ ទារកនៅក្នុងគភ៌នៅមុនពេលចាប់កំណើត គឺមិនទាន់ត្រូវបានចាត់ទុកជាកូននៅឡើយទេ។ ក៏ប៉ុន្តែប្រសិនបើបំបិទសិទ្ធិទារកនៅក្នុងគភ៌មិនឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ទារកដែលនឹងត្រូវចាប់កំណើតនៅពេលដ៏ខ្លីខាងមុខ។

ក្រមរដ្ឋប្បវេណី ក៏បានទទួលស្គាល់ជាករណីលើកលែងចំពោះទារកក្នុងគភ៌នូវសមត្ថភាពទទួលសិទ្ធិដែលទាក់ទងនឹងសន្តតិកម្ម ដោយបញ្ញត្តិថា ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្ដើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលមត៌កដោយសន្តតិកម្មនោះបាន។[36] មានន័យថា ករណីដែលឪពុកបានទទួលមរណភាពនៅពេលដែលម្ដាយកំពុងតែមានគភ៌ កូនដែលនៅក្នុងគភ៌នោះនៅពេលកើត អាចទទួលសន្តតិកម្មនូវទ្រព្យសម្បត្តិរបស់ឪពុកបាន។ ករណីទារកស្លាប់នៅពេលក្រោយសម្រាល គឺមិនអាចធ្វើសន្តតិកម្មពីទ្រព្យសម្បត្តិរបស់ឪពុកបានទេ ហើយនៅពេលម្ដាយកំពុងមានគភ៌ ម្ដាយមិនអាចតំណាងឱ្យទារកក្នុងគភ៌ទាមទារឱ្យចែកមត៌កបានទេ។

### ៣. ទារកនៅក្នុងគភ៌ និងអច្ច័យទាន

ករណីអច្ច័យទាន ទារកនៅក្នុងគភ៌ក៏ត្រូវបានទទួលស្គាល់នូវសមត្ថភាពទទួលបានសិទ្ធិតាមរយៈមត៌កសាសន៍។ [37] នេះមានន័យថា ឪពុកអាចធ្វើអច្ច័យទានទៅឱ្យទារកមុនពេលមានកំណើតក្នុងនាមជាអច្ច័យលាភី

[35] មាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[36] មាត្រា ៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[37] មាត្រា ៩ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

បានហើយបើទារកនោះ ចាប់កំណើតនៅពេលក្រោយទារកនោះអាចធ្វើលទ្ធកម្មទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃអច្ច័យទានបាន។

## ២.២. ការបញ្ចប់នៃសមត្ថភាពទទួលសិទ្ធិនៃរូបវន្តបុគ្គល

### ២.២.១. ការទទួលមរណភាព

បុគ្គលភាពគតិយុត្តបញ្ចប់នៅពេលមនុស្សស្លាប់។ មរណភាពត្រូវមានការបញ្ជាក់ដោយគ្រូពេទ្យ ទើបមានលក្ខណៈត្រឹមត្រូវ ឬគេអាចសន្មតថាស្លាប់ គឺនៅពេលបេះដូងលែងធ្វើចលនា ទន្ទឹមគ្នាជាមួយការឈប់ដកដង្ហើមជារហូត ហើយបើឱ្យច្បាស់លាស់ គឺភាពឡើងរឹងនៃសាកសព។ [38]

#### ក. សំបុត្រមរណភាព

ជនដែលពាក់ព័ន្ធនិងអ្នកស្លាប់ ត្រូវប្តឹងទៅមន្ត្រីអត្រានុកូលដ្ឋានយ៉ាងយូរ១៥ថ្ងៃ ក្រោយទទួលមរណភាព។[39] មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះអត្តសញ្ញាណជនដែលស្លាប់ក្នុងបញ្ជីមរណភាព។ មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញលិខិតអនុញ្ញាតឱ្យយកសពនោះទៅបញ្ចុះ ឬបូជា។

ការស្លាប់គេសន្មតថាមានសាកសពមួយ ព្រោះសាកសពជាភស្តុតាងបង្ហាញថាមានការស្លាប់។ បើគ្មានសាកសពទេ ចាំបាច់ត្រូវមានសាលក្រមប្រកាសពីការបាត់ខ្លួន ព្រោះសាលក្រមនេះមានអានុភាពអាចចាត់ទុកថា ជនដែលបាត់ខ្លួនស្លាប់បាត់ទៅហើយ។

ក្នុងករណីដែលសហព័ទ្ធណាមួយបាត់ខ្លួនកន្លងហួសពី១ឆ្នាំ គិតពីថ្ងៃដែលបាត់ខ្លួននោះមក ដោយគ្មានដំណឹងអ្វីសោះ ហើយក៏គ្មាននរណាដឹងថាជននោះស្លាប់ ឬរស់ សហព័ទ្ធម្នាក់ទៀតអាចនឹងរៀបការទៀតបាន បើផុតរយៈពេល១៥ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមដែលបញ្ជាក់ថា ជននោះបានបាត់ខ្លួនពិតមែន។ ជនណាក៏ដោយមិនអាចប្តឹងសុំបដិសេធអាពាហ៍ពិពាហ៍ថ្មីនេះបានឡើយ ទោះបីសហព័ទ្ធដែលត្រូវបានសាលក្រមប្រកាសថាបាត់ខ្លួននោះ ត្រលប់មកវិញក៏ដោយ។

សំបុត្រមរណភាពត្រូវប្រាប់ពីត្រកូល ឈ្មោះ ភេទ មុខរបរ លំនៅដ្ឋាន ថ្ងៃ ខែ ឆ្នាំដែលស្លាប់ ថ្ងៃខែឆ្នាំ និងទីកន្លែងកើត ព្រមទាំងឈ្មោះឪពុកម្តាយនៃសព។

#### ខ. អត្ថិភាពនៃបុគ្គលភាពគតិយុត្តក្រោយពេលស្លាប់

ថ្វីត្បិតតែបុគ្គលភាពត្រូវបានបញ្ចប់នៅពេលទទួលមរណភាពក៏ដោយ ក៏ច្បាប់ទទួលស្គាល់ចំពោះសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកស្លាប់បិតនៅជាបន្ត មានដូចជា៖

[38] មាត្រា ៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[39] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន.លេខ១០៣អនក្រ/បក. ចុះថ្ងៃទី២៩ ធ្នូ ឆ្នាំ ២០០០

**បណ្តាំ៖** ជាឆន្ទៈរបស់បុគ្គលដែលបានសំដែងឡើងមុនពេលខ្លួនស្លាប់។ ឆន្ទៈរបស់សពនេះបង្កើតបាននូវអានុភាព ដោយច្បាប់ឱ្យតម្លៃគតិយុត្តដល់បណ្តាំនោះ។ ដូច្នេះការបែងចែកមត៌កត្រូវគោរពតាមបណ្តាំ ករណីគ្មានបណ្តាំមត៌កត្រូវបែងចែងតាមច្បាប់។

**ការគោរពសាកសព៖** ត្រូវបានច្បាប់ធានា។ ការបំពានលើរូបរាងកាយសាកសពត្រូវហាមឃាត់ តាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ អំពើប៉ះពាល់ដល់បូរណភាពនៃសាកសព ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយខែទៅមួយឆ្នាំ និងពិន័យជាប្រាក់ពី **១០០.០០០រៀល** ទៅ **២.០០០.០០០រៀល**។[40]

ប៉ុន្តែការប៉ះពាល់លើរូបរាងកាយសាកសព អាចធ្វើឡើងបានដើម្បីធ្វើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ឬដើម្បីបញ្ជាក់ពីមូលហេតុនៃការស្លាប់ ឬការដកហូតយកសេរីរាង្គរបស់សាកសពក្នុងគោលដៅព្យាបាល ឬសិក្សាវិទ្យាសាស្ត្រអាចធ្វើទៅបាន បើគ្មានការបដិសេធពីសាមីជន ឬពីគ្រួសារ។ ជួនកាលគោលការណ៍នេះក៏មិនអាចត្រូវបានអនុវត្តទាំងស្រុងទេ ព្រោះថាពេលខ្លះចៅក្រមអាចបង្គាប់ឱ្យធ្វើការវះសាកសពក៏មាន។

**ការការពារកេរ្តិ៍ឈ្មោះរបស់ជនដែលស្លាប់៖** គឺការពារប្រឆាំងនឹងការសរសេរជេរប្រមាថ ឬបរិហារកេរ្តិ៍ជាហេតុធ្វើឱ្យមានការខូចខាតខាងស្មារតីចំពោះគ្រួសាររបស់អ្នកស្លាប់។ ជនដែលជាគ្រួសារ ជាទាយាទមានសិទ្ធិប្តឹងទាមទារជួសជុលសំណងអន្តរាយ។

### ២.២.២. ការប្រកាសបាត់ខ្លួននៃរូបវន្តបុគ្គល

ការប្រកាសអំពីការបាត់ខ្លួននេះ គឺជាស្ថានភាពដែលគេចាត់ទុកថាបុគ្គលនោះបានទទួលមរណភាពទៅលើទំនាក់ទំនងគតិយុត្តជុំវិញលំនៅដ្ឋានជាដើម ដោយតាមនីតិវិធីដែលបានកំណត់នៅក្នុងករណីដែលពុំមានដំណឹងច្បាស់លាស់ថាបុគ្គលនោះនៅរស់ ឬស្លាប់អំឡុងពេលកំណត់។ ក្នុងករណីដែលពុំមានដំណឹងរយៈពេលយូរថាបុគ្គលនោះនៅរស់ ឬស្លាប់ហើយទ្រព្យសម្បត្តិដែលបានបន្សល់ទុកនោះទោះដល់ពេលណាក៏ដោយ ក៏មិនអាចធ្វើសន្តតិកម្មបានទេ។ ប៉ុន្តែចាំបាច់ត្រូវតែមានអ្នកគ្រប់គ្រងបន្តហើយសហព័ទ្ធក៏មិនអាចរៀបអាពាហ៍ពិពាហ៍ទៀតដែរ។

ដូច្នេះហើយក្រមរដ្ឋប្បវេណីបានបញ្ញត្តិនូវប្រព័ន្ធនៃការប្រកាសអំពីការបាត់ខ្លួននេះឡើង។ [41] ដើម្បីអាចធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិ និងសហព័ទ្ធម្ខាងទៀតអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។

ការប្រកាសអំពីការបាត់ខ្លួនមានពីរប្រភេទគឺ ការបាត់ខ្លួនធម្មតា និងការបាត់ខ្លួនពិសេស ហើយករណីទាំងពីរនេះក៏មានលក្ខខណ្ឌខុសគ្នាដែរ។

[40] មាត្រា ២៦១ នៃក្រមព្រហ្មទណ្ឌ លេខ នស/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[41] មាត្រា ៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

**ក. ការប្រកាសបាត់ខ្លួនធម្មតា**

ការប្រកាសអំពីការបាត់ខ្លួនធម្មតា គឺនៅពេលមិនមានដំណឹងច្បាស់លាស់រយៈពេល៥ឆ្នាំថា បុគ្គលដែលអវត្តមាននោះនៅរស់ ឬស្លាប់។ [42] តុលាការអាចប្រកាសអំពីការបាត់ខ្លួនតាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលសន្មត់ថាជាសន្តតិជន អច្ឆ័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយឬអ្នកផ្សេងទៀតដែលមានសារៈប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន។

**ខ. ការប្រកាសបាត់ខ្លួនពិសេស**

ការបាត់ខ្លួនពិសេស គឺអនុវត្តទៅលើករណីដែលមិនច្បាស់លាស់ថាបុគ្គលដែលជួបប្រទះនឹងគ្រោះថ្នាក់អាចនៅរស់ ឬស្លាប់។ បុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬបុគ្គលដែលជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងថាបុគ្គលនោះនៅរស់ ឬទទួលមរណភាពហើយ ក្នុងអំឡុងពេល១ឆ្នាំ ក្រោយពីបញ្ចប់សង្គ្រាមក្រោយពីនាវាលិច ឬក្រោយពីគ្រោះថ្នាក់នោះបានកន្លងផុតទៅ តុលាការអាចប្រកាសអំពីការបាត់ខ្លួនបានតាមពាក្យសុំរបស់អ្នកដែលមានទំនាក់ទំនងផលប្រយោជន៍ដូចខាងលើ។[43]

**២.២.៣. អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន**

នៅពេលប្រកាសអំពីការបាត់ខ្លួន ឬអ្នកដែលបានបាត់ខ្លួនត្រូវចាត់ទុកថាទទួលមរណភាពចំពោះទំនាក់ទំនងគតិយុត្តជុំវិញលំនៅដ្ឋាន ឬទីសំណាក់។[44] មានន័យថា សន្តតិកម្មអាចចាប់ផ្តើមបានហើយសហព័ទ្ធអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ប៉ុន្តែត្រូវចាត់ទុកថាមរណភាពចំពោះតែទំនាក់ទំនងគតិយុត្តនៅជុំវិញលំនៅដ្ឋានតែប៉ុណ្ណោះមិនមែនដកហូតសមត្ថភាពទទួលសិទ្ធិរបស់បុគ្គលនោះទេ។ ដូច្នេះហើយបើបុគ្គលនោះនៅរស់ ហើយរស់នៅកន្លែងមួយទៀត ហើយបុគ្គលនោះអាចធ្វើលទ្ធកម្មនូវសិទ្ធិ និងកាតព្វកិច្ចបាន។

**ឧទាហរណ៍៖** បុគ្គលនោះបានបង្កើតកិច្ចសន្យាក៏មានសុពលភាពដែរ។ ពេលដែលបង្កើតអានុភាពនៃការប្រកាសអំពីការបាត់ខ្លួនក្នុងករណីការបាត់ខ្លួនធម្មតាគឺអំឡុងពេល៥ឆ្នាំ ហើយករណីបាត់ខ្លួនពិសេស គឺពេលគ្រោះថ្នាក់នោះកន្លងផុតទៅ។

---

[42] មាត្រា ៤១ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[43] មាត្រា ៤១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[44] មាត្រា ៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

### ២.២.៤. អានុភាពការលុបចោលការប្រកាសបាត់ខ្លួន

ប្រសិនបើបុគ្គលដែលបានប្រកាសថា បានបាត់ខ្លួនហើយតែតាមពិតបុគ្គលដែលគេប្រកាសថាបាត់ខ្លួននៅមានជីវិត ហើយត្រឡប់មកលំនៅដ្ឋានដើមវិញ [45] តើបុគ្គលនោះអាចមានអានុភាពលុបចោលការប្រកាសបាត់ខ្លួនបានដែរ ឬទេ?

ក្នុងករណីដែលបានប្រកាសអំពីការបាត់ខ្លួនរួចហើយ តាមបញ្ញត្តិច្បាប់ត្រូវបានចាត់ទុកថាទទួលមរណភាពដូច្នេះហើយទោះបីជាសាមីខ្លួនបានត្រលប់មកវិញក៏ដោយ ក៏អានុភាពនៃការប្រកាសបាត់ខ្លួនមិនបាត់បង់ទេ។ ដើម្បីឱ្យការប្រកាសអំពីការបាត់ខ្លួនបាត់បង់អានុភាពនោះ ចាំបាច់ធ្វើការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ។ ប្រសិនបើមានការបញ្ជាក់ថាបុគ្គលដែលបានបាត់ខ្លួននៅរស់ ឬមានការបញ្ជាក់ថាបានទទួលមរណភាពនៅពេលខុសពីពេលដែលបានកំណត់ តុលាការត្រូវតែលុបចោលការប្រកាសអំពីការបាត់ខ្លួនតាមពាក្យសុំរបស់សាមីខ្លួន ឬបុគ្គលដែលមានផលប្រយោជន៍។[46]

នៅពេលដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល គេចាត់ទុកថាការប្រកាសអំពីការបាត់ខ្លួននោះមិនមានតាំងពីដំបូង។ ដូចនេះហើយទើបមានការព្រួយបារម្ភអំពីការបាត់បង់ផលប្រយោជន៍របស់បុគ្គលដែលបានធ្វើលទ្ធកម្មទ្រព្យសម្បត្តិ បុគ្គលដែលធ្វើពាណិជ្ជកម្មជាមួយបុគ្គលធ្វើលទ្ធកម្មនោះ និងសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ថ្មីក្រោយពីការប្រកាសអំពីការបាត់ខ្លួន ដោយសារការប្រកាសអំពីការបាត់ខ្លួន។ មូលហេតុនេះហើយទើបក្រមរដ្ឋប្បវេណីបង្កើតឡើងនូវបទបញ្ញត្តិដើម្បីគ្រប់គ្រង និងការខាតបង់នេះឡើង។ ដំបូងដែលទទួលបានទ្រព្យសម្បត្តិដោយចំពោះពីបុគ្គលដែលបាត់ខ្លួន។

### ២.២.៥. ការចាត់ទុកថាបានទទួលមរណភាពស្របពេលជាមួយគ្នា

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិយ៉ាងច្បាស់អំពីការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ក្រោយពេលបុគ្គលផ្សេងទៀតបានទទួលមរណភាពទេ បុគ្គលទាំងនោះត្រូវបានចាត់ទុកថាបានទទួលមរណភាពស្របពេលជាមួយគ្នា។[47]

ក្នុងករណីដែលបុគ្គលច្រើននាក់បានទទួលមរណភាព តែមិនដឹងថា បុគ្គលណាបានទទួលមរណភាពមុន ឬក្រោយនោះត្រូវចាត់ទុកថា បុគ្គលទាំងនោះបានទទួលមរណភាពព្រមគ្នា។

[45] មាត្រា ៤៤ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[46] មាត្រា ៤៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[47] មាត្រា ៤៥ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

**ឧទាហរណ៍៖** ក្នុងករណីដែលយន្តហោះធ្លាក់ ហើយឪពុក និងកូនដែលបានជិះយន្តហោះនោះបានទទួលមរណភាព ត្រូវចាត់ទុកថា ឪពុក និងកូននោះបានទទួលមរណភាពព្រមគ្នា។ ការបង្កើតបញ្ញត្តិរបៀបនេះ គឺដើម្បីដោះស្រាយឱ្យបានសមរម្យនូវបញ្ហាសន្តតិកម្ម។

សូមពិចារណាមើលករណីនៃគ្រួសារមួយដែលមានប្តីប្រពន្ធ និងកូនម្នាក់ កូននោះនៅក្មេងហើយមិនទាន់មានកូនទេ ថែមទាំងគ្មានទ្រព្យសម្បត្តិទៀត ឪពុកម្តាយខាងប្តីក៏នៅមានសុខភាពល្អ។ ក្នុងករណីដែលឪពុក និងកូនបានទទួលមរណភាព តើអ្នកណាទទួលមរណភាពមុន អ្នកណាទទួលមរណភាពក្រោយនោះ លទ្ធផលនៃសន្តតិកម្មខុសគ្នាខ្លាំង។ ប្រសិនបើប្តីបានទទួលមរណភាពមុន ប្រពន្ធនឹងទទួលទ្រព្យពាក់កណ្តាល ដោយសន្តតិកម្មហើយកូនក៏បានទទួលពាក់កណ្តាលដូចគ្នាដែរ។[48] បន្ទាប់មក កូនបានទទួលមរណភាព ហើយពេលនោះ ប្រពន្ធនឹងបានទទួលទ្រព្យពីកូនទាំងអស់ដោយសន្តតិកម្ម។[49] ផ្ទុយទៅវិញ ប្រសិនបើកូនបានទទួលមរណភាពមុនប្រពន្ធ និងឪពុកម្តាយរបស់ប្តីនឹងទទួលម្នាក់ ១ភាគ៣ ដោយសន្តតិកម្ម។[50] ក្នុងស្ថានភាពនេះ ការបង្កើតនូវហេតុការណ៍កាន់កាប់ទ្រព្យសម្បត្តិមុន ជាការមួយដែលអ្នកកាន់កាប់អាចចំណេញជាងគេ។ នេះគឺដោយសារតែបុគ្គលដែលចង់បដិសេធនូវហេតុការណ៍បានសម្រេចនោះ ត្រូវធ្វើការបញ្ជាក់ភស្តុតាងយ៉ាងសកម្មថា តើអ្នកណាបានទទួលមរណភាពមុន ក៏ប៉ុន្តែតាមធម្មតា មិនងាយធ្វើបានឡើយ។ យោងតាមបញ្ញត្តិនេះ ប្រសិនបើបានទទួលមរណភាពព្រមគ្នាទៅ បុគ្គលដែលបានទទួលមរណភាពព្រមគ្នានេះ មិនអាចធ្វើសន្តតិកម្មបានទេ ដូច្នេះហើយ កូនមិនអាចធ្វើសន្តតិកម្មទ្រព្យសម្បត្តិរបស់ឪពុកទេ ហើយប្រពន្ធ និងឪពុកម្តាយរបស់ប្តីនឹងបានទទួល ១ភាគ៣ក្នុងម្នាក់ៗ។

ក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងបានទទួលមរណភាពទេ។ មានន័យថាលក្ខខណ្ឌគឺសំដៅទៅលើស្ថានភាពមិនច្បាស់លាស់នៃទំនាក់ទំនងមុននិងក្រោយនៃការទទួលមរណភាព។

**ឧទាហរណ៍៖** ទោះបីជាទទួលមរណភាពដោយសារគ្រោះថ្នាក់ក្នុងពេលជាមួយគ្នាក៏ដោយប្រសិនបើអាចបញ្ជាក់អំពីទំនាក់ទំនងមុននិងក្រោយនៃការទទួលមរណភាព នោះសន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកទៅលើទំនាក់ទំនងនោះ។

ប្រសិនបើមិនច្បាស់លាស់អំពីទំនាក់ទំនងមុននិងក្រោយនៃការទទួលមរណភាពទេ យើងត្រូវយកមាត្រា៤៥ មកអនុវត្តចំពោះភាពមិនច្បាស់លាស់ថាបុគ្គលដែលបានបាត់ខ្លួនមានអវត្តមាននៅរស់ ឬទទួល

[48] មាត្រា ១១៦២ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[49] មាត្រា ១១៥៩ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[50] មាត្រា ១១៦២ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

មរណភាព។ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីអានុភាពនោះថា ចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា។ ប្រសិនបើយើងក្រឡេកមកមើលលើ សន្តតិកម្មវិញ គឺមានតែជនដែលមានជីវិតនៅ នាពេលចាប់ផ្ដើមសន្តតិកម្មប៉ុណ្ណោះ ទើបអាចទទួលសន្តតិកម្មបាន។[51] ដូច្នេះហើយ ជនដែលបានសន្មតថា បានទទួលមរណភាពព្រមពេលជាមួយគ្នា ដោយផ្អែកលើមាត្រា៤៥ មិនអាចក្លាយជាសន្តតិជនបានទេ។ នោះមានន័យថា នៅចន្លោះនៃបុគ្គលទាំងពីរដែលបានសន្មតថាបានទទួលមរណភាពព្រមពេលជាមួយគ្នា ដោយផ្អែកលើមាត្រា៤៥ មិនអាចបង្កើតឱ្យមានសន្តតិកម្មនោះទេ។

[51] មាត្រា ១១៤៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

# ជំពូកទី៣

# ជនដែលត្រូវបានគេរកឃើញថាអសមត្ថភាពក្នុងការបញ្ចេញឆន្ទៈ

# ជំពូកទី៣

# ជនដែលត្រូវកម្រិតសមត្ថភាពក្នុងការបង្ហាញឆន្ទៈ

សមត្ថភាពខាងឆន្ទៈ គឺសំដៅលើសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។[52] សកម្មភាព នៅពេលនេះមានន័យថា ជាកិច្ចសន្យា និងសកម្មភាពឯកតោភាគី។[53] តាមគោលការណ៍ស្វ័យភាពបុគ្គលឯកជន បុគ្គលអាចបង្កើតទំនាក់ទំនងគតិយុត្តរបស់ខ្លួនតាមរយៈឆន្ទៈសេរីរបស់ខ្លួន។ ត្រង់ចំណុចនេះ វាមានភាពចាំបាច់ណាស់សម្រាប់បុគ្គលដែលអាចបង្ហាញនូវឆន្ទៈរបស់ខ្លួនដោយត្រឹមត្រូវ។ នៅក្នុងន័យថា សមត្ថភាពខាងឆន្ទៈត្រូវបានទាញចេញពីគោលការណ៍ស្វ័យភាពបុគ្គលឯកជន។

## ៣.១. អានុភាពនៃការខ្វះសមត្ថភាពខាងឆន្ទៈ

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនបានអាចលុបចោលបាន។ [54] មានន័យថា សម្រាប់សកម្មភាពណាដែលធ្វើដោយជនដែលស្ថិតនៅក្នុងស្ថានភាពចុះថយយ៉ាងខ្លាំងនូវសមត្ថភាពក្នុងការយល់ដឹង និងការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនអាចលុបចោលបាន។

**ឧទាហរណ៍៖** បុគ្គលដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបាននូវសកម្មភាពរបស់ខ្លួនដោយសារជននោះបរិភោគស្រា ច្រើនរហូតស្រវឹង ឬជននោះប្រើប្រាស់ថ្នាំដែលប៉ះពាល់សកម្មភាពខាងឆន្ទៈ។ ប្រសិនបើ សាមីជន ឬសន្តតិជន ឬអច្ច័យលាភី លុបចោលសកម្មភាពនោះ សកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។[55]

ជាគោលការណ៍ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក្នុងផ្នែកទី៤ គឺសម្រាប់ការពារកុំឱ្យមានការខូចខាតដោយកិច្ចការជួញដូររបស់អ្នកដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ។ មាត្រានេះមានន័យថា ទោះបីជាមិនមែនជាជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព ដែលបានកំណត់នៅក្នុងផ្នែកទី៤ ក៏ដោយក៏អាចលុបចោលបាននូវសកម្មភាពដែលបានធ្វើឡើងក្នុងស្ថានភាពក្នុងការយល់ដឹង និងក្នុងការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់។

[52] មាត្រា ១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[53] មាត្រា ១៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[54] មាត្រា ១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[55] មាត្រា ៣៥៨ កថាខណ្ឌទី២ និងមាត្រា៣៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

## ៣.២. សមត្ថភាពក្នុងការធ្វើសកម្មភាព

សមត្ថភាពខាងឆន្ទៈមានន័យថាសកម្មភាពក្នុងស្ថានភាពដែលអាចយល់ និងវិនិច្ឆ័យបាននូវលទ្ធផលតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន។[56] ប៉ុន្តែនៅពេលធ្វើសកម្មភាពអ្វីមួយមានករណីជាច្រើនដែលមិនអាចធ្វើការវិនិច្ឆ័យថា អ្នកធ្វើសកម្មភាពនោះមាន ឬមិនមានសកម្មភាពខាងឆន្ទៈ ហើយការបញ្ជាក់នេះមិនមានភាពងាយស្រួលនោះទេ។

ទោះបីជាបុគ្គលដែលមិនមានសមត្ថភាពក្នុងការធ្វើសកម្មភាព នាពេលធ្វើសកម្មភាពនោះ វាមានការលំបាកក្នុងការបញ្ជាក់ពីសមត្ថភាពនៅក្រោយពេល។ ទន្ទឹមនឹងនេះ ប្រសិនបើជនបែបនេះអាចលុបកិច្ចសន្យាចោលបានដោយសារតែការខ្វះសមត្ថភាពខាងឆន្ទៈ ធ្វើឱ្យប៉ះពាល់ដល់ស្ថេរភាពប្រតិបត្តិការណ៍ជំនួញរបស់ភាគីម្ខាងទៀត។ បុគ្គលដែលមិនមានសមត្ថភាពខាងឆន្ទៈ និងកម្រិតនូវសកម្មភាពរបស់ពួកគាត់ក្នុងការធ្វើសកម្មភាព ដើម្បីការពារសិទ្ធិរបស់ពួកគាត់ និងដើម្បីរក្សានូវស្ថេរភាពប្រតិបត្តិការណ៍ជំនួញ។ ជាងនេះទៅទៀត បុគ្គល ដែលមានសមត្ថភាពខាងឆន្ទៈហើយ តែខ្វះសមត្ថភាពក្នុងការប្រឈមមុខជាមួយនឹងប្រព័ន្ធ និងផលប្រយោជន៍ស្មុគស្មាញត្រូវទទួលបានការការពារ។

ដោយផ្អែកទៅលើក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ជនដែលត្រូវកម្រិតសមត្ថភាពត្រូវទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា អ្នកអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភកៈរបស់ជននោះ នៅមុនពេលបង្ហាញឆន្ទៈរបស់ខ្លួន។ ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាពធ្វើសកម្មភាពដោយមិនបានទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា អ្នកអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភកៈទេ នោះសកម្មភាពរបស់ជននោះអាចលុបចោលបាន។[57] នេះជាការបញ្ជាក់ថា ជនទាំងនោះមិនអាចធ្វើសកម្មភាពប្រកបដោយប្រសិទ្ធិភាព និងឯករាជ្យបានទេ។ ដូច្នេះជនដែលត្រូវបានកម្រិតសមត្ថភាពត្រូវចាត់ទុកថាជា *ជនអសមត្ថភាពក្នុងការធ្វើសកម្មភាព*។[58]

ជាក់ស្តែងនៅពេលដែលសកម្មភាពដែលត្រូវបានធ្វើឡើងដោយបុគ្គល ដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពត្រូវបានបញ្ចប់ ព្រោះវាមានការលំបាកសម្រាប់ភាគីម្ខាងទៀត ដើម្បីដឹងថាជននោះមិនមានសមត្ថភាពពេញលេញ។ ហើយប្រសិនបើឱ្យភាគីខាងជនអសមត្ថភាពអាចលុបចោលសកម្មភាពដោយសារអសមត្ថភាពដោយមិនមានកម្រិត នោះវាអាចធ្វើឱ្យបាត់បង់ដល់ស្ថេរភាពក្នុងការប្រកបកិច្ចការ។ម្យ៉ាងវិញទៀតក៏មានភាពចាំបាច់ក្នុងការការពារជនដែលត្រូវបានកម្រិតសមត្ថភាព។ ដូច្នេះហើយ ក្រមរដ្ឋប្បវេណីបានចាត់ថ្នាក់

[56] មាត្រា ១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[57] មាត្រា ២៦ និង៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[58] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ជនទាំងនោះជាបីប្រភេទ ដើម្បីរក្សាតុល្យភាព រវាងការការពារជនដែលត្រូវបានកម្រិតសមត្ថភាព និងថែរក្សានូវស្ថេរភាពនៅក្នុងការប្រកបកិច្ចការ។ ជនដែលត្រូវបានកម្រិតសមត្ថភាព គឺមានដូចជា៖

- អនីតិជន
- ជននៅក្រោមអាណាព្យាបាលទូទៅ
- ជននៅក្រោមហិតូបត្ថម្ភ

ជនក្រៅពីជនដែលត្រូវបានកម្រិតនូវសមត្ថភាពធ្វើសកម្មភាព ជាជនដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពពេញលេញ។ កិច្ចសន្យាដែលបង្កើតឡើងដោយជនក្រៅពីជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព គឺមានសុពលភាពពេញលេញ ប្រសិនបើពុំមានមូលហេតុផ្សេងទៀតដែលនាំឱ្យមោឃៈ ឬមូលហេតុដែលអាចលុបចោលកិច្ចសន្យាបាន។

### ៣.២.១. អនីតិជន

អនីតិជន បើយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា សំដៅលើជនដែលមានអាយុក្រោម **១៨**( **ដប់ប្រាំបី** )ឆ្នាំ។[59] ក៏ប៉ុន្តែ អនីតិជនដែលទទួលបានអត្តាធីនភាពត្រូវបានចាត់ទុកថា បានដល់នីតិភាព។ [60] ជនដែលស្ថិតនៅក្រោមអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនចំពោះការអនុវត្តនូវកិច្ចគតិយុត្តតម្រូវឱ្យទទួលបានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាល។ ដូចនេះហើយសកម្មភាពដែលធ្វើឡើងដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោលបាន។[61]

អ្នកមានសិទ្ធិអំណាចមេបាគឺសំដៅដល់ឪពុកម្តាយ ជាឪពុក ឬម្តាយ។[62] ចំពោះអ្នកមានសិទ្ធិអំណាចមេបាលើកូនសុំ គឺឪពុកម្តាយចិញ្ចឹម។[63] ចំណែកឯអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវចាប់ផ្តើមនៅពេលមិនមានអ្នកអនុវត្តសិទ្ធិអំណាចមេបាសម្រាប់អនីតិជន។[64] អ្នកដែលអាចធ្វើការលុបចោលបានគឺសាមីខ្លួន ឬអ្នកតំណាងដែលច្បាប់កំណត់មានន័យថាអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។[65] អនីតិជនអាចធ្វើការលុបចោលតែម្នាក់ឯងដោយមិនចាំបាច់ទទួលការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណា

[59] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[60] មាត្រា ២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[61] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[62] មាត្រា ១០៣៦ និងមាត្រា១០៣៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[63] មាត្រា ១០៣៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[64] មាត្រា ១០៦៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[65] មាត្រា ៣៥៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ព្យាបាលសម្រាប់អនីតិជន។ សកម្មភាពរបស់អនីតិជនក្រោមរូបភាពជាកិច្ចសន្យា ឬសកម្មភាពឯកតោភាគី ដែលត្រូវបានលុបចោលនឹងត្រូវក្លាយជាមិនមានអានុភាពតាំងពីដំបូង ហើយមិនមានការខាតបង់ផលប្រយោជន៍ណាមួយទៅលើអនីតិជននោះទេ។

ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬឱ្យរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃមិនអាចលុបចោលបានទេ ទោះបីជាមិនមានការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនក៏ដោយ។ [66]ឧទាហរណ៍៖ ការទិញម្ហូបអាហារ សម្លៀកបំពាក់ ការបង់ទឹក ករណីដែលទទួលបានប្រទានកម្ម ឬរួចផុតពីកាតព្វកិច្ចអនីតិជនអាចធ្វើសកម្មភាពដែលមានសុពលភាពតែម្នាក់ឯងបាន។ ចំពោះសកម្មភាពទាំងនេះមានលក្ខណៈសំខាន់ណាស់ក្នុងការសម្រេចថា តើសកម្មភាពណាគឺជាសកម្មភាពដែលទាក់ទងសកម្មភាពប្រចាំថ្ងៃ ដោយធ្វើការពិចារណាទៅលើលក្ខខណ្ឌជាច្រើនផ្សេងទៀត ដូចជាអាយុរបស់អនីតិជន តម្លៃ ឬប្រភេទនៃកិច្ចការនោះជាអាទិ៍។

អនីតិជនអាចធ្វើការចាត់ចែងទ្រព្យសម្បត្តិដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែងក្នុងទំហំនៃគោលបំណងដែលបានកំណត់។[67] ឧទាហរណ៍៖ ប្រាក់របស់ឪពុកម្ដាយឱ្យសម្រាប់ទិញខោដៃនោះ អនីតិជនអាចទិញខោដៃបាន ហើយអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលអាចអនុញ្ញាតឱ្យអនីតិជនចាត់ចែងទ្រព្យសម្បត្តិដែលមិនបានកំណត់គោលដៅបាន។

ទាក់ទងនឹងការប្រកបអាជីវកម្មរបស់អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយ ឬច្រើនប្រភេទពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវមានសមត្ថភាពដូចនីតិជនចំពោះមុខជំនួញនោះ។ [68] ឧទាហរណ៍៖ អនីតិជនដែលឪពុកម្ដាយអនុញ្ញាតឱ្យបើកហាងកាហ្វេមួយកន្លែង អាចធ្វើសកម្មភាពបានដូចជា ជួលបុគ្គល ទិញទំនិញមកដាក់លក់ក្នុងហាង ហើយសកម្មភាពទាំងនេះមិនអាចធ្វើការលុបចោលក្រោមហេតុផលមិនមានការយល់ព្រមពីឪពុកម្ដាយនោះទេ។ ប្រសិនបើសកម្មភាពពាក់ព័ន្ធនឹងអាជីវកម្មដែលត្រូវបានអនុញ្ញាត តែអនីតិជនមិនមានលទ្ធិភាពធ្វើសកម្មភាពតែម្នាក់ឯងបាននោះទេ គឺធ្វើឱ្យបាត់បង់នូវអត្ថន័យនៃការអនុញ្ញាតឱ្យធ្វើអាជីវកម្ម៖

ក្រមរដ្ឋប្បវេណីបានកំណត់ពីលក្ខខណ្ឌនាំឱ្យដល់អត្តាធីនភាពដូចខាងក្រោម៖

- ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ១៦ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងបានដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបានតាមពាក្យសុំរបស់អនីតិជននោះ។

[66] មាត្រា ១៨ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[67] មាត្រា ១៩ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[68] មាត្រា ២០ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

- អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ។
- អនីតិជនដែលទទួលបានអត្តាធីនភាពត្រូវចាត់ទុកថាបានដល់នីតិភាព។ [69] ហេតុនេះហើយអនីតិជនដែលទទួលបានអត្តាធីនភាពអាចបង្កើតកិច្ចសន្យា និងធ្វើសកម្មភាពឯកតោភាគីដោយមានសុពលភាពតែម្នាក់ឯងបាន មិនអាចធ្វើការលុបចោលសកម្មភាពទាំងនោះដោយហេតុថាមិនមានការយល់ព្រមពីអ្នកអាណាព្យាបាលបាននោះទេ។

### ៣.២.២. ជននៅក្រោមអាណាព្យាបាលទូទៅ

ចំពោះជនដែលស្ថិតនៅក្រោមស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារតែមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅបាន តាមពាក្យសុំរបស់សាមីខ្លួនសហព័ន្ធញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅដ្ឋានរបស់ជននោះ ឬតំណាងអយ្យការ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំនៅពេលដែលមានពាក្យសុំ។[70]

ក្នុងករណីធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមហិតូបត្ថម្ភ តុលាការត្រូវលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភចំពោះជននោះ។ [71] មានន័យថា ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យបានដោយសារតែមានវិបត្តិផ្នែកបញ្ញាស្មារតី។ ដូចបានបញ្ជាក់ខាងលើ ជនដែលស្ថិតក្នុងស្ថានភាពដោយសារវិបត្តិបញ្ញាស្មារតីបែបនេះ តុលាការអាចប្រកាសពីអាណាព្យាបាលទូទៅ ដែលមានលក្ខខណ្ឌទាំងពីរនោះគឺ៖

- ខ្វះសមត្ថភាពជានិរន្តរ៍
- ត្រូវប្រកាសដោយតុលាការ អំពីការចាប់ផ្តើមអាណាព្យាបាលទូទៅ

**ឧទាហរណ៍៖**

- ជនដែលមិនអាចទិញអីវ៉ាន់ប្រចាំថ្ងៃដោយខ្លួនឯងបាន ហើយចាំបាច់ត្រូវមានអ្នកជំនួសក្នុងការធ្វើកិច្ចការ
- ជនដែលមិនអាចវិនិច្ឆ័យពីជីវិតរស់នៅប្រចាំថ្ងៃ ដូចជា ឈ្មោះ គ្រួសារ និងទីកន្លែងដែលខ្លួនរស់នៅ ជាអាទិ៍

[69] មាត្រា ២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[70] មាត្រា ២៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[71] មាត្រា ២៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

- ជនដែលធ្លាក់ក្នុងស្ថានភាពជាមនុស្សរុក្ខជាតិ (ស្ថានភាពស្លាប់ខួរក្បាលជាដើម)

របបអាណាព្យាបាលទូទៅនេះ គឺជារបបមួយសម្រាប់ការពារសិទ្ធិរបស់ជនដែលមានសមត្ថភាពខ្សោយ ដែលមានដូចជាជីវិត រូបរាងកាយ សេរីភាព ទ្រព្យសម្បត្តិ ជាអាទិ៍ ព្រោះជនខ្វះសមត្ថភាពមិនអាចយល់ដឹងអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។

ចំពោះជនបែបនេះ ប្រសិនបើមានពាក្យសុំឱ្យប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅពីសាមីខ្លួន ឬគ្រួសារនោះ តុលាការត្រូវពិនិត្យមើលពីស្ថានភាព ដើម្បីវិនិច្ឆ័យនូវការចាប់ផ្តើមអាណាព្យាបាលទូទៅ ហើយជ្រើសតាំងអ្នកដែលសមរម្យឱ្យធ្វើជាអ្នកអាណាព្យាបាលទូទៅ។

ចំពោះអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនវិញ ក៏មានសិទ្ធិ និងដាក់ពាក្យសុំឱ្យប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅផងដែរ ការអនុញ្ញាតឱ្យមានសិទ្ធិនេះ ក៏ព្រោះតែអ្នកត្រួតពិនិត្យអាចត្រូវបានគេសន្និដ្ឋានថា វាមានសារៈសំខាន់សម្រាប់អនីតិជនដែលមានសមត្ថភាពខ្សោយត្រូវបានប្រកាសឱ្យចាប់ផ្តើមអាណាព្យាបាលទូទៅ។ រីឯជនស្ថិតក្រោមរបបហិតូបត្ថម្ភ ប្រសិនបើជនដែលមានវិបត្តិផ្នែកស្មារតី ហើយគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាព ហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈអាចនឹងដាក់ពាក្យសុំដើម្បីចាប់ផ្តើមការប្រកាសអាណាព្យាបាលទូទៅបាន[72]ប៉ុន្តែដោយសារតែជនស្ថិតនៅក្រោមហិតូបត្ថម្ភរួចហើយ ដូច្នេះតុលាការត្រូវលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភនោះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួននៅពេលដែលតុលាការធ្វើការប្រកាសចាប់ផ្តើមអាណាព្យាបាល។ [73] ការតម្រូវឱ្យតុលាការលុបចោលដូចនេះ ក៏ព្រោះតែបើយើងទុកជនម្នាក់ឱ្យស្ថិតនៅក្រោមរបបហិតូបត្ថម្ភផង និងរបបអាណាព្យាបាលទូទៅផង វានឹងនាំឱ្យមានទំនាក់ទំនងគតិយុត្តដ៏ស្មុគស្មាញមួយកើតឡើង។

ចំពោះសិទ្ធិលុបចោលសកម្មភាពវិញ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា សកម្មភាពដែលជននៅក្រោមអាណាព្យាបាលទូទៅបានធ្វើ អាចលុបចោលបាន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលមានទំនាក់ទំនងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។[74] មានន័យថា សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលបានធ្វើអាចត្រូវបានគេលុបចោលដោយសាមីខ្លួន ឬអ្នកអាណាព្យាបាលទូទៅ។ មិនតែប៉ុណ្ណោះ ទោះបីជាសកម្មភាពដែលជននៅក្រោមអាណាព្យាបាលទូទៅបានធ្វើ ដោយមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅក៏ដោយ ក៏សកម្មភាពនោះអាចលុបចោលបានដែរ ព្រោះអ្នកនៅក្រោមអាណាព្យាបាលទូទៅស្ថិតនៅក្នុងស្ថានភាព

[72] មាត្រា ១១៣៨ និងមាត្រា១១៣៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[73] មាត្រា ១១០៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[74] មាត្រា ២៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ជានិរន្តន៍ដែលខ្វះសមត្ថភាព ដូច្នេះទោះបីជាអ្នកអាណាព្យាបាលបានផ្តល់នូវការយល់ព្រមជាមុនក៏ដោយក៏ជនដែលស្ថិតនៅក្រោមអាណាព្យាបាលមិនអាចធ្វើសកម្មភាពជាចាំបាច់តាមការរំពឹងទុកដែរ។ ក៏ប៉ុន្តែសកម្មភាពដែលទាក់ទងនឹងជីវិភាពរស់នៅប្រចាំថ្ងៃ ដែលជននៅក្រោមអាណាព្យាបាលធ្វើសកម្មភាពនោះ មិនអនុញ្ញាតនេះ គឺមានលក្ខណៈដូចគ្នាទៅនឹងករណីនៃអនីតិជន។

ក្រមរដ្ឋប្បវេណីមាត្រា២៦ បានបញ្ញត្តិពីការកម្រិតសមត្ថភាពរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅទាក់ទងនឹង សកម្មភាពដែលពាក់ព័ន្ធនិងទ្រព្យសម្បត្តិប៉ុណ្ណោះ រីឯសកម្មភាពពាក់ព័ន្ធនឹងឋានៈបុគ្គលរបស់ជនដែលនៅក្រោមអាណាព្យាបាលទូទៅវិញត្រូវការពិចារណាផ្សេងទៀត។ [75]

**ឧទាហរណ៍៖**ក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា អ្នកនៅក្រោមអាណាព្យាបាលទូទៅអាចរៀបអាពាហ៍ពិពាហ៍បានក្នុងករណីដែលជននោះមានសមត្ថភាពក្នុងកម្រិតអប្បបរមា ដែលចាំបាច់ដើម្បីធ្វើការវិនិច្ឆ័យពីអានុភាពនៃអាពាហ៍ពិពាហ៍។ ក្នុងករណីនេះមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ។ [76]

### ៣.២.៣. ជននៅក្រោមហិតូបត្ថម្ភ

ជាគោលការណ៍នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់លើជនដែលក្លាយជានីតិជនតាមច្បាប់កំណត់ ដែលមានការយល់ដឹងតិចតួចដោយសាររងអំពើព្យសនៈកម្ម បណ្តាលឱ្យមានវិការៈខាងបញ្ញាស្មារតី។

ក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីជននៅក្រោមហិតូបត្ថម្ភថា ជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួនសហព័ន្ធញាតិដែលស្ថិតនៅក្នុង៤(បួន)ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។ [77] មានន័យថា គឺជាជនទាំងឡាយដែលមានសតិទន់ខ្សោយដោយជំងឺថ្លង់ គ ខ្វិន ជរា ប្រមឹក ងងឹតងងល់ ញៀនអាភៀន (មិនមែនជានីតិជនដែលឆ្កួតវង្វេងល្ងីល្ងើ) ដែលអាចត្រូវតុលាការសម្រេចឱ្យឋិតនៅក្រោមហិតូបត្ថម្ភ ដើម្បីធ្វើការពិភាក្សា ឬត្រួតពិនិត្យលើសកម្មភាពស៊ីវិល។

នីតិជនឋិតនៅក្រោមហិតូបត្ថម្ភ មានសមត្ថកិច្ចបំពេញដោយខ្លួនឯងនូវកិច្ចការប្រចាំថ្ងៃ កិច្ចដែលជាប់ទាក់ទងនឹងជីវភាពឯកជន (ទទួលកូនដើម្បីចិញ្ចឹម និងគ្រប់គ្រង) លើកលែងតែការរៀបអាពាហ៍ពិពាហ៍ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ។

---

[75] មាត្រា ២៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[76] មាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[77] មាត្រា ២៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ជននៅក្រោមហិតូបត្ថម្ភ គឺជាអ្នកដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី លើកលែងតែអ្នកដែលជាកម្មវត្ថុនៃរបបអាណាព្យាបាល មានន័យថា អ្នកដែលគ្រាន់តែអាចទិញរបស់របរសម្រាប់ជីវភាពប្រចាំថ្ងៃតែប៉ុណ្ណោះ ប៉ុន្តែមិនអាចធ្វើកិច្ចសន្យាសំខាន់ៗដែលមានចែងក្នុងមាត្រា៣០ ដោយឯកឯងបានហើយដែលចាំបាច់មានជំនួយពីអ្នកផ្សេង ជានិច្ចកាល។ ចំពោះអ្នកទាំងអស់នេះ ពេលដែលមានពាក្យសុំពីសាមីខ្លួន ឬពីអ្នកមានសិទ្ធិដាក់ពាក្យសុំក្នុងគ្រួសារ ជាអាទិ៍ ដើម្បីសុំឱ្យចាប់ផ្ដើមហិតូបត្ថម្ភ តុលាការត្រូវធ្វើការពិនិត្យនូវស្ថានភាពនោះ និងវិនិច្ឆ័យអំពីការចាប់ផ្ដើមហិតូបត្ថម្ភនេះ ហើយជ្រើសតាំងជនដែលខ្លួនទទួលស្គាល់ថា សមស្របធ្វើជាហិតូបត្ថម្ភកៈ។[78]

ក្នុងករណីនេះ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ត្រូវបានបញ្ចូលជាអ្នកដែលមានសិទ្ធិដាក់ពាក្យសុំឱ្យចាប់ផ្ដើមហិតូបត្ថម្ភនេះ គឺដោយសារតែគិតដល់ករណីដែលពិការភាពខាងផ្លូវចិត្តរបស់ជនដែលធ្លាប់នៅក្រោមអាណាព្យាបាលទូទៅបានធូរស្រាល ហើយត្រូវប្ដូរឱ្យទៅនៅក្រោមរបបហិតូបត្ថម្ភវិញ។ ម្យ៉ាងទៀត ដើម្បីកុំឱ្យមានអំឡុងពេលមួយដែលគ្មានការការពារ នៅពេលដែលអនីតិជនដែលមានពិការភាពខាងបញ្ញា ឬខាងផ្លូវចិត្ត ក្លាយជានីតិជន នោះទើបមាត្រានេះអនុញ្ញាតឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំងសម្រាប់អនីតិជននោះដាក់ពាក្យសុំឱ្យចាប់ផ្ដើមហិតូបត្ថម្ភ។

ជននៅក្រោមហិតូបត្ថម្ភមិនអាចធ្វើសកម្មភាពគតិយុត្តសំខាន់ៗតែម្នាក់ឯងបានទេ គឺតម្រូវឱ្យមានការយល់ព្រមពីហិតូបត្ថម្ភកៈ ប៉ុន្តែប្រសិនបើមិនមានការយល់ព្រមពីហិតូបត្ថម្ភកៈទេ សកម្មភាពនោះអាចលុបចោលបាន ហើយអ្នកមានសិទ្ធិលុបចោលគឺ សាមីខ្លួន ឬហិតូបត្ថម្ភកៈ។ [79] សកម្មភាពគតិយុត្តសំខាន់ៗដែលអាចលុបចោលបានមានដូចជា៖

- ការទទួល ឬការប្រើប្រាស់ទុន
- ការខ្ចីទ្រព្យ ឬការធានា
- ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត។
- ការធ្វើសកម្មភាពបណ្ដឹង
- ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈត្តកម្ម
- ការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬការបែងចែកនូវមត៌ក

[78] មាត្រា ២៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[79] មាត្រា ៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

- ការប្រកែកមិនទទួលប្រទានកម្មឬអច្ច័យទាន ឬការយល់ព្រមទទួលនូវប្រទានកម្មឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក
- ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬការជួសជុលធំ
- ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី)ឆ្នាំ ចំពោះដីធ្លីលើសពី ២(ពីរ)ឆ្នាំ ចំពោះអាគារលើសពី ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុ។
- សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលបានរៀបរាប់នៅក្នុងមាត្រា២៨ (ការប្រកាសពីការចាប់ផ្ដើមហិតូបត្ថម្ភ) នៃក្រមរដ្ឋប្បវេណី ឬហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ។

## ៣.៣. ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព

ដោយសារតែ ភាគីម្ខាងទៀតដែលបានធ្វើសកម្មភាពជាមួយនឹងជនដែលត្រូវបានកម្រិតសមត្ថភាពងាយស្រួលទទួលរងនូវការខូចប្រយោជន៍ និងធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពនៃកិច្ចការជួញដូរ ព្រោះជនដែលត្រូវបានកម្រិតសមត្ថភាព អាចនឹងលុបចោលនូវកិច្ចសន្យានោះពេលណាក៏បាន។ ដូច្នេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិនូវវិធានដើម្បីការពារភាគីដែលបានចុះកិច្ចសន្យាជាមួយនឹងជនដែលបានកម្រិតសមត្ថភាព។

ជនដែលត្រូវបានកម្រិតសមត្ថភាពនេះ សំដៅលើ៖

- អនីតិជន[80]
- ជនក្រោមអាណាព្យាបាលទូទៅ[81]
- ជននៅក្រោមហិតូបត្ថម្ភ[82]

ជារួមជនដែលអសមត្ថភាព អាចលុបចោលនៃសកម្មភាពដែលបានធ្វើ ដូច្នេះវាអាចធ្វើឱ្យភាគីដែលបានធ្វើកិច្ចសន្យា ជាមួយនឹងអសមត្ថជនងាយនឹងបាត់បង់ប្រយោជន៍ និងអាចទទួលនូវហានិភ័យផ្សេងៗ។

ដូច្នេះដើម្បីការពារផលប្រយោជន៍របស់ភាគីដែលបានបង្កើតកិច្ចសន្យាជាមួយនឹងអសមត្ថជន ក្រមរដ្ឋប្បវេណីបានចែងពីសិទ្ធិដាស់តឿនរបស់ភាគីនោះទៅអ្នកអាណាព្យាបាល ឬអ្នកដែលមានសិទ្ធិអំណាចមេបា ឱ្យធ្វើការផ្ដល់សច្ចានុម័តចំពោះសកម្មភាពនោះ។ [83]

[80] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[81] មាត្រា ២៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[82] មាត្រា ២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[83] មាត្រា ៣២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ប្រសិនបើ ជនដែលត្រូវបានកម្រិតសមត្ថភាពបានប្រើវិធីឆបោក ដើម្បីឱ្យគេជឿជាក់ថាជាសមត្ថជននោះ សកម្មភាពនោះ មិនត្រូវអនុញ្ញាតឱ្យលុបចោលបានទេ។[84]

**៣.៣.១. សិទ្ធិដាស់តឿន**

ភាគីម្ខាងនៃជនដែលត្រូវកម្រិតសមត្ថភាពអាចមានសិទ្ធិជូនដំណឹងទៅជនដែលបានកំណត់មួយចំនួន និងធ្វើការដាស់តឿនឱ្យជននោះឆ្លើយថា ផ្តល់ ឬមិនផ្តល់ សច្ចានុមតិនៅក្នុងអំឡុងពេលជាក់លាក់ជាកំណត់។

កិច្ចសន្យា ដែលបានបង្កើតឡើងជាមួយនឹងជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះ គឺកិច្ចសន្យាមានសុពលភាពដែរ។ ប៉ុន្តែកិច្ចសន្យានោះអាចនឹងត្រូវបានលុបចោល ហើយភាគីម្ខាងទៀតត្រូវស្ថិតនៅក្នុងស្ថានភាពអស្ថេរភាពដោយគ្មានទីបញ្ចប់នៃកិច្ចសន្យាដែលអាចត្រូវបានគេលុបចោល។ ដូចនេះភាគីម្ខាងទៀតអាចដាស់តឿនឱ្យភាគីនៃជន ដែលត្រូវបានកម្រិតនូវសមត្ថភាព ត្រូវកំណត់ច្បាស់លាស់នូវទំនាក់ទំនងគតិយុត្តិនោះឱ្យបានឆាប់រហ័ស។

ក្រោយពេលដែលភាគីម្ខាងទៀត បានចុះកិច្ចសន្យាជាមួយនឹងជនដែលត្រូវបានកម្រិតនូវសមត្ថភាព រួចហើយភាគីនោះអាចធ្វើការដាស់តឿនបុគ្គលជាក់លាក់មួយចំនួនឱ្យធ្វើការបញ្ជាក់ច្បាស់លាស់ថា តើគាត់ផ្តល់សច្ចានុមតិលើកិច្ចសន្យានោះដែរ ឬទេ?

រីឯអ្នកត្រូវបានកម្រិតនូវសមត្ថភាពបានក្លាយជាជន ដែលមានសមត្ថភាពពេញលេញភាគីម្ខាងទៀតអាចជូនដំណឹងទៅជននោះ និងធ្វើការដាស់តឿនឱ្យឆ្លើយថាតើគាត់ផ្តល់សច្ចានុមតិលើសកម្មភាពនោះ ឬអត់នៅក្នុងអំឡុងពេលលើសពី ១ខែព្រោះជនដែលបានទទួលការដាស់តឿននោះ ក៏ចាំបាច់ត្រូវការពេលវេលាមួយដើម្បីពិចារណាលើលក្ខខណ្ឌមួយចំនួនដែរ។ [85]

ដូច្នេះបើបានធ្វើការដាស់តឿននេះហើយ ក្នុងរយៈពេលនោះបានកន្លងផុតទៅដោយគ្មានចម្លើយអំពីការផ្តល់ ឬមិនផ្តល់នូវសច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនោះត្រូវបានចាត់ទុកថាបានផ្តល់សច្ចានុមតិ។

ដូច្នេះ ភាគីម្ខាងទៀតអាចជូនដំណឹងទៅអ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈ និងធ្វើការដាស់តឿនជននោះ នៅមុនពេលដែលជនដែលត្រូវបានកម្រិតសមត្ថភាព ក្លាយជាជនដែលមានសមត្ថភាពឱ្យឆ្លើយថា បានផ្តល់សច្ចានុមតិលើសកម្មភាពនោះនៅក្នុងអំឡុងពេលលើសពី ១ខែ។ នៅក្នុងករណីនេះ

[84] មាត្រា ៣២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[85] មាត្រា ៣២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ប្រសិនបើអ្នកអាណាព្យាបាល មិនបានឆ្លើយតប នៅក្នុងអំឡុងពេលនោះទេ សកម្មភាពនោះត្រូវបានចាត់ទុកថាបានផ្តល់សច្ចានុមតិ។[86]

ជាងនេះទៅទៀតនៅក្នុងករណីនៃហិតូបត្ថម្ភ ភាគីម្ខាងទៀតអាចជូនដំណឹងទៅជននៅក្រោមហិតូបត្ថម្ភ ហើយដាស់តឿនជននោះឱ្យទទួលយកសច្ចានុមតិពីហិតូបត្ថម្ភកៈ នៅក្នុងអំឡុងពេលលើសពី ១ខែ ។ ប្រសិនបើជននៅក្រោមហិតូបត្ថម្ភ មិនបានជូនដំណឹងនៅក្នុងអំឡុងពេលនោះទេ កិច្ចសន្យាត្រូវបានចាត់ទុកថាបានលុបចោល។[87]

### ៣.៣.២. ការឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព

ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោក ដើម្បីឱ្យគេជឿជាក់ថាខ្លួនជាសមត្ថជន ជននោះមិនអាចលុបចោលសកម្មភាពបានទេ។ មានន័យថា ក្នុងករណីដែលជនត្រូវបានកម្រិតសមត្ថភាព បានប្រើវិធីឆបោកធ្វើឱ្យភាគីម្ខាងទៀតយល់ច្រឡំថា ជនដែលត្រូវបានកម្រិតសមត្ថភាពនោះជាសមត្ថជន និងបានធ្វើកិច្ចសន្យាហើយជនដែលត្រូវបានកម្រិតសមត្ថភាព ឬអ្នកអាណាព្យាបាលអាចលុបកិច្ចសន្យានោះ នោះវាមិនមានភាពយុត្តិធម៌ចំពោះភាគីម្ខាងទៀតហើយវាក៏ផ្ទុយនឹង លទ្ធិដែលមានលក្ខណៈជារូបភាពដែរ។ ដូច្នេះ នៅក្នុងករណីនេះជនដែលត្រូវបានកម្រិតសមត្ថភាព និងអ្នកអាណាព្យាបាលរបស់ខ្លួន មិនអាចលុបចោលសកម្មភាពនោះបានទេ។[88]

ការវិនិច្ឆ័យថា តើសកម្មភាពប្រភេទណាជាការឆបោកនោះ គឺត្រូវមើលទៅតាមស្ថានភាពនីមួយៗ ដូចជាតើជនដែលបានធ្វើសកម្មភាព ជាជនដែលត្រូវបានកម្រិតនូវសមត្ថភាពប្រភេទណាដែរ ខ្លឹមសារនៃសកម្មភាពនោះយ៉ាងណាដែរប្រភេទនៃសកម្មភាពរបស់ជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះយ៉ាងណាដែរ។ ការភូតកុហកអំពីអាយុរបស់អនីតិជនភាគច្រើន មិនអាចថាជាការឆបោកបានឡើយ។

ក្នុងករណីដែលភាគីម្ខាងទៀតគិតស្មានថា ខ្លួនជាសមត្ថជន ហើយជននោះលាក់ការណ៍ដោយមិនប្រាប់ថា ខ្លួនជាជននៅក្រោមហិតូបត្ថម្ភ ការណ៍នេះគ្រាន់តែជាការរក្សាការស្ងៀមស្ងាត់ប៉ុណ្ណោះ មិនអាចថាជាការឆបោកទេ ប៉ុន្តែ ប្រសិនបើបានប្រើពាក្យសំដីផ្សេងៗដែលធ្វើឱ្យភាគីម្ខាងទៀតយល់ច្រឡំ នេះអាចក្លាយទៅជាការឆបោកបាន។

[86] មាត្រា ៣២ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[87] មាត្រា ៣២ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[88] មាត្រា ៣៣ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

មានលក្ខខណ្ឌចំនួន៤ ដើម្បីទទួលស្គាល់នូវមធ្យោបាយឆបោកៈ

- ជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើមធ្យោបាយឆបោក
- មធ្យោបាយឆបោកនេះ ត្រូវបានគេប្រើដោយពាក់ព័ន្ធនឹងសមត្ថភាព
- ជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើមធ្យោបាយនោះ ដោយចេតនា
- ភាគីម្ខាងទៀត ត្រូវបានធ្វើឱ្យជឿជាក់ថា ជនដែលត្រូវបានកម្រិតសមត្ថភាព គឺជាជនដែលមានសមត្ថភាព

### ៣.៣.៣ មធ្យោបាយឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព

#### ក. លក្ខខណ្ឌ

- **ជនដែលត្រូវបានកម្រិតសមត្ថភាពបានប្រើមធ្យោបាយឆបោក**

មធ្យោបាយឆបោក គឺជាវិធីបោកបញ្ឆោតដើម្បីធ្វើឱ្យភាគីម្ខាងទៀតជឿថា ជនដែលត្រូវបានកម្រិតសមត្ថភាពនោះមានសមត្ថភាពក្នុងការធ្វើសកម្មភាព។ ថាតើសកម្មភាពណា ដែលត្រូវចាត់ទុកថាជាមធ្យោបាយឆបោក ត្រូវធ្វើការសម្រេចដោយធ្វើការពិចារណាទៅលើលក្ខខណ្ឌជាក់ស្តែងមួយចំនួន ដូចជាប្រភេទនៃការកម្រិតសមត្ថភាព ត្រូវបានគេសង្កត់ធ្ងន់ នោះទំហំនៃវិធីឆបោក និងត្រូវបានកម្រិត។

- មធ្យោបាយឆបោក ត្រូវបានប្រើដោយទាក់ទងនឹង **សមត្ថភាពក្នុងការធ្វើសកម្មភាព**

ឧទាហរណ៍ៈ អនីតិជន បាននិយាយថាខ្លួនមានអាយុ២១ឆ្នាំ ដោយបង្ហាញអត្តសញ្ញាណប័ណ្ណក្លែងក្លាយនៅពេលបង្កើតកិច្ចសន្យាគេចាត់ទុកថា វាឆ្លើយតបទៅនឹងមធ្យោបាយឆបោក ដែលទាក់ទងនឹងសមត្ថភាព។ ផ្ទុយទៅវិញប្រសិនបើអនីតិជន បាននិយាយថា គាត់បានប្រាក់គ្រប់គ្រាន់ដោយបង្ហាញសៀវភៅគណនីធនាគាររបស់ឪពុកគាត់នោះវាមិនមែនជាមធ្យោបាយបោកដែលទាក់ទងនឹងសមត្ថភាពក្នុងការធ្វើសកម្មភាពទេ។

- ជន ដែលត្រូវបានកម្រិតសមត្ថភាព បានប្រើមធ្យោបាយឆបោក ដោយមានចេតនា
- ភាគីម្ខាងទៀត ត្រូវបានធ្វើអោយជឿទុកចិត្តថា ជនដែលត្រូវបានកម្រិតសមត្ថភាពគឺជាជនដែលមានសមត្ថភាពពេញលេញ (ទំនាក់ទំនងហេតុ និងផល)ទំនាក់ទំនងហេតុ និងផលរវាងមធ្យោបាយឆបោក និងការជឿជាក់ទៅលើភាពមិនពិត ត្រូវតំរូវឱ្យមាន។

**ឧទាហរណ៍ៈ** អនីតិជន **ក** បានបន្លំខ្លួនធ្វើជា **គ** ដែលជាបងប្រុសរបស់ខ្លួនមានអាយុ២១ឆ្នាំ ហើយបានចុះកិច្ចសន្យាលក់ ទិញជាមួយនឹង **ខ**។ ប៉ុន្តែ **ខ** បានឱ្យដឹងថា **ក** គឺជាអនីតិជន និងមិនមែនជា **គ** ទៀត។ នៅក្នុងករណីនេះ អាចលុបចោលកិច្ចសន្យា ដោយផ្អែកលើការកម្រិតសមត្ថភាព ទោះបីជា **ក** បានប្រើមធ្យោបាយឆបោក ព្រោះមិនបានច្រឡំថា **ក** គឺជាជនដែលមានសមត្ថភាពឡើយ(មិនមានទំនាក់ទំនងហេតុ និងផល)។

**ខ. អានុភាព**

បើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើមធ្យោបាយឆបោកធ្វើឱ្យភាគីម្ខាងទៀតទុកចិត្តរហូតឈានដល់ចុះកិច្ចសន្យានោះអានុភាពនៃសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាព មិនអាចលុបចោលកិច្ចសន្យានោះបានទេ។

# សេចក្ដីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ របបគតិយុត្តនៃរូបវន្តបុគ្គល ធ្វើឱ្យយើងខ្ញុំបានសិក្សាឈ្វេងយល់ពីចំណេះដឹងបន្ថែម អំពីសមត្ថភាពនៃការទទួលសិទ្ធិ និងការកម្រិតសមត្ថភាពរបស់រូបវន្តបុគ្គលបានយ៉ាងច្បាស់។ ដូចដែលយើងបានសិក្សារួចមកហើយថា រូបវន្តបុគ្គល មានសិទ្ធិតាំងពីចាប់កំណើត និងបានបញ្ចប់ទៅវិញនៅពេលបុគ្គលបានទទួលរងនូវផ្នែកបញ្ញាស្មារតី ឬបាត់បង់នូវសិទ្ធិនៅពេលបានទទួលមរណៈភាព។ ជាងនេះទៅទៀតយើងក៏បានសិក្សាផងដែរ អំពីការបាត់ខ្លួនដែលមានរយៈពេល៥ឆ្នាំ ក្នុងមាត្រា៤១ នៅក្នុងស្ថានភាពធម្មតា ឬមានរយៈពេល១ឆ្នាំ ក្នុងករណីពិសេស។ ដែលបានសន្មត់ថា បាត់ខ្លួនតាមពាក្យសុំរបស់បុគ្គលដែលមានផលប្រយោជន៍ ហើយតុលាការបានចេញដីកាសម្រេចអំពីការបាត់ខ្លួននោះ។ ការប្រកាសបាត់ខ្លួននេះមានន័យថា បុគ្គលដែលបាត់ខ្លួនបានទទួលមរណៈភាព(ស្លាប់)នោះជាការបើកឱកាសឱ្យសហព័ទ្ធម្ខាងទៀតដែលនៅរស់ អាចរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀតបាន ហើយសន្តតិកម្មមានអានុភាពចំពោះសន្តតិជនផងដែរ។

នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិអំពីការកម្រិតសមត្ថភាពនៃសិទ្ធិរបស់រូបវន្តបុគ្គលយ៉ាងច្បាស់អំពី សមត្ថភាពទាក់ទងនិងរូបវន្តបុគ្គល គឺសមត្ថភាពខាងឆន្ទៈ សមត្ថភាពទទួលសិទ្ធិសិទ្ធិបុគ្គល និងការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់រូបវន្តបុគ្គល ដូចជាអនីតិជន ជននៅក្រោមអាណាព្យាបាល និងជននៅក្រោមហិតូបត្ថម្ភ ជាអសមត្ថជន ត្រូវបានការពារផលប្រយោជន៍ពិសេសជាងរូបវន្តបុគ្គលដទៃទៀត ដោយត្បិតថាជនទាំងបីប្រភេទនេះជាក្រុមដែលមានការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្តជាពិសេសលើកិច្ចសន្យា ដែលមានភាពទន់ខ្សោយពេក ដែលអាចនឹងងាយរងគ្រោះនូវការកេងចំណេញផលប្រយោជន៍ពីសមត្ថជន ឬជនទុច្ចរិតផ្សេងៗទៀត។ មិនតែប៉ុណ្ណោះ ច្បាប់ក៏បានការការពារទៅលើភាគីម្ខាងទៀតនៃកិច្ចសន្យាជាមួយជនដែលត្រូវបានកម្រិតសមត្ថភាពផងដែរ។

លើសពីនេះទៅទៀត ក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ដែលត្រូវយកមកអនុវត្តចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិរបស់បុគ្គល មានរូបវន្តបុគ្គល។ បន្ថែមពីនេះក្រមរដ្ឋប្បវេណីក៏បានដាក់ចេញនូវគោលការណ៍ជាមូលដ្ឋាន ដែលជាគោលការណ៍នៃការធានាសេចក្ដីថ្លៃថ្នូររបស់បុគ្គលភាពស្មើគ្នារបស់បុរសនារី និងសិទ្ធិលើទ្រព្យសម្បត្តិដែលត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ។ ក្រមរដ្ឋប្បវេណីក៏បានបើកសិទ្ធិឱ្យប្រើប្រាស់សិទ្ធិតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនដែលត្រូវគោរពនូវសិទ្ធិសេរីភាពខាងឆន្ទៈរបស់បុគ្គល និងទំនាក់ទំនងគតិយុត្តប្រកបដោយសន្តិភាពរួមទាំងបុគ្គលឯកជន។

ថ្វីត្បិតបុគ្គលត្រូវបានការពារសិទ្ធិ ទទួលសិទ្ធិ និងធានាសិទ្ធិ ពីក្រមរដ្ឋប្បវេណីយ៉ាងណាក៏ដោយ ប៉ុន្តែក្រមរដ្ឋប្បវេណីបានហាមបុគ្គលមិនឱ្យប្រើប្រាស់នូវសិទ្ធិដោយបំពានផងដែរ។ បើមិនដូច្នេះទេ នឹងមានការបំពានហួសពីទំហំនៃការការពារកើតមានឡើងហើយ ច្បាប់មិនទទួលស្គាល់នូវអានុភាពសិទ្ធិនោះឡើយ។ ការទទួលស្គាល់នៃក្រមរដ្ឋប្បវេណីនេះ គឺជាការប្រើប្រាស់សិទ្ធិ និងការអនុវត្តករណីយកិច្ចត្រូវធ្វើឡើងដោយសុចរិត និងភាពស្មោះត្រង់។

# អនុសាសន៍

ថ្វីត្បិតតែក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តិអំពីការកម្រិតសមត្ថិភាពរបស់រូបវន្តបុគ្គលហើយក៏ដោយ ក៏ប៉ុន្តែប្រសិនបើមិនមានការចូលរួមអនុវត្តទេនោះក៏គ្មានប្រសិទ្ធិភាពដែរ។ ដូចនេះយើងខ្ញុំចូលរួមបន្ថែមនូវអនុសាសន៍ខ្លឹមសារ និងអត្ថន័យមួយចំនួនទាក់ទងទៅនឹងប្រធានបទខាងលើ ដើម្បីជាប្រយោជន៍ក្នុងការបំពេញន័យបន្ថែមទៀតឱ្យកាន់តែប្រសើរឡើង។

ជាការពិតណាស់ ការឈ្វេងយល់បន្ថែម វាជារឿងមួយដល់សំខាន់សម្រាប់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានឱ្យបានដឹងអំពីប្រធាននៃសិទ្ធិ និងកាតព្វកិច្ចរបស់រូបវន្តបុគ្គល ដើម្បីផ្តល់ភាពងាយស្រួលដល់ជីវភាពប្រចាំថ្ងៃ។ យ៉ាងវិញប្រជាពលរដ្ឋបានយល់ដឹងអំពីការកម្រិតសមត្ថភាពរបស់រូបវន្តបុគ្គលផងដែរ។

ការសិក្សាស្រាវជ្រាវ វាជាកត្តាមួយដ៏សំខាន់សម្រាប់សិក្សានុសិស្សក្នុងការបង្កើននូវចំណេះដឹងបន្ថែមក្រៅពីសិក្សាតាមកាលវិភាគរបស់សាលា។ យ៉ាងណាមិញ វាជាពុទ្ធិមួយក្នុងការឈ្វេងយល់ដឹងអំពីប្រធាននៃសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលគ្រប់រូបដូចជា សមត្ថភាពនៃការទទួលសិទ្ធិរបស់រូបវន្តបុគ្គល និងការកម្រិតសមត្ថភាពនៃការទទួលសិទ្ធិរបស់រូបវន្តបុគ្គល ព្រមទាំងការចាប់ផ្តើម និងបញ្ចប់សមត្ថភាពទទួលសិទ្ធិរបស់រូបវន្តបុគ្គលផងដែរ។ ជាពិសេស ការសិក្សាស្រាវជ្រាវក្រោមប្រធានបទ របបគតិយុត្តនៃរូបវន្តបុគ្គលនេះតែម្តង វាជាគន្លឹះមូលដ្ឋានមួយក្នុងការចាប់ផ្តើមសិក្សាអំពីក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានប្រការឱ្យប្រើ លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០១១
- អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ១០៣អនក្រ/បក, ២៩ ធ្នូ ២០០០
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦

## ២. សៀវភៅ និងស្នាដៃអ្នកនិពន្ធ

- វចនានុក្រមខ្មែរ របស់សម្តេចពោធិញាណ ជួន ណាត
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១ គន្ថីទី១ ដល់គន្ថីទី៣ ឆ្នាំ២០០៩
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ ដោយក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០១៣
- ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា (JICA)
- មេរៀន នីតិរដ្ឋប្បវេណី១ គម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជា ឧបត្ថម្ភដោយអង្គការ JICA សមិទ្ធិផលរបស់ ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ចាប់ផ្តើមពីឆ្នាំ ២០១២ ដល់ ២០១៧
- សេចក្តីផ្តើមនីតិរដ្ឋប្បវេណី និពន្ធដោយ សាស្រ្តាចារ្យ ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ ឆ្នាំ២០១១ (JICA)
- យុត្តិសាស្រ្តល្បីៗនៃរឿងក្តីរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ បកប្រែដោយ លោក ស៊ឹម វិរៈ ខែសីហា ឆ្នាំ២០១៥ (JICA)
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា (JICA)

# ឧបសម្ព័ន្ធទី១

- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារក
- ពាក្យប្តឹងសុំសំបុត្រអត្រានុកូលដ្ឋាន
- សំបុត្របញ្ជាក់កំណើត
- បញ្ជីមរណភាព
- សំបុត្រមរណភាព

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង: ..............................

ស្រុក ខណ្ឌ: ............................

ឃុំ សង្កាត់: ............................

ភូមិ: ..........................................

លេខ: .........................................

## លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារក

យើង .............................. ជាមេភូមិ ........................... ឃុំ សង្កាត់ .............................. ស្រុក ខណ្ឌ .................................. ខេត្ត ក្រុង ............................ សូមបញ្ជាក់ថា (នាមត្រកូល និងនាមខ្លួនទារក)................................ ភេទ .......... កើតនៅថ្ងៃទី .......... ខែ ........... ឆ្នាំ ............. នៅភូមិ.........................ឃុំ សង្កាត់.........................ស្រុក ខណ្ឌ.........................ខេត្ត ក្រុង........................ ឪពុកឈ្មោះ ................................ កើតនៅថ្ងៃទី ........... ខែ ............ ឆ្នាំ ................ និង ម្តាយឈ្មោះ ................................កើតនៅថ្ងៃទី......... ខែ ............ ឆ្នាំ .................. មានទីលំនៅបច្ចុប្បន្ននៅភូមិ ..................... ឃុំ សង្កាត់ .................. ស្រុក ខណ្ឌ ...................... ខេត្ត ក្រុង ........................ពិតជាបានកើតនៅផ្ទះប្រាកដមែន ដែលមាន ឆ្មបបង្កើតឈ្មោះ ....................................... ភេទ ........... ឆ្នាំកំណើត.................................. ទីលំនៅបច្ចុប្បន្ននៅភូមិ ........................... ឃុំ សង្កាត់ .............................. ស្រុក ខណ្ឌ ................................ ខេត្ត ក្រុង ........................... ។

ធ្វើនៅ ....................... ថ្ងៃទី ......... ខែ ........... ឆ្នាំ ..................

មេភូមិ

ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំសំបុត្រអត្រានុកូលដ្ឋាន(១) ............................

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ...................................... សញ្ជាតិ .........................ឆ្នាំកំណើត .....................

មុខរបរបច្ចុប្បន្ន : ........................................ ....................................................................................

ទីលំនៅបច្ចុប្បន្ន : ផ្ទះលេខ...................... នៅភូមិ................. ឃុំ សង្កាត់ (២) ......................... .........

ស្រុក ខណ្ឌ(២) ...........................ខេត្ត ក្រុង(២) ................................................។

**<u>សូមគោរពជូន</u>**

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ (២) ..............................

**<u>កម្មវត្ថុ</u> :** សំណើសុំចុះសៀវភៅអត្រានុកូលដ្ឋាន............................របស់ឈ្មោះ ..........................

**<u>យោង</u> :** - លិខិត(៣)...........................................លេខ......... ចុះថ្ងៃទី .........ខែ............ ...........

ឆ្នាំ.......................របស់.......................................................................................................។

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទ-នាងខ្ញុំ សូមជំរាបជូន លោក /លោកស្រី មន្ត្រីអត្រានុកូលដ្ឋាន មេត្តាជ្រាបថា :ឈ្មោះ...................................ត្រូវជា.............................ពុំទាន់បាន ចុះសៀវភៅអត្រានុកូលដ្ឋាន...................................................នៅឡើយ ។

អាស្រ័យហេតុនេះ សូម លោក /លោកស្រី មន្ត្រីអត្រានុកូលដ្ឋាន មេត្តាចុះសៀវភៅ អត្រានុកូលដ្ឋាន(១) .......................................................តាមសំណើ ខ្ញុំបាទ/ នាងខ្ញុំដោយអនុគ្រោះ ។

ជូនភ្ជាប់មកជាមួយនូវ........................................................................... ចំនួន ០១ ច្បាប់ ។

ធ្វើនៅ.......................... ថ្ងៃទី ......... ខែ ............ ឆ្នាំ ...........

**ស្នាមមេដៃស្តាំអ្នកស្នើ**

**ឈ្មោះ** ............................

**<u>សំគាល់</u>** : (១) កំណើត មរណភាព

(២) គូសចោលនូវពាក្យដែលមិនប្រើ (៣) លិខិតពាក់ព័ន្ធសំរាប់បញ្ជាក់ជាភស្តុតាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង .........
ស្រុក ខណ្ឌ កងមាស.........
ឃុំ សង្កាត់ កងតាណឹង.....

លេខ.......
សៀវភៅបញ្ជាក់កំណើតលេខ
ឆ្នាំ.............២០០៤.................

# សំបុត្របញ្ជាក់កំណើត

| | | | |
|---|---|---|---|
| នាមត្រកូល | | | ភេទ |
| នាមខ្លួនអ្នកកើត | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួនអ្នកកើត | | |
| សញ្ជាតិ | | ខ្មែរ | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | ថ្ងៃទី១០ ឧសភា ឆ្នាំ ១៩៩៨ | |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | ភូមិទី ៥ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម ព្រះរាជាណាចក្រកម្ពុជា | |

| ឪពុក ម្តាយ | ឪពុក | ម្តាយ |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី១៦ ឧសភា ឆ្នាំ១៩៦៩ | ថ្ងៃទី៣០ កក្កដា ឆ្នាំ១៩៧៤ |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | ភូមិទី ៥ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម | ភូមិទី ៥ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម |

ធ្វើនៅ......កងតាណឹង ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤

មន្ត្រីអត្រានុកូលដ្ឋាន

វិរៈ . ចរ៉ា

~~រាជធានី~~ ខេត្ត (១)........... កណ្តាល ......
~~ក្រុង~~ ស្រុក ~~ខណ្ឌ~~ (២)........ ល្វាឯម .........
ឃុំ ~~សង្កាត់~~ (៣)......... កោះកែវ ............

លេខ (៤)........... ០៣ ...............................
សៀវភៅមរណភាពលេខ (៥)....០១/២០១៤....
ឆ្នាំ (៦)....... ២០១៤ .......................................

# បញ្ជីមរណភាព

| | | | |
|---|---|---|---|
| នាមត្រកូល (៧) | ស៊ឹម | ភេទ (៩) | សញ្ជាតិ (១០) |
| នាមខ្លួនសព (៨) | វណ្ណា | ស្រី | ខ្មែរ |
| ជាអក្សរឡាតាំង (១១) នាមត្រកូល | SIM | | |
| ជាអក្សរឡាតាំង (១១) នាមខ្លួនសព | VANNA | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១២) | ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១ | | |
| ទីកន្លែងកំណើត (១៣) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | ........... ភូមិបឹង ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា .................. | | |
| ស្ថានភាពសព (១៤) នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | មានប្តី | | |
| មុខរបររបស់សពមុនពេលស្លាប់ (១៥) | កសិករ | | |
| ទីលំនៅរបស់សពមុនពេលស្លាប់ (១៦) | ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល ប្រទេសកម្ពុជា | | |
| លេខអត្តសញ្ញាណប័ណ្ណ (១៧) | គ្មាន | | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៨) | ថ្ងៃ ច័ន្ទ ទី ២០ ខែ មករា ឆ្នាំ ២០១៤ | | |
| ទីកន្លែងស្លាប់ (១៩) | ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល ប្រទេសកម្ពុជា | | |
| មូលហេតុស្លាប់តាមបណ្តឹងរបស់អ្នករាយការណ៍ (២០) | លើសឈាម | | |
| នាមត្រកូល និង នាមខ្លួនឪពុកសព (២១) | ស៊ឹម សារឿន | សញ្ជាតិ ខ្មែរ (២២) | |
| ជាអក្សរឡាតាំង (២៤) | SIM SAROEUN | ~~រស់~~ ឬ ស្លាប់ (២៣) | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៥) | ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩១០ | | |
| នាមត្រកូល និង នាមខ្លួនម្តាយសព (២៦) | ស្រី នាង | សញ្ជាតិ ខ្មែរ (២៧) | |
| ជាអក្សរឡាតាំង (២៩) | SREY NEANG | ~~រស់~~ ឬ ស្លាប់ (២៨) | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣០) | ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២ | | |
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍អំពីសព (៣១) | សោម សារិទ្ធ | ភេទ (៣២) | សញ្ជាតិ (៣៣) |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៤) | ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៥៥ | ប្រុស | ខ្មែរ |
| ត្រូវជាអ្វីនឹងសព (៣៥) | កូនបង្កើត | | |
| មុខរបរបច្ចុប្បន្ន (៣៦) | កសិករ | | |
| ទីលំនៅបច្ចុប្បន្ន (៣៧) | ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល ប្រទេសកម្ពុជា | | |
| លេខអត្តសញ្ញាណប័ណ្ណ (៣៨) | គ្មាន | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះ នឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។

(៤០) ធ្វើនៅ...កោះកែវ..... ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤

(៣៩) **ស្នាមមេដៃស្តាំអ្នករាយការណ៍**

សោម សារិទ្ធ

(៤១) **មន្ត្រីអត្រានុកូលដ្ឋាន**

មេឃុំ

(៤២) ហត្ថលេខា និងត្រា

ប៊ុត ប៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

~~រាជធានី~~ ខេត្ត (១) ---- *កណ្ដាល* -----

លេខ (៤)-------- *០៣* ------------------

~~ក្រុង~~ ស្រុក ~~ខណ្ឌ~~ (២) ----- *ល្វាឯម* ---

សៀវភៅមរណភាពលេខ (៥)–០១/២០១៤--

ឃុំ ~~សង្កាត់~~ (៣) ----- *កោះកែវ* ---

ឆ្នាំ (៦)---------- *២០១៤* -----------------

# សំបុត្រមរណភាព

<table>
<tr><td colspan="2">នាមត្រកូល (៧)</td><td>ស៊ឹម</td><td rowspan="2">ភេទ (៩)<br>ស្រី</td></tr>
<tr><td colspan="2">នាមខ្លួនសព (៨)</td><td>វណ្ណា</td></tr>
<tr><td rowspan="2">ជាអក្សរឡាតាំង (១០)</td><td>នាមត្រកូល</td><td colspan="2">SIM</td></tr>
<tr><td>នាមខ្លួនសព</td><td colspan="2">VANNA</td></tr>
<tr><td colspan="2">សញ្ជាតិ (១១)</td><td colspan="2">ខ្មែរ</td></tr>
<tr><td colspan="2">ថ្ងៃ ខែ ឆ្នាំកំណើត (១២)</td><td colspan="2">ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១</td></tr>
<tr><td colspan="2">ទីកន្លែងកំណើត (១៣)<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស</td><td colspan="2">.........ភូមិបឹង ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង<br>ប្រទេសកម្ពុជា .......................................................</td></tr>
<tr><td colspan="2">ស្ថានភាពសព (១៤)<br>នៅលីវ មានប្ដី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ</td><td colspan="2">មានប្ដី</td></tr>
<tr><td colspan="2">ថ្ងៃ ខែ ឆ្នាំស្លាប់ (១៥)</td><td colspan="2">ថ្ងៃ ច័ន្ទ ទី ២០ ខែ មករា ឆ្នាំ ២០១៤</td></tr>
<tr><td colspan="2">នាមត្រកូល និង នាមខ្លួនឪពុកសព (១៦)</td><td>ស៊ឹម សារឿន</td><td rowspan="2">សញ្ជាតិ (១៧)<br>ខ្មែរ</td></tr>
<tr><td colspan="2">ជាអក្សរឡាតាំង (១៨)</td><td>SIM SAROEUN</td></tr>
<tr><td colspan="2">ថ្ងៃ ខែ ឆ្នាំកំណើត (១៩)</td><td colspan="2">ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០</td></tr>
<tr><td colspan="2">នាមត្រកូល និង នាមខ្លួនម្ដាយសព (២០)</td><td>ស្រី នាង</td><td rowspan="2">សញ្ជាតិ (២១)<br>ខ្មែរ</td></tr>
<tr><td colspan="2">ជាអក្សរឡាតាំង (២២)</td><td>SREY NEANG</td></tr>
<tr><td colspan="2">ថ្ងៃ ខែ ឆ្នាំកំណើត (២៣)</td><td colspan="2">ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២</td></tr>
</table>

(២៤) ធ្វើនៅ...កោះកែវ..... ថ្ងៃទី *២២* ខែ *មករា* ឆ្នាំ *២០១៤*

(២៥) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(២៦) *ហត្ថលេខា និងត្រា*

*ប៊ុត ប៊ុន*

# ទម្រង់គំរូនានានៃសេចក្តីសម្រេចរបស់តុលាការ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

លេខ ៖..........................

## ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

យើង.............................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាខេត្តកណ្តាល

បានឃើញមាត្រា ៦២ កឋាខ័ណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ:.....................ចុះថ្ងៃទី..........ខែ...........ឆ្នាំ..........របស់សាលាដំបូងខេត្តកណ្តាល ។

រវាងដើមចោទឈ្មោះ.........................ភេទ..........អាយុ.......ឆ្នាំ របរកស៊ី...............................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ..............ផ្លូវលេខ......................ក្រុម..............ភូមិ...............................
ឃុំ,សង្កាត់..................................ស្រុក, ខណ្ឌ..................................ខេត្ត, ក្រុង...............................
ប្តី, ប្រពន្ធឈ្មោះ...................................... មានកូន................នាក់។

និងចុងចំលើយឈ្មោះ.............................ភេទ........... អាយុ........ឆ្នាំ របរកស៊ី.......................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ផ្លូវលេខ.................ក្រុម............ភូមិ...............................
ឃុំ, សង្កាត់.................................ស្រុក, ខណ្ឌ...............................ខេត្ត, ក្រុង...............................
ប្តី, ប្រពន្ធឈ្មោះ..................................... មានកូន...............នាក់។

ដែលមានកម្មវត្ថុបណ្តឹង:..........................................................................................
..........................................................................................................................

### សំអាងហេតុ

-ដើម្បីដំណើរការនីតិវិធីបណ្តឹងទៅតាមច្បាប់។

-..........................................................................................................

-..........................................................................................................

### ហេតុដូច្នេះសម្រេច

បង្គាប់ឱ្យដើមចោទឈ្មោះ................................មានទីលំនៅផ្ទះលេខ...........ផ្លូវលេខ.............
ក្រុម.............ភូមិ.............................ឃុំ, សង្កាត់..............................ស្រុក, ខណ្ឌ.............................
ខេត្ត, ក្រុង..........................................។
បង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធចំនួន.........................................................................
នៅសាលាដំបូងខេត្តកណ្តាល ឱ្យបានមុនថ្ងៃទី.....................ខែ....................ឆ្នាំ.................... ជាកំណត់ ដើម្បីតុលាការចាត់ការរឿងក្តីនេះតាមច្បាប់ ។

បានទទួល
ថ្ងៃទី.........ខែ.................ឆ្នាំ............
**ស្នាមមេដៃ**

កណ្តាល, ថ្ងៃទី.............ខែ............ឆ្នាំ............
**ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

## ដីកាសម្រេចបណ្ដឹងតវ៉ា និងការចូលរួមជួយអន្តរាគមន៍

លេខ:............................ យើង............................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរៈ នៃសាលាដំបូងកណ្ដាល

បានឃើញមាត្រា ៩៥ និងមាត្រា ៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ:......................ចុះថ្ងៃទី..........ខែ...........ឆ្នាំ..........របស់សាលាដំបូងខេត្តកណ្ដាល ។

រវាងដើមចោទឈ្មោះ.........................ភេទ..........អាយុ.......ឆ្នាំ របរកស៊ី................................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ..............ផ្លូវលេខ......................ក្រុម..............ភូមិ.............................
ឃុំ,សង្កាត់.................................ស្រុក, ខណ្ឌ.................................ខេត្ត, ក្រុង..............................
ប្ដី, ប្រពន្ធឈ្មោះ..................................... មានកូន................នាក់។

និងចុងចំលើយឈ្មោះ..............................ភេទ........... អាយុ.........ឆ្នាំ របរកស៊ី.......................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ផ្លូវលេខ.................ក្រុម............ភូមិ.....................................
ឃុំ, សង្កាត់.................................ស្រុក, ខណ្ឌ..............................ខេត្ត, ក្រុង...................................
ប្ដី, ប្រពន្ធឈ្មោះ.................................... មានកូន...............នាក់។

ដែលមានកម្មវត្ថុបណ្ដឹង:.........................................................................................................
....................................................................................................................................................

បានឃើញពាក្យបណ្ដឹងតវ៉ា និងការចូលរួមជួយអន្តរាគមន៍ចុះថ្ងៃទី...........................................
របស់ឈ្មោះ.............................ភេទ.................អាយុ...........ឆ្នាំ មានទីលំនៅសព្វថ្ងៃផ្ទះលេខ...........
ផ្លូវលេខ..................ក្រុម...............ភូមិ..................................ឃុំ, សង្កាត់........................................
ស្រុក, ខណ្ឌ.......................... ខេត្ត, ក្រុង.............................. ដែលចូលរួមជាភាគី.......................។

### សំអាងហេតុ

-.................................................................................................................................

-.................................................................................................................................

-.................................................................................................................................

### ហេតុដូច្នេះសម្រេច

១-ពាក្យបណ្ដឹងតវ៉ា និងការចូលរួមជួយអន្តរាគមន៍ មានមូលហេតុសមស្របតាម, ផ្ទុយច្បាប់។

២-មិនអនុញ្ញាតិឱ្យឈ្មោះ.................................ចូលរួមជួយអន្តរាគមន៍ជាភាគី.......................
នៅក្នុងសំណុំរឿងខាងលើតាមច្បាប់តទៅ ។

កណ្ដាល, ថ្ងៃទី.............ខែ...............ឆ្នាំ..............

**ចៅក្រម,ក្រុមប្រឹក្សាជំនុំជំរៈ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

## ដីកាសម្រេចជ្រើសតាំង ឬផ្លាស់ប្ដូរអ្នកតំណាងពិសេស

លេខ:...............................

យើង.........................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាដំបូងខេត្តកណ្ដាល

បានឃើញមាត្រា ៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជ ក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ:......................ចុះថ្ងៃទី..........ខែ...........ឆ្នាំ..........របស់សាលាដំបូងខេត្តកណ្ដាល ។

រវាងដើមចោទឈ្មោះ.........................ភេទ..........អាយុ.......ឆ្នាំ របរកស៊ី.................................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ..............ផ្លូវលេខ.....................ក្រុម..............ភូមិ...................................
ឃុំ,សង្កាត់..................................ស្រុក, ខណ្ឌ...................................ខេត្ត, ក្រុង...............................
ប្ដី, ប្រពន្ធឈ្មោះ...................................... មានកូន................នាក់។

និងចុងចំលើយឈ្មោះ..............................ភេទ........... អាយុ........ឆ្នាំ របរកស៊ី.......................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ផ្លូវលេខ..................ក្រុម............ភូមិ.....................................
ឃុំ, សង្កាត់.................................ស្រុក, ខណ្ឌ.................................ខេត្ត, ក្រុង...................................
ប្ដី, ប្រពន្ធឈ្មោះ..................................... មានកូន...............នាក់។

ដែលមានកម្មវត្ថុបណ្ដឹង:...........................................................................................................
...................................................................................................................................................

បានឃើញពាក្យសុំជ្រើសរើស, ផ្លាស់ប្ដូរអ្នកតំណាងចុះថ្ងៃទី.........................................................
របស់ឈ្មោះ................................ភេទ.............អាយុ...........ឆ្នាំ មានទីលំនៅសព្វថ្ងៃផ្ទះលេខ...........
ផ្លូវលេខ..................ក្រុម........ភូមិ............................................ឃុំ, សង្កាត់..........................................
ស្រុក, ខណ្ឌ...............................................ខេត្ត, ក្រុង...................................... ។

### សំអាងហេតុ

-......................................................................................................................

-......................................................................................................................

-......................................................................................................................

### ហេតុដូច្នេះសម្រេច

ជ្រើសតាំង, ផ្លាស់ប្ដូរ ឈ្មោះ.................................អាយុ...............ឆ្នាំ មានអាស័យដ្ឋានខាងលើជាតំណាងពិសេសឱ្យឈ្មោះ..................................ចាប់ពីពេលនេះតទៅ ។

កណ្ដាល, ថ្ងៃទី..........ខែ.............ឆ្នាំ............

**ក្រុមប្រឹក្សាជំនុំជំរះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

លេខ:.............................

## ដីកាសម្រេចលុបចោលការអនុញ្ញាត

យើង.................................... ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរ: នៃសាលាដំបូងខេត្តកណ្ដាល

បានឃើញមាត្រា ៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជ ក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ.................ចុះថ្ងៃទី...........ខែ..............ឆ្នាំ............. របស់សាលា ដំបូងខេត្តកណ្ដាល ។

បានឃើញដីកាទទួលស្គាល់, ដីកាចាត់តាំងអ្នកតំណាងដោយអណត្តិ របស់សាលាដំបូងខេត្តកណ្ដាល ។

បានឃើញពាក្យសុំរបស់សាមីខ្លួន

### សំអាងហេតុ

-.......................................................................................................................................

-.......................................................................................................................................

-.......................................................................................................................................

### ហេតុដូច្នេះសម្រេច

លុបចោលការអនុញ្ញាតការអនុញ្ញាត លើលិខិតទទួលស្គាល់អ្នកតំណាងដោយអណត្តិ តាមដីកាលេខ..............ចុះថ្ងៃទី..........ខែ...........ឆ្នាំ........... របស់សាលាដំបូងខេត្តកណ្ដាល ចោលជាអសារបង់។

កណ្ដាល, ថ្ងៃទី...........ខែ.............ឆ្នាំ.............

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងក្រុងភ្នំពេញ
លេខ:
........................

**ដីកាសម្រេចពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត**

យើង.................................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាដំបូងក្រុងភ្នំពេញ។

បានឃើញមាត្រា៣៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជ ក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦។

បានឃើញសាលក្រមលេខ.................. ចុះថ្ងៃទី....... ខែ.............. ឆ្នាំ.............

បានឃើញពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ចុះថ្ងៃទី...... ខែ......... ឆ្នាំ.......... របស់ឈ្មោះ............

**សំអាងហេតុ**

-.........................................................................................................................

-.........................................................................................................................

-.........................................................................................................................

**ហេតុដូច្នេះសម្រេច**

ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ចុះថ្ងៃទី....... ខែ......... ឆ្នាំ............ របស់ឈ្មោះ.............. ត្រឹមត្រូវ ឬមិនត្រឹមត្រូវ។

ធ្វើនៅក្រុងភ្នំពេញ, ថ្ងៃទី.......... ខែ...........ឆ្នាំ...........

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងក្រុងភ្នំពេញ
លេខ:
........................

## ដីកាសម្រេចលើកចោលការទាមទារ ឱ្យចែកចំណែក

យើង....................................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាដំបូងក្រុងភ្នំពេញ។

បានឃើញមាត្រា៤០៩, មាត្រា៤២៦ និងមាត្រា៤៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃ ទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ.................. ចុះថ្ងៃទី......... ខែ..............ឆ្នាំ............ របស់សាលា ដំបូងក្រុងភ្នំពេញ។

បានឃើញសាលក្រមលេខ.................... ចុះថ្ងៃទី........ ខែ................ ឆ្នាំ...............

បានឃើញដីកាសម្រេចទាមទារឱ្យចែកចំណែកលេខ................. ចុះថ្ងៃទី......... ខែ......... ឆ្នាំ......

បានឃើញពាក្យសុំ ចុះថ្ងៃទី....... ខែ......... ឆ្នាំ............. របស់ឈ្មោះ........................................

### សំអាងហេតុ

-..........................................................................................................................................

-..........................................................................................................................................

-..........................................................................................................................................

### ហេតុដូច្នេះសម្រេច

១-លើកចោលការទាមទាររបស់ឈ្មោះ........................................

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់....................................................

ធ្វើនៅក្រុងភ្នំពេញ, ថ្ងៃទី........... ខែ.............ឆ្នាំ.............

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ
លេខៈ
........................

## ដីកាសម្រេចលើកចោលពាក្យសុំបន្តនីតិវិធី

យើង.....................................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញមាត្រា៥២៥ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ តាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ.................. ចុះថ្ងៃទី......... ខែ..............ឆ្នាំ............ របស់សាលា ដំបូងរាជធានីភ្នំពេញ។

បានឃើញសាលក្រមលេខ........................ ចុះថ្ងៃទី........ ខែ.................. ឆ្នាំ.............

បានឃើញដីកាសម្រេចបន្តនីតិវិធីលេខ...................... ចុះថ្ងៃទី......... ខែ........... ឆ្នាំ...............

បានឃើញពាក្យសុំ ចុះថ្ងៃទី......... ខែ...... ឆ្នាំ............... របស់ឈ្មោះ......................................

### សំអាងហេតុ

-..........................................................................................................................................

-..........................................................................................................................................

-..........................................................................................................................................

### ហេតុដូច្នេះសម្រេច

១-លើកចោលពាក្យសុំ ចុះថ្ងៃទី........ ខែ....... ឆ្នាំ............. របស់ឈ្មោះ.......................................

២-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់.................................................

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី........... ខែ.............ឆ្នាំ.............

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ**

# ឧបសម្ព័ន្ធទី២

## អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ :** ១០៣ អនក្រ បក

# អនុក្រឹត្យ

# ស្តីពី

# អគ្គានុកូលដ្ឋាន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៦ ក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១/៩៦ /០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/04 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌

តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូល-គ្រួសារខ្លួន និងសង្គមជាតិ និងដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ច ។

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្រប ច្បាប់ ក្នុងដែនសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

សំបុត្រអត្រានុកូលដ្ឋានមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព ។

**មាត្រា ៣.-**

ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអនុត្រានុកូលដ្ឋាន ជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

**មាត្រា ៤.-**

រាល់ការសុំចុះសៀវភៅអនុត្រានុកូលដ្ឋាន កំណើត និងមរណភាព អ្នករាយការណ៍ និង/ឬ សាក្សី និង ឬសាមីខ្លួន ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះការសុំចុះសៀវភៅអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ សាមីខ្លួន និងសាក្សី ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រា-នុកូលដ្ឋាន ។

**មាត្រា ៥.-**

ទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយឯកភាពគ្នាទូទាំងប្រ-ទេស ។

គំរូសំបុត្រអត្រានុកូលដ្ឋាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៦.-**

ការចុះសៀវភៅអត្រានុកូលដ្ឋាន សម្រាប់ព្រះរាជវង្សានុវង្ស ត្រូវអនុវត្តដោយឡែក ដោយប្រគល់ភារកិច្ចនេះជូន រដ្ឋមន្ត្រីព្រះបរមរាជវាំង ។

**មាត្រា ៧.-**

រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ ។

មន្ត្រីអត្រានុកូលដ្ឋាន មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងទេ ។

រាល់ការចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋាន មានចែងក្នុងជំពូកទី ១០ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## អំពីមន្ត្រីអត្រានុកូលដ្ឋាន

**មាត្រា ៨.-**

មេឃុំ ឬចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនដីឃុំ ឬសង្កាត់ ដែលខ្លួនគ្រប់គ្រង ។

នៅពេលដែលមេឃុំ ឬចៅសង្កាត់អវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរឱ្យជំទប់ ឬចៅសង្កាត់រង តាមឋានានុក្រម និងរាយការណ៍ជូនអភិបាលស្រុក ឬខណ្ឌតាមផ្លូវការ ។

ក្នុងករណីមេឃុំ ឬចៅសង្កាត់អវត្តមានដោយស្លាប់ ឬដោយបញ្ឈប់ពីមុខតំណែង ក្នុងចន្លោះពេលដែលមិនទាន់មានការរៀបចំមេឃុំ ឬចៅសង្កាត់ថ្មី សិទ្ធិជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់ជូនទៅជំទប់ ឬចៅសង្កាត់រង តាមឋានានុក្រម ។

**មាត្រា ៩.-**

មន្ត្រីអត្រានុកូលដ្ឋានមានភារកិច្ច :

- ទទួលពិនិត្យ កត់ត្រា រឿងហេតុសំខាន់ៗទាក់ទងនឹង កំណើត អាពាហ៍ពិពាហ៍ មរណភាពនៃជនទាំងឡាយ ចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន
- ចេញសេចក្តីចម្លង ឬសម្រង់នៃអត្រានុកូលដ្ឋាន ដែលមានក្នុងឆ្នាំមិនទាន់ដាច់
- កែតម្រូវអក្ខរាវិរុទ្ធ លើអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ តាមលក្ខខណ្ឌមាត្រា ១៣ នៃអនុក្រឹត្យនេះ
- អនុញ្ញាតអោយរៀបចំអាពាហ៍ពិពាហ៍ និងធ្វើបុណ្យបូជា ឬបញ្ចុះសព
- ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋាន ដែលខ្លួនបានអនុវត្ត
- ចុះហត្ថលេខា និងបោះត្រា លើសំបុត្រអត្រានុកូលដ្ឋាន
- កែតម្រូវ ឬបដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬតាមបទប្បញ្ញត្តិនៃច្បាប់
- ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទឱ្យបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និងការគ្រប់គ្រង
- បញ្ជូនសៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលដាច់ទៅ យកទៅតម្កល់ទុកនៅសាលាស្រុក ឬខណ្ឌផ្ទាល់ ០១ ច្បាប់ និងនៅតុលាការខេត្ត ឬក្រុងសាមី ០១ច្បាប់
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ ឬសង្កាត់ ឱ្យបានយល់ដឹងអំពីកាតព្វកិច្ចរបស់ខ្លួន ចំពោះអត្រានុកូលដ្ឋាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ដែលមកទំនាក់ទំនងអំពីអត្រានុកូលដ្ឋាន
- ធ្វើរបាយការណ៍អំពី កំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ ឬសង្កាត់ជារៀងរាល់ខែ និង រាល់ដំណាច់ឆ្នាំនីមួយៗ ផ្ញើទៅសាលាស្រុក ឬសាលាខណ្ឌ សាមី
- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន អំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់ ។

**មាត្រា ១០.-**

រាល់ការអនុវត្តការងារអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋានដូចការងារអត្រានុកូលដ្ឋាន ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិអន្តរជាតិ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ដោយប្រកាសរួម ។

**មាត្រា ១១.-**

ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានមន្ត្រី ០១រូប នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឱ្យទទួលមុខងារជាមន្ត្រីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយជូនព័ត៌មានទៅ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

បែបបទនៃការបំពេញមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននេះ ត្រូវពិគ្រោះរវាងក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

## ជំពូកទី ៣
## អំពីសៀវភៅអត្រានុកូលដ្ឋាន

**មាត្រា ១២.-**

ក្នុងឃុំ ឬសង្កាត់នីមួយៗ ត្រូវមានសៀវភៅអត្រានុកូលដ្ឋាន សម្រាប់កត់ត្រាអំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព បញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព ។

សៀវភៅនេះត្រូវធ្វើជា០២ច្បាប់ដូចគ្នា តាមប្រភេទនីមួយៗ តាមគំរូដែលកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សៀវភៅនេះត្រូវចុះចំនួនសន្លឹក និងចុះលេខរៀងសន្លឹក ពីសន្លឹកទី១ ដល់សន្លឹកចុងក្រោយ ។ សន្លឹកទី១ និង សន្លឹកចុងក្រោយត្រូវសរសេរជាអក្សរ និងត្រូវចុះហត្ថលេខាពេញដោយអភិបាលស្រុក ឬអភិបាលខណ្ឌ ។ សន្លឹកទី២ និងសន្លឹកដទៃទៀតដែលអាចចុះហត្ថលេខាសង្ខេប និងបោះត្រារបស់អភិបាលស្រុក ឬអភិបាលខណ្ឌគ្រប់សន្លឹក ។

**មាត្រា ១៣.-**

សៀវភៅអត្រានុកូលដ្ឋានទាំងអស់ មិនត្រូវឱ្យមាន កោស ឆូត លុប សរសេរជ្រៀតថែមឡើយ ។ បើមានកោស ឆូត លុបត្រូវទុកពាក្យទាំងនោះឱ្យនៅមើលបាន ហើយសរសេរទឹកខ្មៅពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងថា យល់ព្រមលុបប៉ុន្មានពាក្យ និងយល់ព្រមថែមប៉ុន្មានពាក្យ ទើបមន្ត្រីអត្រានុកូលដ្ឋាន អ្នករាយការណ៍ និង ឬសាក្សី និង ឬសាមីខ្លួនចុះហត្ថលេខា ឬផ្តិតមេដៃស្តាំទាំងអស់គ្នា ។

ចំពោះសន្លឹកណា ដែលសរសេរខុស ត្រូវរក្សាទុកជាឯកសារមិនឱ្យហែកចោលឡើយ ។

**មាត្រា ១៤.-**

សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗ ត្រូវបើកឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ មករា ហើយត្រូវបញ្ឈប់នៅថ្ងៃទី ៣១ ខែ ធ្នូ រៀងរាល់ឆ្នាំ ។

នៅខែមករាឆ្នាំបន្ទាប់ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបញ្ជូនសៀវភៅតាមប្រភេទនីមួយៗ ០១ច្បាប់ ទៅសាលាស្រុក ឬខណ្ឌសាមី ដើម្បីត្រួតពិនិត្យ និងតម្កល់ទុកនៅទីនោះ និងបញ្ជូន ០១ច្បាប់ទៀតដែលដូចគ្នាទៅតម្កល់ទុកនៅតុលាការខេត្ត ឬក្រុងសាមី ដើម្បីមុខការតាមផ្លូវច្បាប់ ។

សៀវភៅអត្រានុកូលដ្ឋាន ដែលបានប្រើប្រាស់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវបញ្ជូនតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅខែ មករា ឆ្នាំបន្ទាប់ មកតម្កល់ទុក ០១ច្បាប់ នៅក្រសួងមហាផ្ទៃ និង ០១ច្បាប់ទៀតមកតម្កល់ទុកនៅក្រសួងយុត្តិធម៌ ។

**មាត្រា ១៥.-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរៀបចំទុកដាក់ ថែរក្សាសៀវភៅអត្រានុកូលដ្ឋាន និងសំណុំឯកសារដែលពាក់ព័ន្ធការងារអត្រានុកូលដ្ឋានឱ្យបានល្អ និងរក្សាការសម្ងាត់ របស់បុគ្គលម្នាក់ៗ ។

ចំពោះសាលាឃុំ សង្កាត់ណា ដែលមិនធានាសុវត្ថិភាព មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់នោះ ត្រូវផ្ញើសៀវភៅអត្រានុកូលដ្ឋានទៅរក្សាទុកនៅសាលាស្រុក ឬខណ្ឌសាមី ។ ពេលធ្វើអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាននោះត្រូវទៅធ្វើនៅសាលាស្រុក ឬខណ្ឌ ទៅតាមបែបបទដូចបានអនុវត្តនៅសាលាឃុំ ឬសង្កាត់ ។

**មាត្រា ១៦.-**

ក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំសៀវភៅអត្រានុកូលដ្ឋានឱ្យបានឯកភាពទូទាំងប្រទេស និងបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន អំពីរបៀបកត់ត្រាចូលក្នុងសៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ និងធានាផ្គត់ផ្គង់សៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់មន្ត្រីអត្រានុកូលដ្ឋាន ។

## ជំពូកទី ៤
## អំពីសំបុត្រកំណើត

**មាត្រា ១៧.-**

បើមានទារកកើត ឪពុក ឬម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ មិនឱ្យហួស ៣០ថ្ងៃដោយបញ្ជាក់ឱ្យបានច្បាស់ថា ឪពុក និងម្តាយនៃទារកនោះ មានខាន់ស្លា ឬឥតខាន់ស្លា ។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍ របស់ឪពុក និងម្តាយទារកនោះ ។

បើឪពុក ម្តាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬអ្នកនៅជិតខាងដែលបានឃើញ និងដឹងឮផ្ទាល់ពីទារកនោះកើតឱ្យទៅចុះសៀវភៅកំណើត ឱ្យបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និងម្តាយទារកនោះជាប់ទៅជាមួយផង ។

**មាត្រា ១៨.-**

នាមត្រកូលរបស់ទារក អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬអាចយក ឈ្មោះជីតាខាងឪពុក ឬអាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន ។

ឪពុក ម្ដាយ ឬអាណាព្យាបាល ជាអ្នកដាក់នាមខ្លួនឱ្យទារក ។

**មាត្រា ១៩.-**

បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬសង្កាត់នៃ ទីកន្លែងដែលរើសទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុ និងចុះក្នុងសៀវភៅកំណើត ដោយរកឈ្មោះ ដាក់ឱ្យ ហើយបើក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំ កំណើតទារកដែលរើសបាននោះ ដោយស្មាន និងឈ្មោះឪពុក ម្ដាយដាក់ថាមិនស្គាល់ ។

បើមានជនណា សុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ។

ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើស បាននោះ ទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រកំណើត របស់ទារកនោះ និងកំណត់ហេតុស្ដីអំពីការប្រគល់ទារកនោះ ជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ។

**មាត្រា ២០.-**

ចំពោះទារក ឬកុមារ ដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា ក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ហើយដែលពុំទាន់មានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត អ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះត្រូវធ្វើសេចក្ដី រាយការណ៍ និងនាំទារក ឬកុមារនោះ ទៅជូនមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមជ្ឈមណ្ឌលនោះតាំងនៅ ដើម្បីមន្ត្រី អត្រានុកូលដ្ឋានផ្ដល់សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតឱ្យ ។

**មាត្រា ២១.-**

ការសុំទារក ឬកុមារ ពីមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និងការសុំ ទារក ឬកូនពីឪពុក ម្ដាយធ្វើជាកូនចិញ្ចឹម ត្រូវអនុវត្តទៅតាមនីតិវិធី ដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

កិច្ចសន្យាសុំកូនខាងលើនេះ ត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន ។

**មាត្រា ២២.-**

បើមានទណ្ឌិតណាម្នាក់សម្រាលកូន ទីកន្លែងកំណើតនៃទារកនោះ ត្រូវយកតាមលំនៅដ្ឋានរបស់ម្ដាយ ឬឪពុក ។

**មាត្រា ២៣.-**

ទារកកើតពីឪពុក ម្ដាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅកំណើតដែរ ។ នៅពេល ធ្វើសំបុត្រកំណើត បើឪពុក ម្ដាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះ បានឆ្លើយទទួលស្គាល់ដោយដាក់លាក់ ចំពោះមុខ មន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក ម្ដាយនោះថា ជា ឪពុក ម្ដាយរបស់កូននោះ ។

ករណីមានតែឪពុក ឬមានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកថាជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងតែប៉ុណ្ណោះ ។

ក្រោយពេលឪពុក ឬម្តាយបានប្តឹងចុះក្នុងសៀវភៅកំណើត ឪពុក ឬម្តាយណា ដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុក ឬម្តាយនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

កូនឥតខាន់ស្លាដែលឪពុក ម្តាយបានទទួលស្គាល់នឹងទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឪពុក ម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នា និងពេលចុះអាពាហ៍ពិពាហ៍ ឬក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

**មាត្រា ២៤.-**

ក្រោយពេលចុះសៀវភៅកំណើតរួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឱ្យអ្នករាយការណ៍ នូវសំបុត្រកំណើតច្បាប់ដើម ០១ សន្លឹកទុកជាសម្គាល់ និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ២៥.-**

បើមានទារកកើតហើយ ទុកឱ្យហួសរយៈពេល ៣០ថ្ងៃ ពុំបានទៅរាយការណ៍ ចុះសៀវភៅកំណើត ឪពុក ឬ ម្តាយ ឬអាណាព្យាបាល ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី ។

ឪពុក ឬម្តាយ ឬអាណាព្យាបាលទារកនោះ ត្រូវយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ដើម្បីចុះសៀវភៅកំណើត ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ។

**មាត្រា ២៦.-**

ទារកកើតពីម្តាយ ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្របច្បាប់ឯបរទេស ឬពីឪពុកជាពលរដ្ឋខ្មែរ ម្តាយជាជនបរទេស ឬពីឪពុកជាជនបរទេស ម្តាយជាពលរដ្ឋខ្មែរ ឪពុក ម្តាយ នៃទារកនោះ អាចសុំចុះសៀវភៅកំណើតនៅឯប្រទេសនោះតាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ ។ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវទៅចុះសៀវភៅកំណើតនៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅតាមសំបុត្រកំណើតដែលប្រទេសនោះចេញឱ្យ ដោយយកសញ្ជាតិតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅ នូវសំបុត្រកំណើតថ្មី ឱ្យយកទៅប្រើប្រាស់ ។

បើឪពុក ម្តាយនៃទារកនោះ បានទៅរាយការណ៍ចុះសៀវភៅកំណើតនៅឯស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ អាចយកសំបុត្រកំណើតដែលប្រគល់ឱ្យនោះមកប្រើប្រាស់ជាផ្លូវការបាន ។

**មាត្រា ២៧.-**

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលបានរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បានកើតទារកនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ឪពុក ម្តាយទារកនោះ អាចទៅចុះសៀវភៅកំណើតនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់ ឬអាចទៅចុះសៀវភៅកំណើតនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃប្រទេសរបស់ខ្លួន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។ បើចុះសៀវភៅកំណើតនៅសាលាឃុំ សាលាសង្កាត់ នាមត្រកូល និងនាមផ្ទាល់ខ្លួន និង នាមនៃឪពុក ម្តាយរបស់ទារកនោះ ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

ចំពោះសញ្ជាតិនៃកូននោះ ត្រូវអនុវត្តតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៥
## អំពីសំបុត្រអាពាហ៍ពិពាហ៍

**មាត្រា ២៨.-**

បុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យឱ្យបានហ្មត់ចត់នូវពាក្យសុំនោះដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៩.-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងធ្វើនោះ ផ្សាយជាសាធារណៈ នៅលំនៅដ្ឋាន និងនៅសាលាឃុំ ឬសាលាសង្កាត់ នៃសាមីខ្លួននារី ០១ច្បាប់ ។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងបិទនៅសាលាឃុំ ឬសង្កាត់នៃសាមីខ្លួនបុរស ០១ច្បាប់ ។

ប័ណ្ណប្រកាសត្រូវចុះ :

១- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅនៃអនាគត ប្តី ប្រពន្ធ ។

២- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅរបស់ឪពុក ម្តាយ នៃអនាគតប្តី ប្រពន្ធ បើឪពុក ឬម្តាយស្លាប់ ត្រូវដាក់ថាស្លាប់

៣- រយៈពេលប្តឹងជំទាស់ ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ ។ ផុតរយៈពេល ១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្តឹងជំទាស់ ។ បើមានបណ្តឹងជំទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្តឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយចប់ ។

**មាត្រា ៣០.-**

អាពាហ៍ពិពាហ៍ នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារី ដែលស្ម័គ្រចិត្តទទួលគ្នាជាប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋាន ខាងលំនៅដ្ឋានរបស់នារី ។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីអាត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន ០២នាក់ផង ។

**មាត្រា ៣១.~**

ពេលសាមីខ្លួនជាអនាគត ប្តី និងប្រពន្ធមករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ៣២.~**

ការសុំរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលរស់នៅស្របច្បាប់ឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេស ដែលគូភាគីមានទីលំនៅ ។ ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ និងអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយនឹងបទបញ្ញត្តិច្បាប់នៃព្រះ រាជាណាចក្រកម្ពុជា ។ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនៃកន្លែងរៀបអាពាហ៍ពិពាហ៍ នោះ ឬបើប្តី ប្រពន្ធមកតាំងលំនៅនៅព្រះរាជាណាចក្រកម្ពុជាត្រូវយកមកចុះសៀវភៅអាពាហ៍ពិពាហ៍នៅសាលាឃុំ ឬសង្កាត់ដែលខ្លួនបានរស់នៅ ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឬមន្ត្រី អត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពី សៀវភៅនូវសំបុត្រពាហ៍ពិពាហ៍ថ្មី ឱ្យទៅជននោះយកទៅប្រើប្រាស់ ។

**មាត្រា ៣៣.~**

អាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស ឬជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៤.~**

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនអន្តោប្រវេសន៍នោះបាន ដោយអនុវត្តតាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ ដែលមានចែងនៅក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋានដោយប្រាប់ពី ទីកន្លែង និងពេលវេលាដែលខ្លួនរៀបអាពាហ៍ពិពាហ៍នេះឱ្យបានច្បាស់ ។

ពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ឬសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាក៏បាន ។

ការចុះឈ្មោះនៃជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

## ជំពូកទី ៦

## អំពីសំបុត្រមរណភាព

**មាត្រា ៣៥.-**

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់ របស់អ្នកស្លាប់ ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសព បើស្លាប់ដោយជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទង ដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋណាមួយ ។

ការចុះសៀវភៅមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព ។

បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាត អាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សង្គម ត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬផ្នែកអនាម័យភ្លាម ។ បើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះ សពតាមការសម្រេចនោះ ។

**មាត្រា ៣៦.-**

បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យ ដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយណា ដែលមានការពាក់ព័ន្ធត្រូវរាយការណ៍ភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ ដើម្បីឱ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និងដោះស្រាយរួសរាន់ ។ ក្រោយពីមានការសម្រេចយ៉ាង ណាពីភ្នាក់ងារមានមសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពបាន ។

**មាត្រា ៣៧.-**

បើមានពលរដ្ឋខ្មែររស់នៅក្នុងឃុំ ឬសង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬសង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់របស់អ្នកស្លាប់រស់នៅដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់ ឱ្យទៅយកសពធ្វើបុណ្យ និងចុះសៀវភៅមរណភាពនៅឃុំ ឬសង្កាត់នៃអ្នកស្លាប់នោះស្នាក់នៅជាប់លាប់ ។

បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬគ្មានអ្នកស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ត្រូវចាត់

ថែងបូជា ឬបញ្ចុះសពនោះ និងចុះសៀវភៅមរណភាពក្នុងឃុំ ឬសង្កាត់នោះ ។

**មាត្រា ៣៨.-**

បើមានអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ អ្នកទទួលខុសត្រូវនៃពន្ធនាគារនោះ ត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងទៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅអចិន្ត្រៃយ៍របស់អ្នកទោសនោះដើម្បីមន្ត្រីអត្រានុកូលដ្ឋានចុះក្នុងសៀវភៅមរណភាព ។

**មាត្រា ៣៩.-**

ពេលមានអ្នករាយការណ៍អំពីមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅមរណភាព រួចប្រគល់ឱ្យអ្នកសុំនូវសំបុត្រមរណភាពច្បាប់ដើម ០១សន្លឹក និងចេញសេចក្ដីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ៤០.-**

បើមានអ្នកស្លាប់ទុកហួសរយៈពេល ១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត-ក្រុងសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅមរណភាព ។

**មាត្រា ៤១.-**

បើមានពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេសបានស្លាប់ ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកដែលបានឃើញអ្នកស្លាប់នោះផ្ទាល់ អាចទៅចុះសៀវភៅមរណភាពនៅប្រទេសនោះ តាមច្បាប់របស់ប្រទេសនោះ ។ ពេលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាពដែលធ្វើនៅបរទេសនោះទៅចុះសៀវភៅនៅ ឃុំ ឬសង្កាត់ដែលសាមីខ្លួនអ្នកស្លាប់ ធ្លាប់ស្នាក់នៅជាប់លាប់មុនពេលចេញទៅបរទេស ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវដកយកសំបុត្រមរណភាពថតចម្លងជាផ្លូវការទុកជាឯកសារ ហើយចម្លងចេញពីសៀវភៅមរណភាពនូវសំបុត្រមរណភាពថ្មី ប្រគល់ឱ្យសាមីខ្លួនអ្នកសុំយកទៅប្រើប្រាស់ ។

បើបានទៅរាយការណ៍ចុះសៀវភៅមរណភាពនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ រួចហើយពេលត្រឡប់មកប្រទេសកម្ពុជាវិញអាចយកសំបុត្រមរណភាពនោះមកប្រើប្រាស់ជាផ្លូវការបាន ។

**មាត្រា ៤២.-**

ជនអន្តោប្រវេសន៍ និងជនបរទេសរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានស្លាប់នៅ លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬអ្នកទទួលខុសត្រូវ អាចទៅចុះសៀវភៅមរណភាពនៅសាលាឃុំ ឬសង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់ មុនពេលខ្លួនស្លាប់ ឬអាចទៅចុះសៀវភៅមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ។

បើចុះសៀវភៅមរណភាពនៅឃុំ ឬសង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

## ជំពូកទី ៧
## អំពីសំបុត្របញ្ជាក់កំណើត

**មាត្រា ៤៣.-**

ពលរដ្ឋខ្មែរដែលបានកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំនើតប្រើប្រាស់ អាចសុំចុះសៀវភៅបញ្ជាក់សំបុត្រកំណើតបាន តាមគំរូវណៃនាំថ្មី នៅសាលាឃុំ ឬសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានស្គាល់ច្បាស់ពីប្រវត្តិអ្នកត្រូវសុំធ្វើសំបុត្របញ្ជាក់កំណើត និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយ ពីពេលដែលសាមីខ្លួនកើតនាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះនៅក្នុងសៀវភៅបញ្ជាក់កំណើតមិនត្រូវឱ្យខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬសោធននិវត្តន៍ជាផ្លូវការឡើយ ។

**មាត្រា ៤៤.-**

ពេលមានអ្នកមកសុំចុះសៀវភៅកំនើត មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់កំណើត រួចត្រូវប្រគល់អោយសាមីខ្លួន ឬក្រុមគ្រួសារនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួនដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ៨
## អំពីសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

**មាត្រា ៤៥.-**

ពលរដ្ឋខ្មែរដែលបានគ្នាជាប្តី ឬប្រពន្ធ ពិតប្រាកដ នៅមុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយគ្មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនប្តី ប្រពន្ធអាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូវណៃនាំថ្មីនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់ពីសាមីខ្លួនប្តី ប្រពន្ធនោះ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយគ្នានាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៤៦.-**

ពេលមានសាមីខ្លួនប្តី និងប្រពន្ធមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ៩
## អំពីសំបុត្របញ្ជាក់មរណភាព

**មាត្រា ៤៧.-**

ពលរដ្ឋខ្មែរ ដែលស្លាប់មុនពេលអនុក្រឹត្យស្តីពី អត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តានដែលនៅរស់ អាចមកសុំចុះសៀវភៅបញ្ជាក់មរណភាពតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្នបាន ដោយនាំសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់អំពីការស្លាប់ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយអ្នកស្លាប់ មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៤៨.-**

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់មរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់មរណភាព រួចត្រូវប្រគល់ឱ្យអ្នកសុំនូវសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំ ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ១០
## អំពីសេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋាន

**មាត្រា ៤៩.-**

សេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋានមាន សេចក្តីចម្លង ឬសម្រង់សំបុត្រកំណើត សេចក្តីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព សេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់កំណើត សេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ និងសេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់មរណភាព ។

រាល់ខ្លឹមសារនៃសេចក្តីចម្លង ត្រូវអនុវត្តដូចគ្នា នឹងខ្លឹមសារក្នុងសំបុត្រអត្រានុកូលដ្ឋានដើម ។ សម្រង់អត្រានុកូលដ្ឋាន ត្រូវធ្វើតាមសំណើរបស់អ្នកសុំដោយដកស្រង់នូវខ្លឹមសារសំខាន់ៗ ចេញពីសៀវភៅអត្រានុកូលដ្ឋាន ។

**មាត្រា ៥០.-**

បើមានអ្នកមកសុំចម្លង ឬសុំស្រង់សំបុត្រអត្រានុកូលដ្ឋានពីមន្ត្រីអត្រានុកូលដ្ឋាន អ្នកសុំត្រូវមានសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមយកមកជាមួយ តែការចម្លង ឬសម្រង់ត្រូវស្រង់ចេញពីសៀវភៅដែលតម្កល់ទុក ។ ក្នុងករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មន្ត្រីអត្រានុកូលដ្ឋានត្រូវចម្លងតាមសៀវភៅអត្រានុកូលដ្ឋាន ដែលបានចុះពីមុនមក និងកំពុងថែរក្សា ក្នុងឆ្នាំដែលមិនទាន់ដាច់ នៅសាលាឃុំ ឬសង្កាត់ ។ ក្នុងករណីសៀវភៅអត្រានុកូលដ្ឋានបានវិនាសដោយមានកំណត់ហេតុត្រឹមត្រូវ ហើយមានសេចក្តីណែនាំពីអន្តរក្រសួង ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ទើបធ្វើការចម្លង ឬសម្រង់ចេញពី សន្លឹកអត្រានុកូលដ្ឋាន ដែលសាមីខ្លួនអ្នកសុំមាន ហើយយកទៅប្រើការបាន ។

**មាត្រា ៥១.-**

ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ ឬសាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬសង្កាត់ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬខណ្ឌ និងបោះត្រាផង ។

**មាត្រា ៥២.-**

ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាស្រុក ឬខណ្ឌ ឬនៅតុលាការខេត្ត ក្រុងសាមី ។

ការសុំចម្លង ឬសម្រង់នៅសាលាស្រុក ឬសាលាខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬខណ្ឌ និងបោះត្រាផង ។

ការសុំចម្លង ឬសម្រង់នៅតុលាការខេត្ត ក្រុង ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងត្រូវបញ្ជាក់ហត្ថលេខានោះ ដោយប្រធានតុលាការ ឬចៅក្រមជំនួស និងបោះត្រាផង ។

**មាត្រា ៥៣.-**

ពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ការសុំចម្លង ឬសម្រង់អត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង ។

ការសុំចម្លង ឬសម្រង់អត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវសុំចម្លង ឬសុំស្រង់នៅក្រសួងមហាផ្ទៃ ឬនៅក្រសួងយុត្តិធម៌ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់ទុកនៅទីនោះ ។

## ជំពូកទី ១១

## អំពីការទទួលខុសត្រូវចំពោះមុខច្បាប់

## ស្តីពីការងារអត្រានុកូលដ្ឋាន

**មាត្រា ៥៤.-**

សាមីខ្លួន និង ឬអ្នករាយការណ៍ និង ឬសាក្សី ត្រូវសំដែងនូវការស្មោះត្រង់ ចំពោះការបញ្ជាក់អះអាងរបស់ខ្លួនអំពីហេតុការណ៍ដែលកើតមានឡើង ហើយដែលខ្លួនបានដឹងឮ ឬឃើញផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្តីពីអត្រានុកូលដ្ឋានតាមប្រភេទ ។

**មាត្រា ៥៥.-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ។ បើមានមន្ត្រីអត្រានុកូលដ្ឋានណាម្នាក់មានការឃុបឃិត ឬក្លែងបន្លំដោយចេតនា ក្នុងការធ្វើសំបុត្រអត្រានុកូលដ្ឋាន ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

សំបុត្រអត្រានុកូលដ្ឋានក្លែងបន្លំដែលបានចេញរួចហើយ ត្រូវប្រមូលយកមកវិញ និងប្តឹងទៅតុលាការ ដើម្បីបដិសេធ និងសុំផ្តន្ទាទោសតាមច្បាប់ ។

## ជំពូកទី១២

## អំពីថវិការអត្រានុកូលដ្ឋាន

**មាត្រា ៥៦.-**

ការបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាល អំពីការងារអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេសត្រូវស្ថិតនៅក្នុងបន្ទុកថវិការដ្ឋ ។

**មាត្រា ៥៧.-**

ក្រសួងមហាផ្ទៃត្រូវលើកគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ការសុំបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាលការងារអត្រានុកូលដ្ឋាន ។

**មាត្រា ៥៨.-**

ការសុំចុះសំបុត្រអត្រានុកូលដ្ឋាន កំណើត និងមរណភាព អ្នកមកសុំមិនតម្រូវឱ្យបង់ថ្លៃអ្វីឡើយ ។

ការសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និងការចុះសំបុត្រអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ ការសុំបញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព អ្នកសុំត្រូវបង់ថ្លៃក្រដាសតាមការកំណត់ ។

រាល់ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានអ្នកមកសុំត្រូវបង់ថ្លៃក្រដាស និងថ្លៃបិទតែមប្រិ៍ ដើម្បីជាប្រយោជន៍សម្រាប់ ឃុំ ឬសង្កាត់ និងចំណូលថវិការដ្ឋ ។

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រិ៍ត្រូវកំណត់ដោយអនុក្រឹត្យ តាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ១៣

## អន្តរប្បញ្ញត្តិ

**មាត្រា ៥៩.-**

ការសុំបញ្ជាក់អត្រានុកូលដ្ឋានមានចុះសៀវភៅបញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។ ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋាន កំណើត និងមរណភាព ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន ។ ឯការបញ្ជាក់អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍អនុញ្ញាតឱ្យប្តីប្រពន្ធសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

**មាត្រា ៦០.-**

ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនរបស់ជន

ណាម្នាក់ផ្សេងទៀត ។

**មាត្រា ៦១.-**

រាល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ចាស់ ដែលមានស្រាប់ពីសង្គមមុនៗ និងអត្រានុកូលដ្ឋានក្រោយឆ្នាំ ១៩៧៨ហើយរក្សាទុករហូតដល់បច្ចុប្បន្ន សាមីខ្លួនត្រូវយកមកបង្ហាញមន្ត្រីអត្រានុកូលដ្ឋានបច្ចុប្បន្ន ដើម្បីចុះក្នុងសៀវភៅអត្រានុកូលដ្ឋានតាមគំរូថ្មី សម្រាប់ប្រើប្រាស់ទៅថ្ងៃក្រោយ ។

**មាត្រា ៦២.-**

ក្នុងករណីដែលពិនិត្យឃើញសំបុត្រអត្រានុកូលដ្ឋានចាស់ពីមុនណាមួយ ដែលមានលក្ខណៈពុំត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រមូលសំបុត្រអត្រានុកូលដ្ឋាននោះមកវិញ រួចណែនាំឱ្យសាមីជនបំពេញបែបបទសុំអត្រានុកូលដ្ឋានថ្មី ។

**មាត្រា ៦៣.-**

ហាមមនុស្សម្នាក់ចុះសៀវភៅអត្រានុកូលដ្ឋានក្នុងប្រភេទនីមួយៗ លើសពី ០១ដង និងនៅច្រើនកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១៤
## អំពីទោសប្បញ្ញត្តិ

**មាត្រា ៦៤.-**

ជនណារាយការណ៍មិនពិត អំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬយកអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬរាយការណ៍សុំចុះអត្រានុកូលដ្ឋានលើសពី ០១ដង នៅទីកន្លែងដដែល ឬទីកន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រើប្រាស់អត្រានុកូលដ្ឋានក្លែង ត្រូវពិន័យ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៦៥.-**

មន្ត្រីអត្រានុកូលដ្ឋានណា សមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋ ដែលមកសុំ ឬបានទារប្រាក់លើសច្បាប់កំណត់ពីប្រជាពលរដ្ឋសម្រាប់ការងារអត្រានុកូលដ្ឋាន ត្រូវពិន័យជាប្រាក់ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

## ជំពូកទី ១៥
## អវសានប្បញ្ញត្តិ

**មាត្រា ៦៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
|---|---|---|
| **ស ខេង** | **យូ ហុកគ្រី** | **អ៊ុក វិធុន** |

**ចម្លងជូន**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៦៧

-កាលប្បវត្តិ-ឯកសារ

# ឧបសម្ព័ន្ធទី៣

## មេរៀន នីតិរដ្ឋប្បវេណី

ដកស្រង់ចេញពី គម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជា ឧបត្ថម្ភដោយអង្គការ JICA សមិទ្ធិផលរបស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចាប់ផ្តើមពីឆ្នាំ២០១២ ដល់ ២០១៧

# គន្ថីទី២៖ បុគ្គល

## *ជំពូកទី១៖ រូបវន្តបុគ្គល*

១. សមត្ថភាពទទួលសិទ្ធិ

**១.១ និយមន័យនៃសមត្ថភាពទទួលសិទ្ធិ**

សមត្ថភាពទទួលសិទ្ធិ គឺជាឋានៈដែលអាចក្លាយទៅជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។ បើមិនមានសមត្ថភាពទទួលសិទ្ធិទេ ក៏មិនអាចទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចដែរ។ សមត្ថភាពទទួលសិទ្ធិត្រូវបានទទួលស្គាល់តែចំពោះបុគ្គលប៉ុណ្ណោះ។ ផ្ទុយទៅវិញ សត្វចិញ្ចឹម មិនមានសមត្ថភាពទទួលសិទ្ធិនោះទេ ហេតុនេះហើយមិនអាចធ្វើលទ្ធកម្មសិទ្ធិតាមរយៈកិច្ចសន្យា និងមិនអាចទទួលកាតព្វកិច្ចតាមតាមរយៈអំពើអនីត្យានុកូលនោះទេ។ ឧទាហរណ៍ ម្ចាស់សត្វមិនអាចផ្ទេរសិទ្ធិទៅឲ្យសត្វដែលខ្លួនចិញ្ចឹមនោះទេ។

**១.២ គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ**

ក្រមរដ្ឋប្បវេណីបានធ្វើការបែងចែកបុគ្គលជាពីរប្រភេទគឺ រូបវន្តបុគ្គល និងនីតិបុគ្គល។ រូបវន្តបុគ្គលគឺជាមនុស្ស ហើយនីតិបុគ្គលគឺជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចពិសេសដែលទទួលស្គាល់ដោយច្បាប់។ ក្រមរដ្ឋប្បវេណីមាត្រា៦ បញ្ញត្តថា "រូបវន្តបុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច"។ មានន័យថា ក្រមរដ្ឋប្បវេណីទទួលស្គាល់ថា រូបវន្តបុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិ។

**១.៣ ពេលចាប់ផ្តើមនៃសមត្ថភាពទទួលសិទ្ធិ**

**១.៣.១ គោលការណ៍ទូទៅ**

តើរូបវន្តបុគ្គលមានសមត្ថភាពទទួលសិទ្ធិចាប់មានពីពេលណា? ក្រមរដ្ឋប្បវេណី មាត្រា៨ បញ្ញត្តថា បុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិ នៅពេលដែលចាប់កំណើត។ និយមន័យនៃការចាប់កំណើតមិនបានបញ្ញត្តច្បាស់លាស់នោះទេក្នុងក្រមរដ្ឋប្បវេណី គឺពឹងផ្អែកទៅលើការបកស្រាយរបស់កម្ពុជា។ នៅប្រទេសជប៉ុន មានការបកស្រាយជាច្រើនដូចជា ពេលដែលខ្លួនទារកទាំងមូលបានកើតផុតពីគភ៌ម្តាយ (ទ្រឹស្តីនៃការកើតផុតខ្លួនទាំងមូល) ពេលដែលទារកកើតបានមួយផ្នែកពីគភ៌ម្តាយ (ទ្រឹស្តីនៃការកើតតែមួយផ្នែក) និងពេលដែលទារកបានឯករាជ្យពីគភ៌ម្តាយ ហើយចាប់ផ្តើមដកដង្ហើម (ទ្រឹស្តីនៃការដកដង្ហើមឯករាជ្យ) ប៉ុន្តែ ទ្រឹស្តីនៃការកើតផុតខ្លួនទាំងមូល គឺគេទទួលស្គាល់ច្រើន។ នៅប្រទេសកម្ពុជា យើងអាចបកស្រាយដោយយោងតាមវចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត ពាក្យថា "ចាប់កំណើត" មានន័យថា កើតចេញពីផ្ទៃម្តាយ ឬ ចាប់ពីពេលវេលាដែលកើត។

**១.៣.២ ករណីលើកលែង**

ដូចដែលបានពិភាក្សាមុននេះ៖ ពេលចាប់ផ្តើមនៃសមត្ថភាពទទួលសិទ្ធិ គឺពេលដែលមានកំណើត។ មានន័យថា ជាគោលការណ៍ ទារកនៅមុនពេលចាប់កំណើតមិនមានសមត្ថភាពទទួលសិទ្ធិនោះទេ។ ប៉ុន្តែ ទារកដែលនៅក្នុងគភ៌ ហើយបែរជាមិនទទួលស្គាល់សិទ្ធិទាល់តែសោះ ដូចជាសន្តតិកម្មជាដើមនោះ គឺមិនស្មើភាពនោះទេ។ ហេតុនេះហើយ ក្រមរដ្ឋប្បវេណីមាត្រា៩ បានបញ្ញត្តនូវករណីលើកលែងដោយទទួលស្គាល់សមត្ថភាពទទួលសិទ្ធិរបស់ទារកក្នុងគភ៌ ដែលទាក់ទងទៅនឹងការទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល សិទ្ធិទទួលបានសន្តតិកម្ម និងអច្ច័យទាន។

### ក. ទារកនៅក្នុងគភ៌ និង អំពើអនីត្យានុកូល

ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា "ទារកដែលនៅក្នុងគភ៌នាពេលមានអំពើអនីត្យានុកូល បើទារកនោះមានកំណើតនៅពេលក្រោយ អាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួននៅក្នុងគភ៌ដោយអំពើអនីត្យានុកូលបាន"(មាត្រា ៩ កថាខណ្ឌទី ១) ទាក់ទងនឹងការទាមទារសំណងការខូចខាតដែលកើតឡើងដោយអំពើអនីត្យានុកូល ទារកក្នុងគភ៌ ត្រូវបានទទួលស្គាល់ថាមានសមត្ថភាពទទួលសិទ្ធិ។

ឧទាហរណ៍ ក្នុងករណីដែលប្តីបានរងគ្រោះថ្នាក់ចរាចរណ៍ស្លាប់ក្នុងពេលដែលប្រពន្ធកំពុងតែមានគភ៌ ទារកដែលនៅក្នុងគភ៌នាពេលដែលមានគ្រោះថ្នាក់កើតឡើង ក្រោយពេលដែលកើតមកអាចទាមទារសំណងការខូចខាតជាការខូចខាតផ្នែកស្មារតី និង ទ្រព្យសម្បត្តិដោយសារមរណភាពរបស់ឪពុក ចំពោះចារីបាន។ ប៉ុន្តែ ក្នុងមាត្រាបានបញ្ញត្តថា "បើទារកនោះមានកំណើតនៅពេលក្រោយ" ដូច្នេះហើយ ករណីទារកស្លាប់ពេលសម្រាលម្តាយជាដើមមិនអាចធ្វើសន្តតិកម្មសិទ្ធិទាមទារសំណងការខូចខាតបានទេ ហើយនៅមុនពេលទារកចាប់កំណើត ក៏ម្តាយមិនអាចធ្វើជាអ្នកតំណាងទារកក្នុងផ្ទៃ ដើម្បីទាមទារសំណងការខូចខាតបានដែរ (មាត្រា៧៦០ កថាខណ្ឌទី២)។

### ខ. ទារកនៅក្នុងគភ៌ និង សន្តតិកម្ម

ក្រមរដ្ឋប្បវេណី ក៏បានទទួលស្គាល់ជាករណីលើកលែងចំពោះទារកក្នុងគភ៌នូវសមត្ថភាពទទួលសិទ្ធិដែលទាក់ទងនឹងសន្តតិកម្ម ដោយបញ្ញត្តថា "ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលមត៌ក ដោយសន្តតិកម្មនោះបាន" (មាត្រា៩ កថាខណ្ឌទី២)។ មានន័យថា ករណីដែលឪពុកបានទទួលមរណភាពនៅពេលដែលម្តាយកំពុងតែមានគភ៌ កូនដែលនៅក្នុងគភ៌នោះ នៅពេលកើត អាចទទួលសន្តតិកម្មនូវទ្រព្យសម្បត្តិរបស់ឪពុកបាន។ ករណីទារកនោះស្លាប់នៅពេលសម្រាលគឺមិនអាចធ្វើសន្តតិកម្មពីទ្រព្យសម្បត្តិរបស់ឪពុកបានទេ ហើយនៅពេលម្តាយកំពុងមានគភ៌ ម្តាយមិនអាចតំណាងឲ្យទារកក្នុងគភ៌ ទាមទារឲ្យចែកមត៌កបានទេ។

### គ. ទារកនៅក្នុងគភ៌ និងអច្ច័យទាន

ករណីអច្ច័យទាន ទារកនៅក្នុងគភ៌ ក៏ត្រូវបានទទួលស្គាល់នូវសមត្ថភាពទទួលបានសិទ្ធិតាមរយៈមតកសាសន៍ (មាត្រា៩ កថាខណ្ឌទី៣)។ នេះមានន័យថា ឪពុកអាចធ្វើអច្ច័យទានទៅឲ្យទារកមុនពេលមានកំណើតក្នុងនាមជាអច្ចលាភីបាន ហើយបើទារកនោះចាប់កំណើតនៅពេលក្រោយ ទារកនោះអាចធ្វើលទ្ធកម្មទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃអច្ច័យទានបាន។

**ករណីសិក្សា**

X ជាប្តី ហើយ Y ជាប្រពន្ធ។ Y មានគភ៌កូនរបស់ X។ X បានទទួលមរណភាពដោយសារគ្រោះថ្នាក់ចរាចរណ៍។ តើ Y អាចតំណាងឲ្យទារកក្នុងគភ៌ ហើយទាមទារសំណងការខូចខាតបាន ឬទេ? (ប្រភព៖ យុត្តិសាស្ត្រតុលាការកំពូលនៅប្រទេសជប៉ុន)

ជាគោលការណ៍ រូបវន្តបុគ្គលទទួលបានសមត្ថភាពទទួលសិទ្ធិតាមរយៈការចាប់កំណើត ដូច្នេះទារកក្នុងគភ៌ គឺមិនមានសមត្ថភាពទទួលសិទ្ធិនោះទេ។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីបានទទួលស្គាល់សមត្ថភាពទទួលសិទ្ធិរបស់ទារកក្នុងគភ៌ ដោយកម្រិតក្នុងករណី៣យ៉ាងគឺ ការទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល សន្តតិកម្ម និងអច្ច័យទាន។ នេះមានន័យថា នៅក្រោយពេលចាប់កំណើត ទារកក្នុងគភ៌អាចទាមទារសំណងការខូចខាតចំពោះជនបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍បាន។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីបញ្ញត្តថា បើទារកនោះ

មានកំណើតនៅពេលក្រោយ អាចទាមទារសំណងការខូចខាតបាន ដូច្នេះហើយ យើងអាចពិចារណាបានថា នៅដំណាក់កាលមុនពេលមានកំណើត គឺមិនអាចទាមទារសំណងការខូចខាតបានទេ។ ដូចនេះ ក្នុងករណីសិក្សានេះ Y ដែលជាម្ដាយរបស់ទារកក្នុងគភ៌ មិនអាចតំណាងឲ្យទារកក្នុងគភ៌ ហើយទាមទារសំណងការខូចខាតបានទេ។

### ១.៤ ពេលបញ្ចប់សមត្ថភាពទទួលសិទ្ធិ

#### ១.៤.១ មរណភាព

យើងបានសិក្សាហើយថា ពេលចាប់ផ្តើមនៃសមត្ថភាពទទួលសិទ្ធិគឺនៅពេលមានកំណើត។ ចំណែកឯពេលបញ្ចប់សមត្ថភាពទទួលសិទ្ធិវិញ គឺនៅពេលមរណភាព (មាត្រា៨)។

#### ១.៤.២ ការប្រកាសអំពីការបាត់ខ្លួន

##### ក. និយមន័យនៃការប្រកាសអំពីការបាត់ខ្លួន

ការប្រកាសអំពីការបាត់ខ្លួន គឺជាស្ថានភាពដែលចាត់ទុកថាបុគ្គលនោះបានទទួលមរណភាពទៅលើទំនាក់ទំនងគតិយុត្តជុំវិញលំនៅដ្ឋានដើម តាមរយៈនីតិវិធីដែលបានកំណត់ ក្នុងករណីដែលពុំមានដំណឹងច្បាស់លាស់ថា បុគ្គលនោះនៅរស់ ឬស្លាប់ក្នុងអំឡុងពេលកំណត់។ ក្នុងករណីដែលពុំមានដំណឹងរយៈពេលយូរថា បុគ្គលនោះនៅរស់ ឬស្លាប់ ទ្រព្យសម្បត្តិដែលបានបន្សល់ទុកនោះ ទោះដល់ពេលណាក៏ដោយ ក៏មិនអាចធ្វើសន្តតិកម្មបានទេ តែចាំបាច់ត្រូវមានអ្នកគ្រប់គ្រងបន្ត ហើយសហព័ទ្ធក៏មិនអាចរៀបអាពាហ៍ពិពាហ៍ម្តងទៀតទេ។ ដូច្នេះ ក្រមរដ្ឋប្បវេណីបញ្ញត្តនូវប្រព័ន្ធនៃការប្រកាសអំពីការបាត់ខ្លួននេះឡើង ដើម្បីអាចធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិ និងសហព័ទ្ធម្ខាងទៀតអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។

##### ខ. លក្ខខណ្ឌនៃការប្រកាសអំពីការបាត់ខ្លួន

ការប្រកាសអំពីការបាត់ខ្លួនមាន២ប្រភេទគឺ ការបាត់ខ្លួនធម្មតា និងការបាត់ខ្លួនពិសេស ហើយលក្ខខណ្ឌក៏ខុសគ្នាដែរ។

ការប្រកាសអំពីការបាត់ខ្លួនធម្មតា គឺនៅពេលមិនមានដំណឹងច្បាស់លាស់រយៈពេល៥ឆ្នាំថា បុគ្គលដែលអវត្តមាននោះនៅរស់ ឬស្លាប់។ តុលាការ អាចប្រកាសអំពីការបាត់ខ្លួនតាមពាក្យសុំរបស់ សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬអ្នកផ្សេងទៀតដែលមានប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន (មាត្រា៤១ កថាខណ្ឌទី១)។ ឧទាហរណ៍ ករណីដែលមិនច្បាស់ពីដំណឹង រយៈពេលលើសពី៥ឆ្នាំ អំពីប្តីដែលបានចាកចេញពីផ្ទះថានៅរស់ ឬស្លាប់ ប្រពន្ធអាចទាមទារឲ្យប្រកាសអំពីការបាត់ខ្លួនបាន។

ការបាត់ខ្លួនពិសេស គឺអនុវត្តទៅលើករណីដែលមិនច្បាស់ថាបុគ្គលដែលជួបប្រទះនឹងគ្រោះថ្នាក់នៅរស់ ឬស្លាប់។ បុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬបុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឲ្យទទួលមរណភាព ហើយពុំមានដំណឹងថាបុគ្គលនោះនៅរស់ ឬទទួលមរណភាព ក្នុងអំឡុងពេល១ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬក្រោយពីគ្រោះថ្នាក់នោះបានកន្លងផុតទៅតុលាការអាចប្រកាសអំពីការបាត់ខ្លួនបាន តាមពាក្យសុំរបស់អ្នកដែលមានទំនាក់ទំនងផលប្រយោជន៍ដូចខាងលើ (មាត្រា៤១ កថាខណ្ឌទី២)។

##### គ. អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន

នៅពេលប្រកាសអំពីការបាត់ខ្លួន អ្នកបាត់ខ្លួនត្រូវចាត់ទុកថាទទួលមរណភាពចំពោះទំនាក់ទំនងគតិយុត្តជុំវិញលំនៅឋាន ឬទីសំណាក់ (មាត្រា៤៣)។ នេះមានន័យថា សន្តតិកម្មអាចចាប់ផ្តើមបាន ហើយ សហព័ទ្ធអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។ ប៉ុន្តែ ត្រូវចាត់ទុកថាបានទទួលមរណភាពចំពោះតែទំនាក់ទំនងគតិយុត្តនៅជុំវិញលំនៅឋានប៉ុណ្ណោះ មិនមែនដកហូតនូវសមត្ថភាពទទួលសិទ្ធិរបស់បុគ្គលនោះទេ ដូច្នេះហើយបើបុគ្គលនោះនៅរស់ ហើយរស់នៅកន្លែងផ្សេង បុគ្គលនោះអាចធ្វើលទ្ធកម្មនូវសិទ្ធិ និងកាតព្វកិច្ចបាន ឧទាហរណ៍ថា បុគ្គលនោះបានបង្កើតកិច្ចសន្យា ក៏មានសុពលភាពដែរ។ ពេលដែលបង្កើតអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន ករណីការបាត់ខ្លួនធម្មតាគឺ អំឡុងពេលពេល៥ឆ្នាំ ហើយករណីការបាត់ខ្លួនពិសេស គឺពេលគ្រោះថ្នាក់នោះបានកន្លងផុត។

### ឃ. អានុភាពនៃការលុបចោលការប្រកាសអំពីការបាត់ខ្លួន

ករណីបុគ្គលដែលត្រូវបានប្រកាសថាបាត់ខ្លួន តាមពិតគឺនៅរស់ ហើយត្រលប់មកលំនៅដើមវិញ តើបុគ្គលនោះទទួលបាននូវការការពារផលប្រយោជន៍បែបណា?

ករណីដែលបានប្រកាសអំពីការបាត់ខ្លួនរួចហើយ តាមបញ្ញត្តិច្បាប់ ត្រូវចាត់ទុកថាបានទទួលមរណភាពដូច្នេះហើយ ទោះបីជាសាមីខ្លួនបានត្រលប់មកវិញក៏ដោយ ក៏អានុភាពនៃការប្រកាសអំពីការបាត់ខ្លួនមិនបាត់បង់ទេ។ ដើម្បីឲ្យការប្រកាសអំពីការបាត់ខ្លួនបាត់បង់អានុភាព ចាំបាច់ត្រូវធ្វើការលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ។ ក្រមរដ្ឋប្បវេណីបញ្ញត្តថា ប្រសិនបើមានការបញ្ជាក់ថា បុគ្គលដែលបានបាត់ខ្លួននៅរស់ ឬមានការបញ្ជាក់ថាទទួលមរណភាពនៅពេលខុសពីពេលដែលបានកំណត់ តុលាការត្រូវលុបចោលការប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់សាមីខ្លួន ឬបុគ្គលដែលមានផលប្រយោជន៍ (មាត្រា៤៤ កថាខណ្ឌទី១)។

នៅពេលដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល គេចាត់ទុកថាការប្រកាសអំពីការបាត់ខ្លួននោះមិនមានតាំងពីដំបូង។ ដូចនេះហើយ ទើបមានការព្រួយបារម្ភអំពីការបាត់បង់ផលប្រយោជន៍របស់បុគ្គលដែលបានធ្វើលទ្ធកម្មទ្រព្យសម្បត្តិ បុគ្គលដែលធ្វើពាណិជ្ជកម្មជាមួយបុគ្គលធ្វើលទ្ធកម្មនោះ និងសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ថ្មីក្រោយពីការប្រកាសអំពីការបាត់ខ្លួនជាដើម ដោយសារការប្រកាសអំពីការបាត់ខ្លួន។ មូលហេតុនេះហើយ ទើបក្រមរដ្ឋប្បវេណីបង្កើតឡើងនូវបញ្ញត្តិដើម្បីគ្រប់គ្រងទៅលើផលប្រយោជន៍ និងការខាតបង់នេះឡើង។ ដំបូង បុគ្គលដែលទទួលបានទ្រព្យសម្បត្តិដោយចំពោះពីបុគ្គល ដែលបាត់ខ្លួនដោយសារអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន គឺត្រូវបាត់បង់សិទ្ធិដោយសារការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន ប៉ុន្តែ បុគ្គលដែលបានធ្វើលទ្ធកម្មដោយសុចរិតរួចហើយ គឺសងត្រឹមតែកម្រិតនៃផលប្រយោជន៍ ដែលខ្លួននៅតែទទួលផលប្រយោជន៍[1]ប៉ុណ្ណោះ (មាត្រា៤៤ កថាខណ្ឌទី២)។ ពាក្យថា "បុគ្គលដែលទទួលបានទ្រព្យសម្បត្តិដោយចំពោះ" គឺសំដៅ ទៅលើសន្តតិជន ឬអ្នកទទួលប្រាក់ធានារ៉ាប់រងអាយុជីវិតជាដើម។

ក្នុងករណីសន្តតិជនដែលធ្វើសន្តតិកម្ម ទៅលើទ្រព្យសម្បត្តិរបស់បុគ្គលដែលបានបាត់ខ្លួន ដោយសារការប្រកាសអំពីការបាត់ខ្លួន មិនបានដឹងថាការប្រកាសអំពីការបាត់ខ្លួននោះ ផ្ទុយពីការពិត គ្រាន់តែសងទ្រព្យសម្បត្តិដែលនៅសល់គឺគ្រប់គ្រាន់ ហើយមិនមានករណីយកិច្ចក្នុងការសងទ្រព្យសម្បត្តិដែលបានប្រើប្រាស់ពីមុននោះទេ។ ផលប្រយោជន៍ដែលនៅសល់ គឺរួមបញ្ចូលការចំណាយលើថ្លៃជីវភាពប្រចាំថ្ងៃ។ ក្រមរដ្ឋប្បវេណីបញ្ញត្តថា "អានុភាពនៃសកម្មភាពដែលបានធ្វើឡើងដោយទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន នៅក្រោយការប្រកាស

---

[1] កម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលផលប្រយោជន៍ យើងអាចធ្វើការបកស្រាយដោយប្រែប្រួលទៅតាមករណីសិក្សានីមួយៗដើម្បីកំណត់ករណីយកិច្ចរបស់បុគ្គលក្នុងការទូទាត់សំណង។ ដោយឡែក ចំពោះករណីប្រទេសជប៉ុន

អំពីការបាត់ខ្លួន ប៉ុន្តែមុនពេលលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ ពុំទទួលឥទ្ធិពល ដោយសារការលុបចោលការប្រកាសអំពីការបាត់ខ្លួនឡើយ" (មាត្រា៤៤ កថាខណ្ឌទី៣)។

ឧទាហរណ៍ ករណីដែលប្តី X បានទទួលការប្រកាសអំពីការបាត់ខ្លួន ហើយប្រពន្ធ Y ក៏បានលក់ដីដែលទទួលពីសន្តតិកម្មទៅឲ្យ Z។ ក្រោយមក ការប្រកាសអំពីការបាត់ខ្លួន X ត្រូវបានលុបចោល ហើយករណីនេះ ទាំង Y និង Z មិនបានដឹងថាការប្រកាសអំពីការបាត់ខ្លួននេះផ្ទុយនឹងការពិតនោះទេ ករណីបែបនេះ X មិនអាចទាមទារឲ្យ Z ប្រគល់ដីត្រឡប់មកវិញបានទេ។ ចំពោះករណីបែបនេះ តើចាំបាច់ត្រូវឲ្យទាំង Y និង Z ត្រូវតែសុចរិតទាំងពីរ ឬគ្រាន់តែ Z សុចរិតគឺគ្រប់គ្រាន់នោះ មានចំណុចដែលត្រូវធ្វើការបកស្រាយ។ យើងអាចពិចារណាថា ប្រសិនបើ ផ្តោតសំខាន់ទៅលើផលប្រយោជន៍របស់ X ដែលត្រូវបានប្រកាសអំពីការបាត់ខ្លួនគឺតម្រូវឲ្យទាំង Y និង Z សុចរិត ប៉ុន្តែ ប្រសិនបើផ្តោតសំខាន់ទៅលើសុវត្ថិភាពនៃពាណិជ្ជកម្ម គឺគ្រាន់តែ Z សុចរិតគ្រប់គ្រាន់ហើយ។ ប៉ុន្តែ នៅក្នុងយុត្តិសាស្ត្ររបស់ប្រទេសជប៉ុន គឺតម្រូវឲ្យទាំង Y និង Z សុចរិតមានន័យថា ទាំង Y និង Z មិនបានដឹងថាការប្រកាសអំពីការបាត់ខ្លួននោះផ្ទុយពីការពិតទេ។

ក្រមរដ្ឋប្បវេណី បញ្ញត្តទាក់ទងនឹងអានុភាពនៃអាពាហ៍ពិពាហ៍ថា "ក្នុងករណីដែលការប្រកាស អំពីការបាត់ខ្លួនត្រូវបានលុបចោល ក្រោយពេលសហព័ទ្ធរបស់បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួននោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកផ្សេងហើយ អាពាហ៍ពិពាហ៍មុនត្រូវរលាយដោយសារអាពាហ៍ពិពាហ៍ក្រោយនោះ" (មាត្រា៤៤ កថាខណ្ឌទី៤)។ <u>ឧទាហរណ៍</u> ក្នុងករណីខាងលើ ក្រោយពីប្តី X ត្រូវបានប្រកាសអំពីការបាត់ខ្លួន ប្រពន្ធ Y បានរៀបអាពាហ៍ពិពាហ៍ជាថ្មីជាមួយ Z ក្រោយមក ករណីដែលការប្រកាសអំពីការបាត់ខ្លួន X ត្រូវបានលុបចោល អាពាហ៍ពិពាហ៍រវាង X និង Y ត្រូវរលាយ ហើយមិនមានឥទ្ធិពលដល់អានុភាពនៃអាពាហ៍ពិពាហ៍របស់ Y និង Z ទេ។ ករណីនេះ ទោះបីជា Y និង Z សុចរិត ឬទុច្ចរិតក៏ដោយ ក៏អាពាហ៍ពិពាហ៍ក្រោយនៅតែមានអានុភាព។

**ករណីសិក្សា**

X ត្រូវបានប្រកាសអំពីការបាត់ខ្លួន ហើយប្រពន្ធ Y បានធ្វើសន្តតិកម្មដីរបស់ X។ Y បានធ្វើអនុប្បទានដីនោះទៅ A ហើយ A បានធ្វើអនុប្បទានបន្តទៅ B ហើយបានផ្ទេរការចុះបញ្ជី។ ក្រោយមកការប្រកាសអំពីការបាត់ខ្លួន X ត្រូវបានលុបចោល។ តើ X អាចទាមទារឲ្យ B ប្រគល់ដីមកវិញបានឬទេ? ដោយសិក្សាបែងចែកករណី AB សុចរិត និងទុច្ចរិត។ ប៉ុន្តែ Y មិនបានដឹងថាការប្រកាសអំពីការបាត់ខ្លួននេះផ្ទុយពីការពិតនោះទេ។

នៅពេលដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ត្រូវអនុវត្តដូចដែលការប្រកាសអំពីការបាត់ខ្លួននោះមិនមានតាំងពីដំបូង ប៉ុន្តែ មុនពេលលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន សកម្មភាពដែលបានធ្វើឡើងដោយទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន ពុំទទួលឥទ្ធិពលពីការលុបចោលការប្រកាសអំពីការបាត់ខ្លួនឡើយ (មាត្រា៤៤ កថាខណ្ឌទី៣)។ តើតម្រូវឲ្យភាគីទាំងសងខាងនៃកិច្ចសន្យាសុចរិត ឬគ្រាន់តែបុគ្គលដែលធ្វើលទ្ធកម្មនៃសិទ្ធិនោះសុចរិតប៉ុណ្ណោះគ្រប់គ្រាន់ហើយ គឺមានចំណុចដែលត្រូវបកស្រាយ ប៉ុន្តែ បើឈរលើការបកស្រាយខាងដើម ក្នុងករណីដែល A ទុច្ចរិត ទោះបីជា B សុចរិត ឬ ទុច្ចរិតក៏ដោយ ក៏ X អាចទាមទារចំពោះ B ឲ្យប្រគល់ដីមកវិញបាន។ ម៉្យាងវិញទៀត បើឈរលើការបកស្រាយខាងក្រោយ ប្រសិនបើ B សុចរិត ទោះបីជា A សុចរិត ឬទុច្ចរិតក៏ដោយ ក៏ X មិនអាចទាមទារឲ្យ B ប្រគល់ដីមកវិញបានទេ។ ចុះបើ A សុចរិត តែ B ទុច្ចរិត

វិញយ៉ាងដូចម្ដេចដែរ? ក្នុងករណីនេះ ទោះបីជាឈរលើការបកស្រាយខាងដើមក៏ដោយ បើ A និង Y សុចរិត នៅពេលនោះ A ត្រូវបានការពារ យើងអាចបកស្រាយបានថាទោះបីជាអ្នកទទួលបន្តក្រោយទុច្ចរិតក៏ដោយ ក៏ត្រូវការពារដែរ (គោលការណ៍ដាច់ខាត)។ ប្រសិនបើទទួលស្គាល់ការទាមទារឱ្យ B ប្រគល់ត្រឡប់ ជាហេតុធ្វើឱ្យ B មានសិទ្ធិទាមទារការទទួលខុសត្រូវឱ្យតានាចំពោះ A ដែលសុចរិត។ ទស្សនៈភាគច្រើននៅជប៉ុនអនុវត្តតាមគោលការណ៍ដាច់ខាត។

### ១.៤.៣ ការសន្មតថាបានទទួលមរណភាពព្រមពេលជាមួយគ្នា

ប្រសិនបើមិនដឹងថាទទួលមរណភាពមុន ឬក្រោយទេនឹងទៅជាយ៉ាងណា? ឧទាហរណ៍ ករណីដែលប្ដី X និងកូន Z បានទទួលមរណភាពនៅពេលជាមួយគ្នា ក្នុងគ្រោះថ្នាក់ចរាចរណ៍ ហើយករណីដែល X មានប្រពន្ធ Y និងឪពុក A ប្រសិនបើប្ដី X ទទួលមរណភាពមុន នោះប្រពន្ធ Y និងកូន Z នឹងក្លាយទៅជាសន្តតិជន ហើយ Y នឹងធ្វើសន្តតិកម្មទ្រព្យសម្បត្តិរបស់កូន Z ដូច្នេះ ប្រពន្ធ Y នឹងធ្វើលទ្ធកម្មទ្រព្យសម្បត្តិទាំងអស់។ ម៉្យាងវិញទៀត បើកូន Z ទទួលមរណភាពមុន នោះ ប្រពន្ធ Y និងឪពុក A នឹងក្លាយជាសន្តតិជន។

#### ក. លក្ខខណ្ឌ

ក្រមរដ្ឋប្បវេណីបញ្ញត្តថា "ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងទៀតបានទទួលមរណភាពទេ" (មាត្រា៤៥)។ មានន័យថា លក្ខខណ្ឌគឺសំដៅទៅលើស្ថានភាពមិនច្បាស់លាស់នៃទំនាក់ទំនងមុនក្រោយនៃការទទួលមរណភាព។ ឧទាហរណ៍ ទោះបីជាទទួលមរណភាពដោយសារគ្រោះថ្នាក់ក្នុងពេលជាមួយគ្នាក៏ដោយប្រសិនបើអាចបញ្ជាក់អំពីទំនាក់ទំនងមុននិងក្រោយនៃការទទួលមរណភាព នោះសន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកទៅលើទំនាក់ទំនងនោះ។

#### ខ. អានុភាព

ករណីដែលមិនច្បាស់លាស់អំពីទំនាក់ទំនងមុននិងក្រោយនៃការទទួលមរណភាពទេ ត្រូវយកមាត្រា៤៥ មកអនុវត្ត។ ក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពីអានុភាពនោះថា "ចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា"។ សន្តតិកម្ម គឺមានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្ដើមសន្តតិកម្មប៉ុណ្ណោះ ទើបអាចទទួលសន្តតិកម្មបាន (មាត្រា១១៤៩ កថាខណ្ឌទី១)។ ហេតុនេះ ជនដែលបានសន្មតថា បានទទួលមរណភាពព្រមពេលជាមួយគ្នា ដោយផ្អែកលើមាត្រា៤៥ មិនអាចក្លាយជាសន្តតិជនបានទេ។ មានន័យថា នៅចន្លោះនៃបុគ្គលទាំងពីរ ដែលបានសន្មតថាបានទទួលមរណភាពព្រមពេលជាមួយគ្នា ដោយផ្អែកលើមាត្រា៤៥ មិនបង្កើតឱ្យមានសន្តតិកម្មនោះទេ។

**ករណីសិក្សា**

X មានប្រពន្ធ Y កូន Z និង ឪពុក A។ X និង Z បានទទួលមរណភាពក្នុងគ្រោះថ្នាក់ចរាចរណ៍ជាមួយគ្នា ហើយមិនច្បាស់លាស់ថាបុគ្គលណាមួយទទួលមរណភាពមុន ឬក្រោយនោះទេ។ ចូរបកស្រាយ តើទ្រព្យសម្បត្តិរបស់ X នឹងត្រូវធ្វើសន្តតិកម្មដោយរបៀបណា?

ក្នុងករណីសិក្សានេះ គឺយើងមិនដឹងច្បាស់លាស់ថារវាង Z និង X តើបុគ្គលណាមួយទទួលមរណភាពមុន ឬក្រោយនោះទេ។ ដូច្នេះហើយ ផ្អែកតាមមាត្រា៤៥ ត្រូវសន្មតថាបុគ្គលទាំងពីរបានទទួលមរណភាពព្រម

ពេលជាមួយគ្នា។ ហេតុនេះ Z ដែលជាសន្តតិជនលំដាប់ទី១ មិនអាចធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់ X បានទេ (មាត្រា១១៥៦)។ ដូចនេះ ទ្រព្យសម្បត្តិរបស់ X ត្រូវធ្វើសន្តតិកម្មដោយប្រពន្ធ Y និង ឪពុក A ដែលជាសន្តតិជនលំដាប់ទី២ វិញ (យោង មាត្រា១១៥៩ និង មាត្រា១១៦១ កថាខណ្ឌទី១ និងកថាខណ្ឌទី២)។

២. សិទ្ធិបុគ្គល

**២.១ និយមន័យ**

ក្រមរដ្ឋប្បវេណីចែងអំពីសិទ្ធិបុគ្គលដែលសំដៅទៅលើ "សិទ្ធិដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិត រូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬ សិទ្ធិផ្សេងទៀតដែលជាផលប្រយោជន៍ទាក់ទងនឹងលក្ខណៈបុគ្គល" (មាត្រា១០)។ ឧទាហរណ៍ សិទ្ធិទាក់ទងនឹងការទទួលយកពន្លឺព្រះអាទិត្យ ខ្យល់អាកាស និងសិទ្ធិការពារនូវជីវភាពដោយសន្តិវិធីពីសំឡេងរំខានជាដើម។ តើសិទ្ធិ និងផលប្រយោជន៍ប្រភេទណាជាសិទ្ធិបុគ្គលនោះ ហើយតើត្រូវផ្ដល់នូវការការពារតាមផ្លូវច្បាប់ក្នុងទំហំប៉ុណ្ណាចំពោះសិទ្ធិបុគ្គលនោះ?

**២.២ អានុភាព**

ក្នុងករណីមានការបារម្ភថា នឹងមានការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់ ឬមានការបារម្ភថាការរំលោភសិទ្ធិបុគ្គលដែលបានកើតឡើងហើយនោះ នឹងអាចបន្ត ឬនឹងអាចកើតឡើងទៀតដោយខុសច្បាប់ អ្នកដែលមានសិទ្ធិបុគ្គលអាចទាមទារឲ្យបញ្ឈប់នូវការរំលោភនោះបាន (មាត្រា១១)។ ហើយប្រសិនបើលទ្ធផលនៃសកម្មភាពបំពាននៅតែបន្សល់ អ្នកដែលមានសិទ្ធិបុគ្គលអាចទាមទារឲ្យដកចេញបាន (មាត្រា១២)។ ឧទាហរណ៍ ការទាមទារឲ្យកែតម្រូវ និងប្រមូលទស្សនាវដ្ដីដែលបានចុះអត្ថបទបរិហាកេរ្តិ៍ និងអាចទាមទារឲ្យលុបចោលនូវអត្ថបទដែលបានចុះនោះ។ ប៉ុន្តែ បញ្ញត្តិស្ដីពីសិទ្ធិទាមទារឲ្យបញ្ឈប់ (មាត្រា១១) និងសិទ្ធិទាមទារឲ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ (មាត្រា១២) មិនបានហាមឃាត់ការទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលនោះទេ ដូច្នេះហើយ ប្រសិនបើល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូលត្រូវបានបំពេញ បុគ្គលដែលរងការបំពានសិទ្ធិបុគ្គលអាចទាមទារសំណងការខូចខាតបានដោយផ្អែកលើបញ្ញត្តិនៃអំពើអនីត្យានុកូល។

៣. សមត្ថភាពខាងឆន្ទៈ

**៣.១ និយមន័យ**

សមត្ថភាពខាងឆន្ទៈគឺជាសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន (មាត្រា១៤)។ បុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិ។ ប៉ុន្តែ បុគ្គលគ្រប់រូបមិនមែនសុទ្ធតែអាចធ្វើកិច្ចការ ជំនួញដែលមានសុពលភាពដោយឯកឯងគ្រប់ពេលនោះទេ។ ឧទាហរណ៍ ទោះបីជាក្មេងអាយុ៣ឆ្នាំ និងបុគ្គលដែលកំពុងតែស្រវឹងស្រាខ្លាំង បានសន្យាទិញទំនិញ ដែលមានតម្លៃថ្លៃក៏ដោយ ក៏មិនចាំបាច់ត្រូវទទួលស្គាល់នូវអានុភាពនៃកិច្ចសន្យាបែបនេះនោះទេ។ ដូចនេះ ក្រមរដ្ឋប្បវេណីបញ្ញត្តនូវប្រព័ន្ធសមត្ថភាពខាងឆន្ទៈនេះឡើង ដើម្បីអាចលុបចោលនូវសកម្មភាពរបស់បុគ្គល ដែលខ្វះសមត្ថភាពខាងឆន្ទៈ។

**៣.២ អានុភាពនៃសមត្ថភាពខាងឆន្ទៈ**

ក្រមរដ្ឋប្បវេណីចែងថា "សកម្មភាពដែលភាគីបានធ្វើឡើងនៅក្នុងស្ថានភាព ដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន" (មាត្រា១៤)។ ពាក្យសកម្មភាពដែលប្រើនៅកន្លែងនេះ គឺជាកិច្ចសន្យា និងសកម្មភាពឯកតោភាគី(មាត្រា១៥)។ ឧទាហរណ៍

ករណីដែលក្មេងអាយុ៣ឆ្នាំបានទិញរបស់ក្មេងលេងនៅទីផ្សារ កិច្ចសន្យាទិញលក់នោះអាចលុបចោលបាន។ អ្នកដែលអាចលុបចោលបាន គឺសាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ មានន័យថា អ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន (មាត្រា៣៥៩ កថាខណ្ឌទី២)។ កិច្ចសន្យាលក់ទិញនេះ ត្រូវមានសុពលភាពរហូតដល់ពេលលុបចោល (មាត្រា៣៥៨ កថាខណ្ឌទី១)។ នៅពេលកិច្ចសន្យាត្រូវបានលុបចោល ត្រូវចាត់ទុកថាកិច្ចសន្យានោះមិនមានអានុភាពតាំងពីដំបូង (មាត្រា៣៥៨ កថាខណ្ឌទី២)។ ដូចនេះ ប្រសិនបើមិនទាន់បានបង់ប្រាក់នៅឡើយទេ ក្មេងនោះមិនមានកាតព្វកិច្ចបង់ប្រាក់ទេ ប៉ុន្តែប្រសិនបើបានបង់ប្រាក់ហើយ អ្នកតំណាងរបស់ក្មេងនោះអាចទាមទារឲ្យសងប្រាក់នោះមកវិញបាន។

## ៤. សមត្ថភាពក្នុងការធ្វើសកម្មភាព

### ៤.១ និយមន័យនៃសមត្ថភាពក្នុងការធ្វើសកម្មភាព

សមត្ថភាពខាងឆន្ទៈ មានន័យថាសកម្មភាពក្នុងស្ថានភាពដែលអាចយល់ និងវិនិច្ឆ័យបាននូវលទ្ធផលតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន (មាត្រា១៤)។ ប៉ុន្តែ នៅពេលធ្វើសកម្មភាពអ្វីមួយ មានករណីជាច្រើនដែលមិនអាចធ្វើការវិនិច្ឆ័យថាអ្នកធ្វើសកម្មភាពនោះមាន ឬមិនមានសមត្ថភាពខាងឆន្ទៈ ហើយការបញ្ជាក់ក៏មិនមានភាពងាយស្រួលនោះទេ។ ឧទាហរណ៍ ក្មេងដែលមានអាយុស្មើគ្នាក៏ដោយ ក៏សមត្ថភាពមានគម្លាតខុសគ្នាដែរ ហើយករណីមានជំងឺផ្នែកបញ្ញាស្មារតី និងការស្រវឹងស្រា ក៏មានករណីជាច្រើន ដែលមិនអាចបញ្ជាក់អំពីស្ថានភាពនៃកម្រិតកង្វះសមត្ថភាពខាងឆន្ទៈបាននោះទេ។ ប្រសិនបើមិនអាចបញ្ជាក់អំពីភាពអាច ឬមិនអាចលុបចោលកិច្ចសន្យា ឬសកម្មភាពឯកតោភាគីបានទេ វាធ្វើឲ្យប៉ះពាល់ដល់សុវត្ថិភាពពាណិជ្ជកម្មរបស់ភាគីម្ខាងទៀត ព្រមទាំងមិនអាចការពារជនដែលខ្វះសមត្ថភាពខាងឆន្ទៈបានគ្រប់គ្រាន់ទៀតផង។ ហេតុនេះ ក្រមរដ្ឋប្បវេណីបង្កើតឲ្យមានរបបគតិយុត្តនៃសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់រូបវន្តបុគ្គល ដោយធ្វើការកំណត់ប្រភេទបុគ្គលដែលចាត់ទុកថា មិនមានសមត្ថភាពក្នុងការធ្វើពាណិជ្ជកម្មដោយឲ្យបុគ្គលទាំងនោះមានអ្នកអាណាព្យាបាលសម្រាប់បំពេញសមត្ថភាពនោះ។ ជាមួយគ្នានេះ សកម្មភាពដែលធ្វើឡើងដោយមិនបានទទួលការយល់ព្រមពីអ្នកអាណាព្យាបាល អាចលុបចោលបាន។ ក្រមរដ្ឋប្បវេណីបញ្ញត្តអំពីជនដែលត្រូវកម្រិតសមត្ថភាពជាពាក់ គឺ អនីតិជន ជនស្ថិតនៅក្រោមហិតូបត្ថម្ភ និងជននៅក្រោមអាណាព្យាបាលទូទៅ (មាត្រា១៦)។

### ៤.២ អនីតិជន

អនីតិជនគឺសំដៅទៅលើជនដែលមានអាយុក្រោម១៨ឆ្នាំ។ អាយុនីតិភាព ត្រូវបានកំណត់តាមរយៈទស្សនៈទូទៅក្នុងសង្គមអាស្រ័យលើប្រទេសនីមួយៗ ហើយនៅកម្ពុជាបានកំណត់យកបុគ្គលដែលមាន អាយុគ្រប់១៨ឆ្នាំ ជានីតិជន (មាត្រា១៧)។[2] យោងតាមក្រមរដ្ឋប្បវេណី ជនដែលស្ថិតនៅក្រោមរបបអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ចំពោះការអនុវត្តនូវកិច្ចគតិយុត្តតម្រូវឲ្យទទួលបានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាល។ ដូចនេះ សកម្មភាពដែលធ្វើឡើងដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន (មាត្រា១៨)។

អ្នកមានសិទ្ធិអំណាចមេបាអាចជាឪពុកម្តាយ ឪពុក ឬម្តាយ (មាត្រា១០៣៦, ១០៣៨) ឬ ឪពុកម្តាយចិញ្ចឹម (មាត្រា១០៣៥)។ ចំណែកឯ អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវចាប់ផ្តើមនៅពេលដែលមិនមាន

[2] ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា៤ កំណត់ "នីតិភាព" ចាប់ពីអាយុ២០ឆ្នាំឡើងទៅ។

អ្នកអនុវត្តសិទ្ធិអំណាចមេបាសម្រាប់អនីតិជន (មាត្រា១០៦៧)។ អ្នកដែលអាចធ្វើការលុបចោលបាន គឺសាមីខ្លួន ឬអ្នកតំណាងដែលច្បាប់បានកំណត់ មានន័យថា អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន (មាត្រា៣៥៩ កថាខណ្ឌទី២)។ អនីតិជនអាចធ្វើការលុបចោលតែម្នាក់ឯង ដោយមិនចាំបាច់ទទួលការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។ សកម្មភាពរបស់អនីតិជនក្រោមរូបភាពជាកិច្ចសន្យា ឬសកម្មភាពឯកតោភាគីដែលត្រូវបានលុបចោល នឹងត្រូវក្លាយជាមិនមានអានុភាពតាំងពីដំបូង ហើយមិនមានការខាតបង់ផលប្រយោជន៍ណាមួយទៅលើអនីតិជននោះទេ។

ប៉ុន្តែ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ មិនអាចលុបចោលបានទេ ទោះបីជាមិនបានទទួលការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនក៏ដោយ (មាត្រា១៨ វាក្យខណ្ឌទី២)។ ឧទាហរណ៍ ករណីដែលទទួលបានប្រទានកម្ម ឬរួចផុតពីកាតព្វកិច្ច អនីតិជនធ្វើសកម្មភាពដែលមានសុពលភាពតែម្នាក់ឯងបាន ដោយសារតែមិនមានការព្រួយបារម្ភអំពីការបាត់បង់ផលប្រយោជន៍របស់អនីតិជននោះទេ។ ចំពោះការទិញរបស់ប្រើប្រាស់ប្រចាំថ្ងៃជាដើម អនីតិជនអាចធ្វើតែម្នាក់ឯងបាន។ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ជាសកម្មភាពដែលមានភាពងាយស្រួលក្នុងការវិនិច្ឆ័យជាទូទៅមានតម្លៃទឹកប្រាក់ទាប ដែលមិនមានការព្រួយបារម្ភអំពីការខូចខាតផលប្រយោជន៍របស់អនីតិជន។ ធ្វើបែបនេះ អនុញ្ញាតឲ្យអនីតិជនមានភាពងាយស្រួលក្នុងការធ្វើសកម្មភាពតែម្នាក់ឯងបានដើម្បីបម្រើជីវភាពរស់នៅប្រចាំថ្ងៃ។

អនីតិជនអាចធ្វើការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឲ្យចាត់ចែង ក្នុងទំហំនៃគោលបំណងដែលបានកំណត់ (មាត្រា១៩ វាក្យខណ្ឌទី១)។ ឧទាហរណ៍ ប្រាក់ដែលឪពុកម្តាយបានឲ្យសម្រាប់ថ្លៃទិញខ្មៅដៃ នោះអនីតិជន អាចទិញខ្មៅដៃបាន។ ហើយអ្នកមានអំណាចមេបា និងអ្នកអាណាព្យាបាល អាចអនុញ្ញាតឲ្យអនីតិជនចាត់ចែងទ្រព្យសម្បត្តិដែលមិនបានកំណត់គោលដៅបាន។ ឧទាហរណ៍ ករណីដែលឪពុកម្តាយបានឲ្យប្រាក់កូន១០$ សម្រាប់ចំណាយផ្ទាល់ខ្លួន ដូចនេះអនីតិជនអាចប្រើប្រាក់១០$ នោះដើម្បីទិញទំនិញបាន។ ប្រសិនបើក្នុងទំហំទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបាជាដើម បានអនុញ្ញាតនោះ ទោះបីជាទទួលស្គាល់ឲ្យអនីតិជនចាត់ចែងម្នាក់ឯងក៏ដោយ ក៏ការព្រួយបារម្ភអំពីការបាត់បង់ផលប្រយោជន៍សំខាន់ៗចំពោះអនីតិជននោះ គឺតិចតួច ហើយប្រសិនបើមិនអាចចាត់ចែងត្រឹមកម្រិតប៉ុណ្ណឹងបាននោះទេ វានឹងធ្វើឲ្យអនីតិជនមិនមានភាពងាយស្រួល។

ទាក់ទងនឹងការប្រកបអាជីវកម្មរបស់អនីតិជន ក្រមរដ្ឋប្បវេណីចែងថា "អនីតិជនដែលបានទទួលការអនុញ្ញាតឲ្យប្រកបអាជីវកម្មមួយប្រភេទ ឬច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជនចំពោះមុខជំនួញនោះ" (មាត្រា២០ កថាខណ្ឌទី១)។ ឧទាហរណ៍ អនីតិជនដែលឪពុកម្តាយអនុញ្ញាតឲ្យបើកភោជនីយដ្ឋាន អាចធ្វើសកម្មភាពពាក់ព័ន្ធនឹងភោជនីយដ្ឋានដោយមានសុពលភាពតែម្នាក់ឯងបាន ដូចជាការទិញគ្រឿងផ្សំ និងការជួលបុគ្គលិកជាដើម ហើយសកម្មភាពទាំងនោះ មិនអាចធ្វើការលុបចោលដោយហេតុផលថាមិនមានការយល់ព្រមពីឪពុកម្តាយនោះទេ។ ប្រសិនបើសកម្មភាពពាក់ព័ន្ធនឹងការធ្វើអាជីវកម្មដែលត្រូវបានអនុញ្ញាត តែអនីតិជនមិនមានលទ្ធភាពធ្វើសកម្មភាពតែម្នាក់ឯងបាននោះ វាធ្វើឲ្យបាត់បង់នូវអត្ថន័យនៃការអនុញ្ញាតឲ្យធ្វើអាជីវកម្ម។

ក្រមរដ្ឋប្បវេណីកំណត់ពីល័ក្ខខ័ណ្ឌនាំអញ្ជាធីនភាពដូចខាងក្រោម (មាត្រា២១)៖

-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ១៦ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអព្ភាធីនភាពរបស់អ្នកនោះបានតាមពាក្យសុំរបស់អនីតិជននោះ។

-អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអព្ភាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ។

អនីតិជនដែលទទួលអព្ភាធីនភាព ត្រូវចាត់ទុកថា បានដល់នីតិភាព (មាត្រា២២)។ ហេតុនេះ អនីតិជនដែលទទួលបានអព្ភាធីនភាពអាចបង្កើតកិច្ចសន្យា និងសកម្មភាពឯកតោភាគីដោយមានសុពលភាពតែម្នាក់ឯងបាន ហើយមិនអាចធ្វើការលុបចោលសកម្មភាពទាំងនោះ ដោយហេតុថាមិនមានការយល់ព្រមពីអ្នកអាណាព្យាបាលបាននោះទេ។

### ៤.៣ ជននៅក្រោមអាណាព្យាបាលទូទៅ

ចំពោះជនដែលនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ និងបុគ្គលផ្សេងទៀតដែលបានកំណត់ក្នុងមាត្រា២៤។ ស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពសម្រាប់វិនិច្ឆ័យ និងយល់ដឹងអំពីលទ្ធផលផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន គឺសំដៅទៅលើស្ថានភាពដែលខ្វះនូវសមត្ថភាពខាងឆន្ទៈអាចមិនជាប្រចាំទេ។ ជូនកាលបុគ្គលនោះអាចមានសមត្ថភាពបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមា ដូចនេះហើយទើបមាត្រា២៤ ក៏ដូចជាមាត្រា១១០៥ អនុញ្ញាតឲ្យសាមីខ្លួននោះប្ដឹងទៅ តុលាការដើម្បីសុំប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ។ ម្យ៉ាងទៀត មាត្រា៩៥៤អនុញ្ញាតឲ្យជននៅក្រោមអាណាព្យាបាលទូទៅអាចរៀបអាពាហ៍ពិពាហ៍បាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ ប្រសិនបើគាត់មានសមត្ថភាពបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមា ដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍។

ជនដែលខ្វះនូវសមត្ថភាពខាងឆន្ទៈ អាចជាអ្នកដែលមានវិបត្តិផ្នែកបញ្ញាស្មារតីធ្ងន់ធ្ងរ និងអ្នកជំងឺដែលបាត់បង់ការចងចាំជាដើម។ បុគ្គលដែលត្រូវបានប្រកាសអំពីការចាប់ផ្ដើមអាណាព្យាបាលទូទៅ ហៅថា ជននៅក្រោមអាណាព្យាបាលទូទៅ ហើយតុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅដើម្បីថែរក្សាជននៅក្រោមអាណាព្យាបាលទូទៅនោះ (មាត្រា២៤)។ អ្នកអាណាព្យាបាលទូទៅ គឺជាអ្នកតំណាងដែលច្បាប់បានកំណត់ និងមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវធ្វើជាអ្នកតំណាងឲ្យជននោះ ចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិដែលខ្លួនគ្រប់គ្រង (មាត្រា១១១៤)។ មានន័យថា អ្នកអាណាព្យាបាលទូទៅ មានសិទ្ធិតំណាងទាំងស្រុងចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ និងសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិ លើកលែងតែសកម្មភាពបង្កើតកាតព្វកិច្ចដែលមានកម្មវត្ថុ ជាសកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ដែលតម្រូវឲ្យមានទទួលការយល់ព្រមពីជន នោះ (មាត្រា១១១៤ កថាខណ្ឌទី២)។

សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅអាចលុបចោលបាន (មាត្រា២៦ វាក្យខណ្ឌទី១)។ ទោះបីជាមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅក៏ដោយ ក៏ជននៅក្រោមអាណាព្យាបាលទូទៅមិនអាចធ្វើសកម្មភាពដែលមានសុពលភាពតែម្នាក់ឯងបានទេ ហើយសូម្បីតែធ្វើកិច្ចសន្យាក៏ដោយ ក៏កិច្ចសន្យានោះអាចលុបចោលបានដែរ។ ដោយសារតែជននៅក្រោមអាណាព្យាបាលទូទៅស្ថិតក្នុងស្ថានភាពជានិរន្តរ៍គ្មានសមត្ថភាពខាងឆន្ទៈ។ សាមីខ្លួន និងអ្នកអាណាព្យាបាលទូទៅអាចធ្វើការលុបចោលបាន (មាត្រា៣៥៩ កថាខណ្ឌទី២)។

ប៉ុន្តែ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើម្នាក់ឯងបាន (មាត្រា២៦ វាក្យខណ្ឌទី២)។ ប្រសិនបើក្នុងទំហំនៃសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ នោះមានការបារម្ភតិចតួចចំពោះការបាត់បង់ផលប្រយោជន៍សំខាន់របស់ជននៅក្រោមអាណា ព្យាបាលទូទៅ ហើយបើគ្រាន់តែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃមិនអាចធ្វើម្នាក់ឯងបានដែរនោះ នឹងធ្វើឲ្យជននៅក្រោមអាណាព្យាបាលទូទៅមានភាពមិនងាយស្រួល។

ក្នុងករណីជននៅក្រោមអាណាព្យាបាលទូទៅមានភាពប្រក្រតីផ្នែកបញ្ញាស្មារតីឡើងវិញ តុលាការ ត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ និងជនដែលបានកំណត់ផ្សេងទៀត (មាត្រា២៧)។

### ៤.៤ ជននៅក្រោមហិតូបត្ថម្ភ

ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសចាប់ផ្តើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ និងជនដែលបានកំណត់ផ្សេងទៀត (មាត្រា២៨)។ សមត្ថភាពតិចតួចពេក គឺសំដៅថាមានសមត្ថភាពខាងឆន្ទៈដែរ តែសមត្ថភាពវិនិច្ឆ័យដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិគឺទាបខ្លាំងជាងធម្មតា។ ជនដែលត្រូវបានទទួលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយតុលាការត្រូវជ្រើសរើស ហិតូបត្ថម្ភកៈ ដើម្បីថែរក្សាជននៅក្រោមហិតូបត្ថម្ភ (មាត្រា២៩)។ ជននៅក្រោមហិតូបត្ថម្ភមិនអាចធ្វើសកម្មភាពគតិយុត្តសំខាន់ៗដូចដែលបានបញ្ញត្តក្នុងមាត្រា៣០ តែម្នាក់ឯងបានទេ គឺតម្រូវឲ្យមានការយល់ព្រមពីហិតូបត្ថម្ភកៈ។ ចំពោះសកម្មភាពគតិយុត្តសំខាន់ៗដែលបានបញ្ញត្តក្នុងមាត្រា៣០ ដោយមិនបានទទួលការយល់ព្រមពីហិតូបត្ថម្ភកៈ សកម្មភាពនោះអាចលុបចោលបាន។ អ្នកមានសិទ្ធិលុបចោលគឺសាមីខ្លួន ឬហិតូបត្ថម្ភកៈ (មាត្រា៣៥៩ កថាខណ្ឌទី២)។ ជននៅក្រោមហិតូបត្ថម្ភអាចធ្វើសកម្មភាពដែលមានសុពលភាពតែម្នាក់ឯងបាន លើកលែងតែសកម្មភាពដែលត្រូវបានបញ្ញត្តក្នុងមាត្រា៣០។ ជននៅក្រោមហិតូបត្ថម្ភគឺខុសពីអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ។ ប៉ុន្តែ ទោះបីជាសកម្មភាពដែលបានបញ្ញត្តក្នុងមាត្រា៣០ក៏ដោយ ក៏មិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈនោះទេ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ ហិតូបត្ថម្ភកៈ អាចផ្តល់ការយល់ព្រមទៅជននៅក្រោមហិតូបត្ថម្ភ ចំពោះសកម្មភាពដែលមានបញ្ញត្តក្នុងមាត្រា៣០ ប៉ុន្តែ មិនមានសិទ្ធិតំណាងឲ្យសាមីខ្លួនទេ ដែលខុសពីអ្នកមានអំណាចមេបា និងអ្នកអាណាព្យាបាលទូទៅ។ មានន័យថា ហិតូបត្ថម្ភកៈមិនអាចចុះកិច្ចសន្យាក្នុង នាមជាអ្នកតំណាងឲ្យជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភបានទេ។

ករណីជននៅក្រោមហិតូបត្ថម្ភ មានភាពប្រក្រតីផ្នែកបញ្ញាស្មារតីឡើងវិញ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ និងជនដែលបានកំណត់ផ្សេងទៀត (មាត្រា៣១)។

### ៤.៥ ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព

ដូចដែលបានសិក្សាកន្លងមក សកម្មភាពរបស់ជនដែលត្រូវកម្រិតសមត្ថភាព អាចលុបចោលបាន។ ដើម្បីការពារដល់ជនដែលត្រូវបានកម្រិតសមត្ថភាព គឺត្រូវបានទទួលស្គាល់ការលុបចោល ប៉ុន្តែ ក៏ត្រូវការសិក្សាអំពីការការពារដល់ភាគីពាណិជ្ជកម្មម្ខាងទៀតផងដែរ។ ដូចនេះ ក្រមរដ្ឋប្បវេណីបានបង្កើតនូវបញ្ញត្តិដូចខាងក្រោម និងដើម្បីការពារដល់ភាគីពាណិជ្ជកម្មម្ខាងទៀត។

ជាបឋម ក្រមរដ្ឋប្បវេណីទទួលស្គាល់សិទ្ធិដាស់តឿនរបស់ភាគីម្ខាងទៀត (មាត្រា៣២)។ ប្រសិនបើមិនមានភាពច្បាស់លាស់ទេថា សកម្មភាពរបស់ជនដែលត្រូវកម្រិតសមត្ថភាពត្រូវបានលុបចោល ឬមិនលុបចោលនោះធ្វើឲ្យរំឡុងពេលនោះ ភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពដែលគ្មានស្ថិរភាព។ ដូចនេះ ក្រមរដ្ឋប្បវេណីបញ្ញត្តឲ្យភាគីម្ខាងទៀតដែលធ្វើពាណិជ្ជកម្ម អាចធ្វើការដាស់តឿនចំពោះជនដែលត្រូវបានកម្រិតសមត្ថភាពនិងអ្នកថែរក្សាជននោះឲ្យធ្វើការឆ្លើយតបថាផ្ដល់សច្ចានុម័ត ឬមិនផ្ដល់សច្ចានុម័តនូវសកម្មភាព ដែលអាចលុបចោលបានក្នុងអំឡុងពេលកំណត់មួយ។ ក្នុងករណីជនដែលត្រូវកម្រិតសមត្ថភាពមានសមត្ថភាព ឡើងវិញ ភាគីម្ខាងទៀតអាចធ្វើការដាស់តឿនចំពោះជនដែលត្រូវបានកម្រិតសមត្ថភាពដែលមានសមត្ថភាពឡើងវិញនោះ ដោយកំណត់អំឡុងពេលលើសពី មួយខែ ប្រសិនបើមិនបានឆ្លើយតបក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថាបានផ្ដល់សច្ចានុម័តចំពោះសកម្មភាពនោះ (មាត្រា៣២ កថាខណ្ឌទី១)។ ក្នុងករណី ជនដែលត្រូវកម្រិតសមត្ថភាពនោះមិនមានសមត្ថភាពឡើងវិញទេ ភាគីម្ខាងទៀតអាចធ្វើការដាស់តឿនចំពោះ អ្នកមានអំណាច មេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈ ដោយកំណត់អំឡុងពេលលើសពីមួយខែ ប្រសិនបើមិនឆ្លើយតបក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថាបានផ្ដល់សច្ចានុម័តចំពោះសកម្មភាពនោះ (មាត្រា៣២ កថាខណ្ឌទី២)។ ចំពោះជននៅក្រោមហិតូបត្ថម្ភក៏ដោយ ភាគីម្ខាងទៀតអាចធ្វើការដាស់តឿនឲ្យទទួលយកការផ្ដល់សច្ចានុម័តពី ហិតូបត្ថម្ភកៈ ដោយកំណត់អំឡុងពេលលើសពីមួយខែ ប្រសិនបើមិនបានធ្វើការឆ្លើយតបក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថាបានលុបចោលចំពោះសកម្មភាពនោះ (មាត្រា៣២ កថាខណ្ឌទី៣)។

ក្រមរដ្ឋប្បវេណីបញ្ញត្តថា ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោកដើម្បីឲ្យគេជឿជាក់ថាខ្លួនជាសមត្ថជន ជននោះមិនអាចលុបចោលសកម្មភាពបានទេ(មាត្រា៣៣)។ ឧទាហរណ៍ ករណីដែលជនដែលមានអាយុពិតប្រាកដតែ១៧ឆ្នាំ ទេ ប៉ុន្តែបានប្រាប់ទៅភាគីម្ខាងទៀតថាខ្លួនមានអាយុ១៨ឆ្នាំ។ ប្រសិនបើគ្រាន់តែ ជននោះមិនបាននិយាយថាខ្លួនឯងជាជនដែលត្រូវកម្រិតសមត្ថភាព នោះមិនមែនជាការឆបោកទេ ប៉ុន្តែ ប្រសិនបើជននោះបានប្រើពាក្យសំដីផ្សេងៗ ដែលធ្វើឲ្យភាគីម្ខាងទៀតយល់ច្រឡំ ឬករណីដែលអាចទទួលស្គាល់ថាការយល់ច្រឡំមានកម្រិតខ្ពស់ នោះអាចក្លាយទៅជាការឆបោក។ (យោងយុត្តិសាស្ត្រតុលាការកំពូលប្រទេសជប៉ុន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៦៩)។ ហើយករណីនេះក៏បូករួមទាំងការកុហកថាបានទទួលការយល់ព្រមពីអ្នកមានអំណាចមេបា និងហិតូបត្ថម្ភកៈផងដែរ។

**ករណីសិក្សា**

១. X ដែលមានអាយុ១៧ឆ្នាំ បានទិញអាវយឺតមួយតម្លៃ៥$ ដោយមិនបានទទួលការយល់ព្រមពីអ្នកមានអំណាចមេបា។ តើ X អាចលុបចោលកិច្ចសន្យាលក់ទិញនោះបានទេ?

(យោងមាត្រា១៨)

អនីតិជនដែលបានធ្វើសកម្មភាព ដោយមិនបានទទួលការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន (មាត្រា១៨ វាក្យខណ្ឌទី១)។ ប៉ុន្តែ សកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ មិនអាចលុបចោលបានទេ (មាត្រា១៨ វាក្យខណ្ឌទី២)។ ការទិញអាវយឺតតម្លៃ៥$ អាចនិយាយបានថាជាសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ ហេតុនេះ X មិនអាចធ្វើការលុបចោលកិច្ចសន្យាលក់ទិញនោះបានទេ។

២. X អាយុ១៧ឆ្នាំ បានលក់ផ្ទាំងគំនូរមានតម្លៃថ្លៃដែលបានធ្វើសន្តតិកម្មពីឪពុកទៅឲ្យ Y ក្នុង

តម្លៃ១០០០$។ X បានចំណាយប្រាក់១០០០$ នោះសម្រាប់ដើរលេង។ តើ X អាចលុបចោលកិច្ចសន្យាលក់ទិញផ្ទាំងគំនូរនោះបានទេ? ប្រសិនបើ X អាចលុបចោលកិច្ចសន្យាលក់ទិញនោះបាន តើ X ត្រូវមានករណីយកិច្ចសងប្រាក់១០០០$ ទៅ Y ឬទេ ?

(យោងមាត្រា១៨ មាត្រា៧៣៦ និងមាត្រា៧៣៧)

X បានចុះកិច្ចសន្យាលក់ទិញផ្ទាំងគំនូរជាមួយ Y ដោយមិនបានទទួលការយល់ព្រមពីអ្នកមានអំណាចមេបា។ ការទិញលក់ផ្ទាំងគំនូរដែលមានតម្លៃថ្លៃ មិនអាចនិយាយបានថាជាសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃបានទេ ហេតុនេះ កិច្ចសន្យានោះអាចលុបចោលបាន។ អ្នកមានសិទ្ធិលុបចោលគឺ សាមីខ្លួន ឬអ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា៣៥៩ កថាខណ្ឌទី២) ហេតុនេះ X អាចលុបចោលកិច្ចសន្យាលក់ទិញនោះបាន។ ក្នុងករណី កិច្ចសន្យាត្រូវបានលុបចោល ត្រូវចាត់ទុកថាកិច្ចសន្យានោះមិនមានតាំងពីដំបូង (មាត្រា៣៥៨ កថាខណ្ឌទី២)។ ដូច្នេះ ភាគីនៃកិច្ចសន្យាមានករណីកិច្ចត្រូវប្រគល់ផ្ទាំងគំនូរ និងសងប្រាក់ថ្លៃលក់ទិញទៅភាគីម្ខាងទៀត។ X បានចំណាយប្រាក់១០០០$ ដែលទទួលបានពីថ្លៃលក់ទិញនោះសម្រាប់ដើរលេងអស់ហើយ ហេតុអ្វីបានជានៅតែមានករណីកិច្ចសងប្រាក់ទៀត? ករណីដែលទទួលបានតាវកាលិកពីអ្នកដទៃដោយផ្អែកលើកិច្ចសន្យា ប្រសិនបើកិច្ចសន្យានោះបានបាត់បង់អានុភាព បុគ្គលដែលទទួលតាវកាលិកនោះ ត្រូវមានករណីកិច្ចសងផលប្រយោជន៍ ក្នុងកម្រិតផលប្រយោជន៍ដែលនៅតែមាន (មាត្រា៧៣៦ កថាខណ្ឌទី២)។ X បានចំណាយប្រាក់១០០០$ នោះសម្រាប់ដើរលេង ហើយមិននៅមានផលប្រយោជន៍នោះទេ។ ប៉ុន្តែ បើបុគ្គលដែលបានទទួលផលប្រយោជន៍មានចេតនា ឬកំហុស ចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបានបាត់បង់ បុគ្គលដែលបានទទួលផលប្រយោជន៍នោះមានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ដោយភ្ជាប់ជាមួយនឹងការប្រាក់ (មាត្រា៧៣៧ កថាខណ្ឌទី២)។ ក្នុងករណីនេះ បើយើងទទួលស្គាល់ថា X មានចេតនា ឬកំហុស ចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបាត់បង់ X មានករណីយកិច្ចត្រូវសងប្រាក់១០០០$ ដោយភ្ជាប់ជាមួយការប្រាក់។